**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Royal University of Law and Economics**


**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុ
# របស់ធនាគារជាតិ នៃ កម្ពុជា

កម្មសិក្សាពីថ្ងៃទី៣ ខែមេសា ២០១៧ ដល់ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៧

ឈ្មោះស្ថាប័ន៖ **ធនាគារជាតិ នៃ កម្ពុជា**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ ៖ **ថេង សុភ័ក្ត្រាបុត្រ**

**ឈាង សំណាង**

សាស្ត្រាចារ្យណែនាំ

**លោក ខួន ហេង**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ

ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ឈាង សំណាង និង ថេង សុភ័ក្រ្តាបុត្រ ជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១០ ក្រុម$B_4C_5$ និង ក្រុម$B_4C_1$ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។

**សូមគោរព និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**

១. **អ្នកម្តាយ លោកឪពុក** ទាំងទ្វេរដែលបានផ្តល់កំណើតដល់រូបកូន និងប្រឹងជំនះគ្រប់ឧសគ្គទាំងកម្លាំងកាយ និង កម្លាំងចិត្ត និង ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ ជាពិសេសនោះ គឺការផ្តល់ថវិការក្នុងការចំណាយលើការសិក្សារៀនសូត្រ ។

២. ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ និង មន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែង និង យកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនដល់យើងខ្ញុំ ។

៣. លោកសាស្រ្តាចារ្យណែនាំ **ខួន ហេង** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការពន្យល់ណែនាំ ផ្តល់នូវអនុសាសន៍ ព្រមទាំងកែនូវចំនុចខុសឆ្គង និង ចំនុចខ្វះខាតចាប់តាំងពីចាប់ផ្តើមសរសេររបាយការណ៍កម្មសិក្សារហូតដល់បានបញ្ចប់ដោយជោគជ័យ ។

៤. **ឯកឧត្តមទេសាភិបាល ជា ចាន់តូ** នៃធនាគារជាតិ នៃ កម្ពុជាដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចុះកម្មសិក្សា និងព្រមទាំងបុគ្គលិកធនាគារទាំងអស់ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការពន្យល់ណែនាំ និង ផ្តល់ឯកសារចាំបាច់ ក៏ដូចជាផ្តល់ពតិមានដែលទាក់ទងនឹងប្រធានបទរបស់ក្រុមយើងខ្ញុំ ។

ជាចុងក្រោយនេះ យើងខ្ញុំសូមគោរពជូនពរដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្រ្តាចារ្យណែនាំ ឯកឧត្តមទេសាភិបាលនៃធនាគារជាតិ នៃ កម្ពុជា និងមិត្តភ័ក្តិ ទាំងអស់ឲ្យជួបតែសំណាងល្អ និងពុទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែក ធនាគារ និងហិរញ្ញវត្ថុក្នុងរយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចយើងបានទទួលនូវចំនេះដឹងជាច្រើនពាក់ព័ន្ធនឹងវិស័យធនាគារ ។ ហេតុនេះហើយ សាកលវិទ្យាល័យបានផ្តល់ឱកាសឲ្យយើងខ្ញុំបានចុះកម្មសិក្សា ដើម្បីស្វែងយល់អំពីទ្រឹស្តី និង ការអនុវត្តជាក់ស្តែង ដើម្បីបង្កើនចំណេះដឹងបន្ថែម ។

អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំសុំការអនុញ្ញាតពីអង្គភាពនានា ហើយជាលទ្ធផលក៏ទទួលបានការអនុញ្ញាតពីសំណាក់ ធនាគារជាតិ នៃ កម្ពុជា ក្នុងការចុះកម្មសិក្សាដើម្បីចងក្រងរបាយការណ៍កម្មសិក្សាក្រោមប្រធានបទ "ការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុ "។

ដោយជាក់ស្តែង ប្រទេសកម្ពុជាយើងបានរងនូវឥទ្ធិពលសង្គ្រាមធ្វើឲ្យប្រជាជននៅប្រទេសកម្ពុជាបាត់បង់នូវទំនុងចិត្តលើយរូបិយវត្ថុដែលមានដុល្លារូបនីយកម្មជ្រៀតចូលធ្វើការ អនុវត្តគោលនយោបាយរូបិយវត្ថុនូវមានកម្រិត ដូចច្នេះទើបក្រុមយើងខ្ញុំសម្រេចសរសេររបាយការណ៍នេះឡើងក្នុងគោលបំណងស្វែងយល់ពីការអនុវត្ត និងការអភិវឌ្ឍជាក់ស្តែងនៃគោលនយោបាយរូបិយវត្ថុ និងឧបករណ៍រូបិយវត្ថុដែលធនាគារជាតិ នៃ កម្ពុជាបានអនុវត្តន៍ និងអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថារបាយការណ៍កម្មសិក្សានេះ និងក្លាយជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវដល់បណ្តាមិត្តនិស្សិត ដើម្បីបង្កើននូវចំណេះដឹង ។

ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំជឿជាក់ថាសៀវភៅនេះនៅតែមានចំនុចខ្វះខាត និងកំហុសឆ្គងលើផ្នែកខ្លឹមសារ ក៏ដូចជាចំណុចផ្សេងៗទៀតដោយអចេតនា ។

អាស្រ័យដូចនេះហើយ យើងខ្ញុំសូមអភ័យទោសចំពោះចំណុចខ្វះខាតទាំងនោះដែលបានកើតឡើង ហើយយើងខ្ញុំមានសេចក្តីរីករាយ ក្នុងការរងចាំទទួលការរិះគន់ដើម្បីកែលម្អបន្ថែមដើម្បីឆ្ពោះទៅរកការបង្កើនគុណភាព និងសុក្រឹតភាពនៃរបាយការណ៍នេះ ។

# មាតិកា


បញ្ជីរអក្សរកាត់........................................................................................................ vi
វាក្យស័ព្ទធនាគារ.......................................................................................................vii
បញ្ជីរឧបសម្ព័ន្ធ.......................................................................................................... ix


## សេចក្តីផ្តើម


១. លំនាំបញ្ហា.................................................................................................... ១
២. ចំណោទបញ្ហា ................................................................................................ ១
៣. គោលបំណងនៃការស្រាវជ្រាវ.............................................................................. ២
៤. សារៈសំខាន់នៃការស្រាវជ្រាវ............................................................................. ២
៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..........................................................៣
៦. វិធីសាស្រ្តស្រាវជ្រាវ ...........................................................................................៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ................................................................................ ៤


## ជំពូកទី១
## រំលឹកទ្រឹស្តី


១.១. និយមន័យ .....................................................................................................០៥
១.១.១.គោលនយោបាយរូបិយវត្ថុ.............................................................................០៥
១.១.១.១.គោលនយោបាយវិត្ថារកម្ម.....................................................................០៥
១.១.១.២.គោលនយោបាយរឹតបន្តឹង.......................................................................០៦
១.២. ឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក ..................០៦
១.២.១. ប្រតិបត្តិការទីផ្សារចំហរ .........................................................................០៦
១.២.២. អប្បហារអត្រាការប្រាក់ ...........................................................................០៧
១.២.២.១. ឥណទានដំបូង ................................................................................០៨
១.២.២.១. ឥណទានបន្ទាប់.................................................................................០៨
១.២.២.១. ឥណទានតាមរដូវកាល .......................................................................០៨
១.២.៣. ទុនបម្រុងកាតព្វកិច្ច.................................................................................០៨

១.២.៤. ការប្រាក់លើសមតុល្យប្រាក់បម្រុងកាតព្វកិច្ច និងសមតុល្យអតិរេក ................០៩
១.២.៥. កិច្ចសន្យាទិញត្រលប់........................................................................១០
១.២.៦. ឥណទានមានកាលកំណត់..................................................................១០
១.២.៧.ឧបករណ៍គោលនយោបាយផុតកំណត់.....................................................១១
១.៣. គោលនយោបាយផ្សេងទៀត.......................................................................១២
១.៣.១. គោលក្រោមសូន្យ...............................................................................១២
១.៣.១.១. Credit Easing ..............................................................................១២
១.៣.១. Quantitative Easing.........................................................................១៣
១.៣.១. Forward Guidance ..........................................................................១៣

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ ធនាគារជាតិ នៃកម្ពុជា

២.១. ប្រវត្តិនៃការកកើតធនាគារជាតិនៃកម្ពុជា ......................................................១៥
២.១.១. ដំណាក់កាល ២០ឆ្នាំ មុនឆ្នាំ ១៩៧៥.............................................................១៥
២.១.២. ដំណាក់កាល ២០ឆ្នាំ ក្រោយឆ្នាំ ១៩៧៩ ........................................................១៥
២.១.៣. ដំណាក់កាលពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ ......................................................១៦
២.១.៤. ដំណាក់កាលក្រោយឆ្នាំ ១៩៩៣ រហូតដល់បច្ចុប្បន្ន .............................................១៨
២.២. អត្តសញ្ញាណរបស់ធនាគារជាតិ..................................................................១៨
២.២.១. រូបសញ្ញា...........................................................................................១៨
២.២.២. ផ្លាកសញ្ញា.........................................................................................១៩
២.២.២. អត្ថន័យរូបសញ្ញា ................................................................................១៩
២.៣. បេសកកម្ម..............................................................................................១៩
២.៤. មុខងារ និងភារកិច្ចទូទៅរបស់ធនាគារជាតិនៃកម្ពុជា..............................................១៩
២.៥. រចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា .......................................២០
២.៥.១. រចនាសម្ព័ន្ធ........................................................................................២០
២.៥.១.១. អគ្គលេខាធិការដ្ឋាន ..........................................................................២០

២.៥.១.២. អគ្គនាយកដ្ឋានត្រួតពិនិត្យ ........................................ ២១
២.៥.១.៣. អគ្គធិការដ្ឋាន ........................................ ២២
២.៥.១.៤. អគ្គលេខា ........................................ ២៣
២.៥.១.៥. អគ្គនាយដ្ឋានបច្ចេកទេស ........................................ ២៣

## ជំពូកទី៣

## ការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

៣.១. ស្ថានភាពដុល្លារូបនីយកម្ម និងទិដ្ឋភាពទូទៅនៃប្រាក់រៀលនៅកម្ពុជា ........................................ ៣២
៣.១.១. បទពិសោធន៍នៃការធ្វើបដិដុល្លារូបនីយកម្ម........................................ ៣២
៣.១.២. ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា........................................ ៣៣
៣.១.៣. ស្ថានភាព និងការបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល ........................................ ៣៤
៣.១.៣.១.ប្រវត្តិរូបិយវត្ថុកម្ពុជា........................................ ៣៤
៣.១.៣.២.ស្ថានភាព និងការប្រែប្រួលតម្លៃនៃប្រាក់រៀល ........................................ ៣៤
៣.២. គណៈកម្មាធិការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុ ........................................ ៣៧
៣.៣. ឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ........................................ ៣៨
៣.៣.១. គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់........................................ ៣៨
៣.៣.២. ប្រាក់បម្រុងកាតព្វកិច្ច........................................ ៣៩
៣.៣.៣. មូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា (NCD)........................................ ៤០
៣.៣.៣.១. មូលហេតុនៃការបង្កើតអោយមានមូលបត្រ
ដែលអាចជួញដូរបាន ........................................ ៤០
៣.៣.៣.២. លក្ខណៈទូទៅរបស់មូលបត្រអាចជួញដូរបាន ........................................ ៤១
៣.៣.៣.៣.គុណសម្បត្តិនៃមូលបត្រអាចជួញដូរបាន........................................ ៤១
៣.៣.៣.៤. គុណវិបត្តិនៃមូលបត្រអាចជួញដូរបាន ........................................ ៤៣
៣.៣.៣.៥. ការស្នើរសុំ និងប្រតិបត្តិការមូលបត្រអាចជួញដូរបាន ........................................ ៤៣
៣.៣.៤. ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ........................................ ៤៥
៣.៣.៤.១.គោលដៅនៃការបង្កើតប្រតិបត្តិការ

ផ្តល់សន្ទនីយភាពដោយមានការធានា ..............................................................៤៦
៣.៣.៤.២. លក្ខណៈរបស់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ... ៤៧
៣.៣.៤.៣. ការស្នើរសុំ និងប្រតិបត្តិការរបស់ប្រតិបត្តិការផ្តល់សន្ទនីយ
ភាពដោយមានការធានា........................................................................៤៨

# ជំពូកទី៤

# ការវិភាគទិន្នន័យ និងប្រសិទ្ធភាពនៃការអនុវត្តឧបករណ៍គោលនយោបាយ រូបិយវត្ថុ របស់ធនាគារជាតិ នៃកម្ពុជា

៤.១.និន្នន័យនៃមូលបត្រដែលអាចជួញដូរបានជាប្រាក់រៀល និងដុល្លារអាមេរិក
២០១៣-២០១៧ ..................................................................................................៥០
៤.១.១. តារាងទិន្នន័យនៃមូលបត្រអាចជួញដូរបានជាប្រាក់រៀលឆ្នាំ ២០១៣-២០១៧ ......៥០
៤.១.២. ក្រាហ្វិចនៃមូលបត្រអាចជួញដូរបានជាប្រាក់រៀល ...........................................៥០
៤.១.៣. ការវិភាគទិន្នន័យនិងបកស្រាយតាមក្រាហ្វិចNCDsដែលបានចេញផ្សាយ
ជាប្រាក់រៀលពីឆ្នាំ ២០១៣-២០១៧ ..........................................................៥១
៤.១.៤. តារាងទិន្នន័យនៃមូលបត្រដែលអាចជួញដូរបានជាប្រាក់ដុល្លាអាមេរិក
២០១៣ ដល់ ២០១៧ .........................................................................៥១
៤.១.៥. ក្រាហ្វិចរបស់មូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិក ........................៥១
៤.១.៦. ការវិភាគទិន្នន័យ និងបកស្រាយតាមក្រាហ្វិចNCDsដែលបានចេញផ្សាយជា
ប្រាក់ដុល្លាអាមេរិក.......................................................................... ៥២
៤.២. ទិន្នន័យនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា
ឆ្នាំ២០១៦-២០១៧................................................................................................៥៤
៤.២.១. តារាងទិន្នន័យនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា
ឆ្នាំ ២០១៦- ២០១៧ ........................................................................ ៥២
៤.២.២. ក្រាហ្វិច នៃប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានា.........................៥៣
៤.២.៣.ការវិភាគទិន្នន័យនិងបកស្រាយប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា
ឆ្នាំ ២០១៦-២០១៧ ..........................................................................៥៣
៤.៣. ការវិភាគ (SWOT)...........................................................................................៥៤
៤.៣.១. ចំណុចខ្លាំង ...............................................................................................៥៤

៩.៣.២. ចំណុចខ្សោយ ..................................................................................................៥៥
៩.៣.៣. ឱកាស ..........................................................................................................៥៥
៩.៣.៤. ការគំរាមគំហែង ..............................................................................................៥៦

## សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

សេចក្តីសន្និដ្ឋាន ........................................................................................................ ៥៧
ការផ្តល់អនុសាសន៍ ..................................................................................................... ៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | | |
|---|---|---|---|
| ABIF | : | ក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | ASEAN Banking Integration |
| ADB | : | ធនាគារអភិវឌ្ឍន៍អាស៊ាន | Asian Development Bank |
| BIS | : | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| Brexit | : | ការចាកចេញរបស់អង្គគ្លេសពីសហភាពអឺរ៉ុប | British exit from European Union |
| NCDs | : | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposits |
| LPCO | : | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-providing Collateralized Operation |
| NEER | : | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម | Nominal Effective Exchange Rate |
| REER | : | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត | Real Effective Exchange Rate |
| BOP | : | ជញ្ជីងទូទាត់ | Balance of Payment |

# វាក្យស័ព្ទធនាគារ

**ធនាគារកណ្តាល** (Central Bank)៖ គឺស្ថាប័នជាតិមួយទទួលខុសត្រូវចំពោះការត្រួតពិនិត្យប្រព័ន្ធរូបិយវត្ថុជាតិ។ ធនាគារកណ្តាលមានទំនួលខុសត្រូវខ្ពស់ក្នុងការត្រួតពិនិត្យមើលគោលនយោបាយរូបិយវត្ថុ ដើម្បីអនុវត្តឲ្យបាននូវគោលដៅជាក់លាក់មួយដូចជា ស្ថិរភាពរូបិយវត្ថុ អតិផរណាទាប និង ការងារពេញលេញ។ តួនាទីរបស់ធនាគារកណ្តាលជាទូទៅគឺ បោះពុម្ពលុយ បទបញ្ញត្តិប្រព័ន្ធឥណទាន ត្រួតពិនិត្យធនាគារពាណិជ្ជ គ្រប់គ្រងទុនបម្រុងអន្តរជាតិ និងដើរតួជាអ្នកឲ្យខ្ចីចុងក្រោយ។

**អត្រាប្តូរប្រាក់** (Interest rate) ៖ គឺជាតម្លៃរូបិយវត្ថុរបស់ប្រទេសមួយធៀបនឹងរូបិយប័ណ្ណរបស់ប្រទេសដ៏ទៃទៀត។ អត្រាប្តូរប្រាក់អាចមានន័យដូចខាងក្រោម ៖

- នៅក្នុងន័យផ្ទាល់៖ តម្លៃក្នុងមួយឯកតារូបិយប័ណ្ណបរទេសគិតជារូបិយវត្ថុក្នុងស្រុក
- នៅក្នុងន័យប្រយោល៖ តម្លៃក្នុងមួយឯកតានៃរូបិយវត្ថុក្នុងស្រុកគិតជារូបិយប័ណ្ណបរទេស

**ទុនបម្រុងអន្តរជាតិ** (International Reserve)៖ សំដៅលើទ្រព្យសម្បត្តិជារូបិយប័ណ្ណដែលកាន់កាប់ដោយធនាគារកណ្តាលនៃប្រទេសមួយ ។ ទ្រព្យសម្បត្តិនោះរួមមាន សញ្ញាប័ណ្ណទីផ្សារអន្តរជាតិ (foreign marketable securities) មាស Special Drawing Rights (SDRs) និងទុនបម្រុងនៅមូលនិធិរូបិយវត្ថុអន្តរជាតិ។ គោលបំណងសំខាន់នៃការកាន់ទុនបម្រុងអន្តរជាតិគឺ ដើម្បីធ្វើការទូទាត់ជាលក្ខណៈអន្តរជាតិ និងការពារនូវហានិភ័យអត្រាប្តូរប្រាក់ ។

**អតិផរណា** (Inflation)៖ ជាការកើនឡើងកម្រិតថ្លៃជាទូទៅនៃទំនិញ និងសេវាក្នុងសេដ្ឋកិច្ច ។ អតិផរណាត្រូវបានគណនាជាភាគរយ និងវាស់វែងកំណើនជា ខែ ត្រីមាស និង ឆ្នាំ ។

**ទីផ្សាររូបិយវត្ថុអន្តរធនាគារ** (Interbank Money Market)៖ ទីផ្សារមួយដែលធនាគារផ្តល់ និងខ្ចីពីគ្នាទៅវិញទៅមក ។

**អត្រាការប្រាក់** (Interest Rate)៖ គឺអត្រាដែលការប្រាក់ត្រូវបានបង់ដោយអ្នកខ្ចី (កូនបំណុល) សម្រាប់ប្រាក់ដែលអ្នកខ្ចីបានខ្ចីពីអ្នកផ្តល់កម្ចី (ម្ចាស់បំណុល) ។ អត្រាការប្រាក់ជាធម្មតាត្រូវបានគិតជាភាគរយក្នុងរយៈពេលមួយឆ្នាំ ។

**មូលនិធិរូបិយវត្ថុអន្តរជាតិ** (International Monetary Fund-IMF)៖ អង្គការអន្តរជាតិ ដែលបានបង្កើតឡើងនៅឆ្នាំ១៩៤៥ ក្នុងគោលបំណងលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិ និងសហា

ប្រតិបត្តិការរូបិយវត្ថុ ជួយសម្របសម្រួលពាណិជ្ជកម្មអន្តរជាតិ និងជំរុញអនិកម្មភាព កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រក្នុងពិភពលោក ។

**សន្ទនីយភាព** (Liquidity)៖ កម្រិតដែលទ្រព្យសកម្ម ឬ សញ្ញាប័ណ្ណ អាចត្រូវបានទិញ ឬ លក់នៅក្នុងទីផ្សារ ដោយពុំមានការប៉ះពាល់ដល់តម្លៃទ្រព្យសកម្មនោះ ។ ទ្រព្យសកម្មដែលមានភាពងាយស្រួលក្នុងការ ទិញ និងលក់អាចចាត់ទុកជាទ្រព្យសកម្មដែលមានសន្ទនីយភាព ។ សន្ទនីយភាពឆ្លុះបញ្ចាំងពីសមត្ថភាព ក្នុងការបម្លែងទ្រព្យសកម្មមួយឱ្យទៅជាសាច់ប្រាក់ ។

**គោលនយោបាយរូបិយវត្ថុ** (Monetary Policy)៖ ជាមធ្យោបាយដែលអាជ្ញាធររូបិយវត្ថុរបស់ប្រទេសមួយគ្រប់គ្រងលើការផ្គត់ផ្គង់រូបិយវត្ថុក្នុងគោលបំណងកំណត់អត្រាអតិផរណា ឬ អត្រាការប្រាក់ ដើម្បីធានាបាននូវស្ថិរភាពថ្លៃ និងការជឿជាក់លើរូបិយវត្ថុជាតិ ។ គោលដៅនៃគោលនយោបាយនេះគឺរួមចំណែកដល់ស្ថិរភាព និងកំណើនសេដ្ឋកិច្ច បន្ថយអត្រានិកម្មភាព និងព្យាករណ៍អត្រាប្តូរប្រាក់ជាមួយរូបិយប័ណ្ណផ្សេងៗទៀត ។

**គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ** (Monetary Policy Committee)៖ គណៈកម្មាធិការគោលនយោបាយជាន់ខ្ពស់នៅធនាគារជាតិនៃកម្ពុជា ត្រូវបានបង្កើតឡើង ដើម្បីវាយតម្លៃការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេស និងជាអ្នកសម្រេចគោលនយោបាយរូបិយវត្ថុ ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃ ។

**មូលបត្រអាចជួញដូរបាន** (Negotiable Certificate of Deposits)៖ បំណុលមានការប្រាក់រយៈពេលខ្លីដែលបោះផ្សាយដោយធនាគារកណ្តាល ត្រូវបានកំណត់ជាប្រាក់រៀល និងដុល្លារអាមេរិកក្នុងតម្លៃប្រមាណ ២ ០០០ លានរៀល ។

**ស្ថិរភាពថ្លៃ** (Price Stability)៖ ស្ថានភាពមួយដែលថ្លៃនៅក្នុងសេដ្ឋកិច្ចមួយមិនមានការប្រែប្រួលខ្លាំងក្នុងរយៈពេលណាមួយ ។ ស្ថិរភាពថ្លៃអាចមានន័យថាសេដ្ឋកិច្ចមិនជួបប្រទះអតិផរណា ឬ បរិត្តផរណាខ្ពស់ ។

**ប្រាក់បម្រុងកាតព្វកិច្ច** (Reserve Requirements)៖ ចំនួននៃប្រាក់បញ្ញើ ដែលធនាគារពាណិជ្ជត្រូវរក្សាទុកក្នុងទម្រង់ជាសាច់ប្រាក់សុទ្ធ ឬ បញ្ញើជាមួយធនាគារកណ្តាល ។ ធនាគារកណ្តាលគឺជានិយ័តករដែលអាចកំណត់ប្រាក់បម្រុងកាតព្វកិច្ច។ ធនាគារកណ្តាលប្រើប្រាស់ប្រាក់បម្រុងកាតព្វកិច្ចជាមធ្យោបាយសម្រាប់គ្រប់គ្រងសន្ទនីយភាពក្នុងទីផ្សារ ។ ប្រាក់បម្រុងកាតព្វកិច្ចទាបអនុញ្ញាតឲ្យមានសន្ទនីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ ។ ប្រាក់បម្រុងកាតព្វកិច្ចខ្ពស់ ធ្វើឲ្យមានសន្ទនីយភាពទាប ។

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ A Reverse Repurchase Agreement
ឧបសម្ព័ន្ធ២៖ រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
ឧបសម្ព័ន្ធ៣៖ សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារជាតិនៃកម្ពុជា
ឧបសម្ព័ន្ធ៤៖ ប្រកាសស្តីពី ការចេញផ្សាយមូលបត្រដែលអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា
ឧបសម្ព័ន្ធ៥៖ ពាក្យសុំបើកគណនីបញ្ញើមូលបត្រ
ឧបសម្ព័ន្ធ៦៖ ពាក្យសុំជាវមូលបត្រអាចជួញដូរបាន
ឧបសម្ព័ន្ធ៧៖ ពាក្យសុំផ្ទេរកម្មសិទ្ធិមូលបត្រអាចជួញដូរបាន
ឧបសម្ព័ន្ធ៨៖ ពាក្យសុំលក់មូលបត្រអាចជួញដូរបាន (តែមួយ)
ឧបសម្ព័ន្ធ៩៖ ពាក្យសុំលក់មូលបត្រអាចជួញដូរបាន (ច្រើន)
ឧបសម្ព័ន្ធ១០៖ ការបរិច្ឆេទនៃការដេញថ្លៃ កាលវសាន និងការទូទាត់នៃប្រតិបត្តិផ្តល់សន្ទនីយភាពដោយមានការធានា
ឧបសម្ព័ន្ធ១១៖ ទិន្នន័យមូលបត្រអាចជួញដូរបាន
ឧបសម្ព័ន្ធ១២៖ លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការដែលមានការធានា

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសមហាអំណាចនៅលើពិភពលោក បានគិតគូរយ៉ាងខ្លាំងទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួនពីព្រោះ សេដ្ឋកិច្ចមានការអភិវឌ្ឍ ឬ រីកចម្រើនទើបនាំអោយប្រទេសមានការរីកចម្រើនទៅតាមនោះដែរ ។ ប្រទេសមួយអាចអភិវឌ្ឍន៍បានត្រូវបានពឹងផ្អែកទៅលើវិស័យ និងកត្តាជាច្រើនដោយមានរួមទាំងគោលនយោបាយរូបិយវត្ថុដែលត្រូវបាន អនុវត្តដោយធនាគារកណ្តាលនៃប្រទេសនីមួយៗដើម្បីធានាអោយបាននូវស្ថេរភាពថ្លៃ នាំអោយមានកំនើនសេដ្ឋកិច្ច ។ គោលនយោបាយរូបិយវត្ថុត្រូវបានប្រើប្រាស់ទៅតាមលក្ខខ័ណ្ឌ និងបរិបទសេដ្ឋកិច្ច ដូចជានៅពេលមានវិបត្តិសេដ្ឋកិច្ច តើគួរប្រើគោលនយោបាយ និងឧបករណ៍គោលនយោបាយរូបិយវត្ថុមួយណា ឬពេលសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍គួរប្រើគោលនយោបាយបែបណា ។ ម៉្យាងវិញទៀត ស្ថេរភាពថ្លៃគឺសំដៅទៅលើការធៀបថ្លៃនៃរូបិយវត្ថុមួយ ទៅនឹងតម្លៃទំនិញ ។ ការរក្សាស្ថេរភាពថ្លៃ មិនមែនមិនអោយតម្លៃទំនិញកើនឡើងនោះទេ តែត្រូវកើនក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ឬ ត្រូវបានចាត់ទុកថាកើនក្នុងកម្រិតមួយល្អប្រសើរ ។ តួនាទីនៃការគ្រប់គ្រងស្ថេរភាពថ្លៃ ឬ រក្សាអោយបាននូវស្ថេរភាពថ្លៃគឺជាតួនាទីរបស់ធានាគារកណ្តាលនៃប្រទេសនីមួយៗ ដោយត្រូវបង្កើត គោលនយោបាយរូបិយវត្ថុ ក្នុងការគ្រប់គ្រងស្ថានភាពរូបិយវត្ថុ ។

នៅប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជា បានបង្កើតគោលនយោបាយរូបិយវត្ថុ ដើម្បីគ្រប់គ្រងនឹងដើម្បីធានាអោយបាននៅស្ថេរភាពថ្លៃ រវាងរូបិយវត្ថុរៀលជាមួយ និងថ្លៃទំនិញ ហើយនិងដុល្លារូបនីយកម្ម ។ គោលនយោបាយរូបិយវត្ថុត្រូវបានអមជាមួយនឹងឧបករណ៍គោលនយោបាយរូបិយវត្ថុដើម្បីអាចអនុវត្តន៍បាន ហើយស្ថានភាពរូបិយវត្ថុប្រាក់រៀលនៅកម្ពុជាត្រូវការគោលនយោបាយរូបិយវត្ថុមកអភិវឌ្ឍន៍យ៉ាងចាំបាច់ ។ ធនាគារជាតិនៃកម្ពុជាបាននឹងកំពុងអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុ ជាបន្តបន្ទាប់ ដែលស្របទៅតាមបរិបទនៃស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន ។

## ២. ចំណោទបញ្ហា

ធនាគារជាតិ នៃ កម្ពុជាហៅកាត់ថា " ធនាគារកណ្តាល " គឺជាស្ថាប័នស្វយតសាធារណៈដែលមានលក្ខណៈជាពាណិជ្ជកម្ម និងឧស្សាហកម្ម ។ បេសសកម្មចម្បងគឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ ឲ្យមានស្ថិរភាពសំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន ។

- នយោបាយរូបិយវត្ថុមានគោលដៅយ៉ាងណា ?
- ដើម្បីឈានទៅសម្រេចគោលដៅរក្សាស្ថិរភាពថ្លៃ តើអាជ្ញាធរអាចប្រើឧបករណ៍អ្វីខ្លះ? ប្រសិទ្ធិភាពរបស់ឧបករណ៍មានក្នុងកម្រិតណា?
- តើឧបករណ៍គោលនយោបាយរូបិយវត្ថុជួបបញ្ហាក្នុងការអនុវត្តយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសរសេររបាយការណ៍កម្មសិក្សានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដូចខាងក្រោម ៖

- ស្វែងយល់អំពីស្ថានភាពទូទៅរបស់ ធនាគារជាតិនៃកម្ពុជា
- ស្វែងយល់អំពីការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ស្វែងយល់អំពីការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុ
- ស្វែងយល់អំពីគោលនយោបាយរូបិយវត្ថុពីបណ្តាប្រទេសនានា

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សាដែលបានរៀបចំឡើងនេះសង្ឃឹមយ៉ាងមុតមាំថានឹងផ្តល់អត្ថប្រយោ ជន៍យ៉ាងច្រើនដល់មិត្តនិស្សិត ក៏ដូចជាសាធារណៈជនដែលមានបំណងចង់ស្រាវជ្រាវដើម្បីបង្កើនចំណេះដឹងបន្ថែមទាក់ទងនឹងគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ។ អត្ថប្រយោជន៍ទាំងនេះរួមមាន ៖

- ជួយពង្រឹងនូវសមត្ថភាពរបស់និស្សិត និងសាធារណៈជនឲ្យយល់ដឹងកាន់តែច្បាស់អំពីគោលនយោបាយរូបិយវត្ថុ
- ទទួលបានចំណេះដឹងថ្មីដែលផ្សារភ្ជាប់ទំនាក់ទំនងរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- បង្កើនការយល់ដឹងថា តើប្រាក់រៀលត្រូវបានផ្តល់ទំនុកចិត្តកម្រិតណា?
- យល់ដឹងពីឧបករណ៍គោលនយោបាយរូបិយវត្ថុ ដែលបានអនុវត្តបច្ចុប្បន្នមានប្រសិទ្ធភាពកម្រិតណា
- បង្កើនសមត្ថភាពក្នុងការវិភាគ បកស្រាយទិន្នន័យ និងសកម្មភាពការងារ ។

## ៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់នៃការស្រាវជ្រាវយើងបានកំណត់តែទៅលើតែការចុះកម្មសិក្សានៅ នាយកដ្ឋានស្ថិតិ និងនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជាតែប៉ុន្មោះ ដោយចាប់ពីថ្ងៃទី៣ ខែមេសា ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ ។ ធនាគារជាតិនៃកម្ពុជា មានឧបករណ៍គោលនយោបាយបួន គឺៈ អត្រាប្តូរប្រាក់ ប្រាក់បម្រុងកាតព្វកិច្ច មូលបត្រអាចជួញដូរបាន និងប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានា ។

ចំណែកឯវិសាលភាពនៃការស្រាវជ្រាវ យើងស្រាវជ្រាវផ្តោតសំខាន់តែទៅលើឧបករណ៍គោលនយោបាយតែ ពីរមុខប៉ុណ្ណោះ គឺៈ មូលបត្រអាចជួញដូរបាន (NCDs) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានា (LPCO)។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសរសេររបាយការណ៍កម្មសិក្សានេះ យើងខ្ញុំបានប្រើវិធីសាស្ត្រដើម្បីប្រមូលទិន្នន័យដូចខាងក្រោម ៖

### ក. ទិន្នន័យចំបង

ទិន្នន័យដំបូងគឺជាទិន្នន័យទាំងឡាយណាដែលពុំមានគេប្រើប្រាស់ ឬ គេមិនទាន់បានគេធ្វើការវិភាគ និងបកស្រាយនៅឡើយ ។ ទិន្នន័យចំបងបានមកពីៈ

- ធ្វើសម្ភាសន៍បុគ្គលិកបច្ចេកទេសនៅ នាយកដ្ឋានស្ថិតិ និងនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃ ធនាគារជាតិនៃកម្ពុជា
- របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជាដែលបានបោះផ្សាយតែគេពុំទាន់បានយកមកធ្វើការវិភាគនៅឡើយ ។

### ខ. ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំនេះត្រូវបានប្រមូលពីប្រភពផ្សេងៗទៀតតាមរយៈ ៖

- សៀវភៅ របាការណ៍កម្មសិក្សា និងសារណាដែលនិស្សិតរៀមច្បងបានចងក្រង
- របាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ
- ឯកសារទទួលបានមកពីនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ
- សៀវភៅគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា
- ពត៌មានទទួលបានពី អ៊ីនធឺណែត ទស្សនាវដ្តី វេបសាយធនាគារកណ្តាលបណ្តាប្រទេសនានា និងធនាគារជាតិ នៃ កម្ពុជា ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការរៀបចំរបាយការណ៍នេះសមស្របទៅនឹងគំរោងដូចខាងក្រោម ៖

- **សេចក្តីផ្តើម**

  សេចក្តីផ្តើមនេះ ស្តីពីលំនាំបញ្ហា កម្មវត្ថុនៃការស្រាវជ្រាវ ទំហំនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ការប្រមូលទិន្នន័យ និងរចនាសម្ព័ន្ធការស្រាវជ្រាវ ។

- **ជំពូក១ រំលឹកទ្រឹស្តី**

  ជំពូកនេះ យើងខ្ញុំនឹងធ្វើការលើកឡើងនូវទ្រឹស្តីផ្សេងៗរបស់បណ្តាប្រទេសមួយចំនួន ដែលទាក់ទងនឹងប្រធានបទដែលយកមកសិក្សា ។

- **ជំពូក២ ស្ថានភាពទូទៅរបស់ធនាគារជាតិ នៃ កម្ពុជា**

  ក្នុងផ្នែកនេះ យើងបានលើកយកស្ថានភាពទូទៅដែលរួមមានមុខងារ និងភារកិច្ចរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងអគ្គនាយកដ្ឋានដែលពាក់ព័ន្ធ ។

- **ជំពូក៣ ការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុនៃធនាគារជាតិ នៃ កម្ពុជា**

  នៅក្នុងជំពូកនេះ យើងខ្ញុំធ្វើការសិក្សាលើគោលនយោបាយរូបិយវត្ថុ ឧបករណ៍គោលនយោបាយរូបិយវត្ថុក្នុងស្ថានការណ៍ជាក់ស្តែង ការវិវត្ត និងការអនុវត្តគោលនយោបាយក្រោយសង្គ្រាម មកដល់ពេលបច្ចុប្បន្ន និងការរំពឹកទុកនាពេលអនាគត ហើយនិងមូលហេតុនៃការបង្អាក់ក្នុងការអនុវត្តនយោបាយរូបិយវត្ថុ តាមរយៈនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ។

- **ការវិភាគទិន្នន័យ និងប្រសិទ្ធភាពនៃការអនុវត្តឧបករណ៍គោលនយោបាយរូបិយវត្ថុ របស់ធនាគារជាតិនៃកម្ពុជា**

  នៅក្នុងជំពូកនេះ បន្ទាប់ពីយើងបានចុះស្រាវជ្រាវ កម្មសិក្សារួចហើយ យើងបានបានធ្វើការវិភាគទិន្នន័យដែលបានមកពីការស្រាវជ្រាវទៅលើការអនុវត្ត នៃគោលនយោបាយរូបិយវត្ថុរបស់ ធនាគារជាតិនៃកម្ពុជា តើមានការអភិវឌ្ឍ ពីកម្រិតណាមកកម្រិតណា និងការប្រែប្រួលយ៉ាងដូចម្តេចខ្លះនៃឧបករណ៍គោលនយោបាយរូបិយវត្ថុ ?

- **សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

  ក្នុងផ្នែកនេះយើងខ្ញុំនឹងធ្វើការសរុបខ្លឹមសារនៅក្នុងរបាយការណ៍នេះ និងផ្តល់អនុសាសន៍នូវចំនុចខ្វះខាត ។

- **ឯកសារយោង**
- **ឧបសម្ព័ន្ធ**

# ជំពូកទី ១

# រំលឹកទ្រឹស្តី

# និង ស្ថានភាពទូទៅ

# ជំពូកទី១

# ស្ថានភាពទូទៅ

## ១.១. និយមន័យ

### ១.១.១. គោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុគឺជា ដំណើរការដែលអាជ្ញាធររូបិយវត្ថុនៃប្រទេសមួយដូចជា ធនាគារកណ្តាល ឬ ក្រុមប្រឹក្សាភិបាលរូបិយប័ណ្ណ ក្នុងការគ្រប់គ្រង ការផ្គត់ផ្គង់រូបិយវត្ថុ ក្នុងទិសដៅរក្សាអត្រាអតិផរណា ឬ អត្រាការប្រាក់ ដើម្បីធានាឱ្យបាននូវ ស្ថេរភាពថ្លៃ និងបង្កើនជំនឿទុកចិត្តលើរូបិយប័ណ្ណ។[1]

ទស្សនៈវិស័យនៃគោលនយោបាយរូបិយវត្ថុជាធម្មតាមានការរួមចំណែកដល់ សេដ្ឋកិច្ចគឺ កំណើនសេដ្ឋកិច្ច ស្ថិរភាព កាត់បន្ថយភាពគ្មានការងារធ្វើ និងដើម្បីរក្សាអត្រាប្តូរប្រាក់ជាមួយនឹងរូបិយប័ណ្ណផ្សេងទៀត ។ សេដ្ឋកិច្ចរូបិយវត្ថុ ផ្តល់នូវការយល់ដឹងទូលំទូលាយចូលទៅក្នុងគោលនយោបាយរូបិយវត្ថុល្អប្រសើរបំផុត ។ ចាប់តាំងពីឆ្នាំ1970 គោលនយោបាយរូបិយវត្ថុដែលបង្កើតឡើងជាទូទៅគឺ ដាច់ដោយឡែកពីគោលនយោបាយសារពើពន្ធដែលសំដៅទៅលើការបង់ពន្ធ ការចំណាយរបស់រដ្ឋាភិបាល និងប្រាក់កម្ចី ។ គោលលនយោបាយរូបិយវត្ថុមានពីគឺ គោលនយោបាយវិត្ថារកម្ម (Expansionary policy) ឬ គោលនយោបាយរឹតបន្តឹង (Contractionary policy)[2] ។

#### ១.១.១.១. គោលនយោបាយវិត្ថារកម្ម

គោលនយោបាយវិត្ថារកម្មគឺ ប្រើនៅពេលដែលអាជ្ញាធររូបិយវត្ថុប្រើឧបករណ៍នយោបាយរូបិយវត្ថុរបស់ខ្លួនដើម្បីជំរុញសេដ្ឋកិច្ច ហើយគោលនយោបាយនេះបង្កើនការផ្គត់ផ្គង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ច ច្រើនជាងពេលធម្មតា ។ វាត្រូវបានប្រើជាប្រពៃណីដើម្បីប្រយុទ្ធប្រឆាំងនឹងភាពអត់ការងារធ្វើ នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះដោយបន្ថយអត្រាការប្រាក់ ក្នុងការរំពឹងថានឹងបង្កើនការផ្តល់ឥណទាន ងាយស្រួលក្នុងការពង្រីកអាជីវកម្ម ។ ដូចគ្នានេះការបង្កើនតម្រូវការសរុប (តម្រូវការសរុបសម្រាប់ទំនិញ និងសេវាកម្ម) ទាំងអស់នៅក្នុងសេដ្ឋកិច្ចដែលជួយបង្កើនកំណើន

[1] Jahan, Sarwat: "Inflation Targeting: Holding the Line". International Monetary Funds, Finance & Development. Retrieved 28 December 2014.

[2] Monetary Policy: Federal Reserve Board. January 3, 2006.

សេដ្ឋកិច្ចដែលបានវាស់វែងដោយផលិតផលក្នុងស្រុកសរុប (Gross Domestic Product-GDP) ។ គោលនយោបាយនេះជាធម្មតាគឺ ធ្វើឲ្យថ្លៃនៃរូបិយប័ណ្ណ ធ្លាក់ចុះដោយបន្ថយអត្រាប្តូរប្រាក់ ។

#### ១.១.១.២.គោលនយោបាយរឹតបន្តឹង

ផ្ទុយពីគោលនយោបាយវិត្ថារកម្មគឺ គោលនយោបាយរឹតបន្តឹងគឺ ធ្វើឲ្យថយចុះអត្រាកំណើននៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ។ ការបន្ថយកំណើនសេដ្ឋកិច្ចនេះគឺ ដើម្បីទប់ស្កាត់ អតិផរណា ។ គោលនយោបាយរឹតបន្តឹង អាចនាំឱ្យមានការកើនឡើងភាពគ្មានការងារធ្វើ កម្ចី និងការចំណាយទៅលើអតិថិជន និងអាជីវកម្មដែលជាលទ្ធផលនៅក្នុងការធ្លាក់ចុះសេដ្ឋកិច្ច ។ វាគួរតែត្រូវបានគ្រប់គ្រង និងដឹកនាំថែរក្សាឲ្យបានល្អ ។

### ១.២. ឧបករណ៍រូបិយវត្ថុរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិច

ធនាគារកណ្តាលមានឥទ្ធិពលលើអត្រាការប្រាក់ដោយ វិត្ថារកម្ម (expanding) និងរឹតបន្តឹង (contracting) រូបិយវត្ថុដែលបានចរាចរ និងទុនបម្រុងលើប្រាក់បញ្ញើរបស់ធនាគារ នៅ ធនាគារកណ្តាល ។ ធនាគារកណ្តាលមានឧបករណ៍សំខាន់ៗចំនួនប្រាំពីរ នៃគោលនយោបាយរូបិយវត្ថុ៖

- ប្រតិបត្តិការទីផ្សារចំហរ (Open Market Operations)
- អប្បហារអត្រាការប្រាក់ (The Discount Rate)
- ប្រាក់បម្រុងកាតព្វកិច្ច (The Reserve Requirement)
- ការប្រាក់លើសមតុល្យប្រាក់បម្រុងកាតព្វកិច្ច និងសមតុល្យអតិរេក (Interest on Required Reserve Balances and Excess Balances)
- កិច្ចសន្យាទិញត្រលប់ (Overnight Reverse Repurchase Agreement Facility)
- ឥណទានមានកាលកំណត់ (Term Deposit Facility)
- និងឧបករណ៍គោលនយោបាយផុតកំណត់ (Expired Policy Tools)

#### ១.២.១ ប្រតិបត្តិការទីផ្សារចំហរ ( Open Market Operations )

ឧបករណ៍ដែលបានប្រើជាទូទៅច្រើនបំផុត ដែលធនាគារកណ្តាលអាចមានឥទ្ធិពលដល់មូលដ្ឋានរូបិយវត្ថុនោះគឺ ប្រតិបត្តិការទីផ្សារចំហរ ។ ការគ្រប់គ្រងបរិមាណនៃរូបិយវត្ថុដែលចរាចរគឺតាមរយៈការទិញ និងការលក់នៃឧបករណ៍ហិរញ្ញវត្ថុនានា ដូចជាប័ណ្ណរតនាគារ សញ្ញាប័ណ្ណរបស់ក្រុមហ៊ុន ឬ រូបិយប័ណ្ណបរទេសក្នុងការប្តូរសាច់ប្រាក់នៅលើប្រាក់បញ្ញើនៅធនាគារកណ្តាល។ ប្រាក់បញ្ញើទាំងនោះគឺ អាចបំលែងទៅជារូបិយប័ណ្ណ។ ដូច្នេះការទិញ ឬ លក់ឧបករណ៍ទាំងនេះជាលទ្ធផលក្នុងការបង្កើន ឬ បន្ថយរូបិយប័ណ្ណគោល ឬ បន្ថយការចរាចរទៅក្នុងទីផ្សារ។

ឧទាហរណ៍ ប្រសិនបើធនាគារកណ្តាលមានបំណងកាត់បន្ថយអត្រាការប្រាក់ (ប្រតិបត្តិការគោនយោបាយរិត្តារកម្ម) ទិញបំណុលរដ្ឋាភិបាលដោយបង្កើនចំនួនទឹកប្រាក់ចរាចរ ឬ គណនីប្រាក់បម្រុងរបស់ធនាគារ នោះធនាគារពាណិជ្ជមានប្រាក់បន្ថែមទៀតដើម្បីផ្តល់ប្រាក់កម្ចី ។ ដូច្នេះពួកគេបានកាត់បន្ថយអត្រាការប្រាក់លើកម្ចី ដែលធ្វើឱ្យប្រាក់កម្ចីដែលមានអត្រាទាប ។ អត្រាការប្រាក់លើ កាតព្វកិច្ចឥណទានទាបបង្កើនលទ្ធភាពក្នុងការចំណាយ ទៅលើអាជីវកម្មរបស់អតិថិជនបានខ្ពស់លើសពីនេះទៀត នៅពេលដែលឥណទានអាជីវកម្មមានការកើនឡើង ក្រុមហ៊ុនអាចបង្កើនតម្រូវការដល់អតិថិជនបានខ្ពស់។ ជាចុងក្រោយពួកគេអាចជួលកម្មករបានច្រើន ប្រាក់ចំណូលក៏កើនឡើងនោះធ្វើឲ្យ តម្រូវការនឹងមានការកើនឡើងផងដែរ ។ ឧបករណ៍នេះជាធម្មតាគឺគ្រប់គ្រាន់ដើម្បីជំរុញនូវតម្រូវការ និងជំរុញកំណើនសេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព ។ ជាធម្មតាគោលដៅរយៈពេលខ្លីនៃប្រតិបត្តិការទីផ្សារចំហគឺ ដើម្បីសម្រេចបាននូវគោលដៅអត្រាការប្រាក់រយៈពេលខ្លីជាក់លាក់មួយ ។ នៅក្នុងករណីផ្សេងទៀត គោលនយោបាយរូបិយវត្ថុអាចជំនួសឱ្យអត្រាប្តូរប្រាក់ជាក់លាក់មួយដែលទាក់ទងរូបិយប័ណ្ណបរទេសមួយចំនួន ឬ ផ្សេងទៀតដែលទាក់ទងទៅនឹងមាស ។ ឧទាហរណ៍នៅក្នុងករណីនេះ ធនាគារកណ្តាលសហរដ្ឋសហរដ្ឋអាមេរិចផ្តោតទៅលើ អត្រាការប្រាក់ជាអត្រាដែលសមាជិកធនាគារផ្តល់ប្រាក់កម្ចីដល់គ្នាទៅវិញទៅមកសម្រាប់រយៈពេលខ្លី ។[3]

**១.២.២. អប្បហារអត្រាការប្រាក់** (The Discount Rate)

អប្បហារនៃអាត្រាការប្រាក់គឺ ជាអត្រាការប្រាក់ដែលបានគិតពីធនាគារពាណិជ្ជ និងស្ថាប័នទទួលប្រាក់បញ្ញើរផ្សេងទៀតលើការផ្តល់ប្រាក់កម្ចី ដែលពួកគេទទួលបានប្រាក់កម្ចីពីធនាគារកណ្តាលនៅតាមតំបន់ ដែលហៅថា Discount rate ។ ធនាគារកណ្តាលផ្តល់ជូននូវកម្មវិធី Discount rate ចំនួនបី ទៅឱ្យស្ថាប័នទទួលប្រាក់បញ្ញើរមានដូចជា ឥណទានដំបូង ឥណទានបន្ទាប់ និង ឥណទានតាមរដូវកាល ។ ប្រាក់កម្ចីលើ Discount rate ត្រូវបានធានាសុវត្ថិភាពយ៉ាងពេញលេញ។ Discount rateសំដៅទៅលើឥណទានដែលគ្រឹះស្ថានហិរញ្ញវត្ថុខ្ចីប្រាក់ពីធនាគារកណ្តាលដែល កម្ចីទាំងនេះត្រូវបានកំណត់តម្លៃអប្បហារជាមួយប្រាក់កម្ចីមានសុវត្ថិភាព ដើម្បីកាត់បន្ថយសម្ពាធ (លំហូរហិរញ្ញវត្ថុ) នៅក្នុងទីផ្សារបម្រុង កាត់បន្ថយបញ្ហាសាច់ប្រាក់សម្រាប់ធនាគារ និងជួយក្នុងការធានានូវស្ថេរភាពមូលដ្ឋាននៃទីផ្សារហិរញ្ញវត្ថុ ។

[3]Dr. Paul M. Johnson: Open market operations: A Glossary of Political Economy Terms

#### ១.២.២.១. ឥណទានដំបូង

ប្រាក់កម្ចីត្រូវបានបង្កើតសម្រាប់រយៈពេលខ្លីជាធម្មតា សម្រាប់រយៈពេលមួយយប់ដល់ស្ថាប័នទទួលប្រាក់បញ្ញើរ លក្ខខណ្ឌហិរញ្ញវត្ថុដ៏រឹងមាំ (Financial and performance rating)។ ស្ថាប័នទទួលប្រាក់បញ្ញើរដែលមិនមានសិទ្ធិទទួលបាននូវឥណទានដំបូង អាចអនុវត្តសម្រាប់ឥណទានបន្ទាប់ ។ អត្រាអប្បហារដែលគិតទៅលើឥណទានដំបូង (អត្រាឥណទានដំបូង) ត្រូវបានកំណត់លើកម្រិតនៃអត្រាការប្រាក់ទីផ្សារសម្រាប់រយៈពេលខ្លី ។ ដោយសារតែឥណទានដំបូងគឺជាវិធីសាស្ត្រDiscount Window ចម្បងរបស់ធនាគារកណ្តាល ។ ដូចនេះធនាគារគណ្តាលបានប្រើជាអនុគមន៍ អត្រាអប្បហារមានន័យថាជា អត្រាឥណទានដំបូង ។

#### ១.២.២.២. ឥណទានបន្ទាប់

ឥណទានបន្ទាប់ត្រូវបានប្រើប្រាស់ដើម្បីបំពេញតម្រូវការសន្ទនីភាពរយៈពេលខ្លី ឬ ដើម្បីដោះស្រាយផលលំបាកផ្នែកហិរញ្ញវត្ថុដែលធ្ងន់ធ្ងរ ។ អត្រាអប្បហារលើឥណទានបន្ទាប់គឺ គិតដូចអត្រាអប្បហារលើឥណទានដំបូង ។

#### ១.២.២.៣. ឥណទានតាមរដូវកាល

ឥណទានតាមរដូវកាលត្រូវបានបង្កើនទំនាក់ទំនង ជាមួយស្ថាប័នទទួលប្រាក់បញ្ញើរតូចៗដែល ការពារការឡើងចុះលើតម្រូវការមូលនិធិ ។ អត្រាអប្បហារសម្រាប់ឥណទានតាមរដូវកាលគឺជា មធ្យមនៃអត្រាការប្រាក់ទីផ្សារដែលបានជ្រើសរើស ។ អត្រាអប្បហារដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារកណ្តាលនីមួយៗ ដែលមានតួនាទីដើម្បីពិនិត្យឡើងវិញនូវអភិបាលកិច្ចនៃប្រព័ន្ធធនាគារកណ្តាល ។

### ១.២.៣. ប្រាក់បម្រុងកាតព្វកិច្ច (Reserve Requirement)

ជម្រើសទីបីគឺ ផ្លាស់ប្តូរ ប្រាក់បម្រុងកាតព្វកិច្ច ។ ប្រាក់បម្រុងកាតព្វកិច្ចនេះសំដៅទៅលើសមាមាត្រនៃទ្រព្យសកម្មសរុបដែលធនាគារត្រូវតែរក្សាក្នុងដៃ ។ ធនាគាររក្សាត្រឹមតែ ផ្នែកតូចមួយនៃទ្រព្យសម្បត្តិរបស់ពួកគេជាសាច់ប្រាក់ ដែលអាចប្រើប្រាស់បានសម្រាប់ការដកជាបន្ទាន់ ហើយប្រាក់នៅសល់ត្រូវបានបណ្តាក់ទុននៅក្នុងទ្រព្យសម្បត្តិសន្ទនីភាព មានដូចជាការបញ្ចាំអចលនទ្រព្យ និងប្រាក់កម្ចី ។ នេះគឺជាគោលនយោបាយវិត្ថារកម្ម ដោយសារតែវាបង្កើតឥណទាន ។ បើទោះបីជាឧទាហរណ៍នេះបានត្រូវបង្កើតសាច់ប្រាក់ងាយស្រួលបានភ្លាមៗធនាគារកណ្តាលកម្រនឹងផ្លាស់ប្តូរទុកបម្រុងកាតព្វកិច្ចនេះដោយសារតែវា មានកម្រិតបរិមាណប្រែ

ប្រ្រួលច្រើន និងតម្រូវឱ្យមានគោលនយោបាយថ្មី នីតិវិធីថ្មី ដែលរំខានដល់សមាជិកធនាគារ ហើយការប្រើប្រាស់នៃប្រតិបត្តិការទីផ្សារចំហរត្រូវទទួលបានអាទិភាព ។

### ១.២.៤. ការប្រាក់លើសមតុល្យប្រាក់បម្រុងកាតព្វកិច្ច និងសមតុល្យអតិរេក

( Interest on Required Reserve Balances and Excess Balances )

ធនាគារកណ្តាលបង់ការប្រាក់លើសមតុល្យបម្រុងកាតព្វកិច្ច និងសមតុល្យអតិរេក ។ ក្រុមប្រឹក្សានាយកបានចេញបទបញ្ញត្តិគ្រប់គ្រងការទូទាត់ការប្រាក់ដោយធនាគារកណ្តាលក្នុងបទបញ្ញា D (តម្រូវការប្រាក់បម្រុងកាតព្វកិច្ចនៃស្ថាប័នបញ្ញើ) ។[4] ច្បាប់ស្តីពីការផ្តល់សេវានៃការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០០៦ បានអនុញ្ញាតឱ្យធនាគារកណ្តាលទូទាត់ការប្រាក់ទៅលើសមតុល្យដែលត្រូវបានកាន់កាប់ដោយ ឬ តំនាងអោយឲ្យស្ថាប័នរក្សាទុកនៅធនាគារកណ្តាលនៃប្រាក់បម្រុងដោយមានបទបញ្ញារបស់ក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃទី ១ ខែតុលា ឆ្នាំ ២០១១ ។

អត្រាការប្រាក់លើប្រាក់បម្រុងកាតព្វកិច្ច (អត្រា IORR) ត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាលហើយមានគោលបំណង ដើម្បីលុបបំបាត់ប្រសិទ្ធភាពនៃពន្ធមិនច្បាស់លាស់ដែលប្រាក់បម្រុងកាតព្វកិច្ចត្រូវបានប្រើដើម្បីដាក់លើគ្រឹះស្ថានបញ្ញើ (Depository Institution) ។ អត្រាការប្រាក់លើប្រាក់បម្រុងលើស (អត្រា IOER) ក៏ត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាលហើយផ្តល់ឱ្យធនាគារកណ្តាលនូវឧបករណ៍បន្ថែមសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ។ យោងតាមគោលនយោបាយ និងគោលនយោបាយធម្មតានៃគោលនយោបាយដែលបានអនុម័តដោយគណ:កម្មាធិការទីផ្សារបើកចំហរ (FOMC) ក្នុងអំឡុងពេលធម្មតានៃគោលនយោបាយរូបិយធនាគារ កណ្តាលនៃប្រាក់បម្រុងកាតព្វកិច្ច មានបំណងផ្លាស់ប្តូរអត្រាប្រាប់បម្រុងទៅតាមគោលដៅដែលកំណត់ដោយ គណ:កម្មាធិការទីផ្សារបើកចំហរ ដោយផ្លាស់ប្តូរទៅតាមអត្រា IOER ។ ដូចដែលបានបង្ហាញនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់គណ:កម្មាធិការទីផ្សារចំហរខែមីនាឆ្នាំ ២០១៥ នោះធនាគារកណ្តាលប្រាក់បម្រុងមានបំណងកំណត់អត្រា IOER ស្មើកំរិតអតិបរមានៃគោលដៅសម្រាប់អត្រាមូលនិធិធនាគារកណ្តាល ។ ចំពោះការកំណត់អត្រាបច្ចុប្បន្ននៃ IOER ត្រូវបានកំណត់ដោយគណ:កម្មាធិការទីផ្សារបើកចំហរ ។ ក្រុមប្រឹក្សាភិបាលនឹងបន្តវាយតម្លៃការកំណត់ អត្រាការប្រាក់អោយសមស្របទៅ លើសមតុល្យ នៃប្រាក់បម្រុងនៅក្នុងតម្លៃការ

[4] Federal Reserve.gov: monetarypolicy.

កំណត់ អត្រាការប្រាក់អោយសមស្របទៅ លើសមតុល្យ នៃប្រាក់បម្រុងនៅក្នុងលក្ខខណ្ឌនៃការផ្លាស់ប្តូរទីផ្សារសេដ្ឋកិច្ច។

**១.២.៥. កិច្ចសន្យាទិញត្រលប់** ( Overnight Reserve Repurchase Agreement Facility )

នៅក្នុងគោលការណ៍ធម្មតា និងផែនការនៃគោលនយោបាយ បានប្រកាសកាលនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៤ គណៈកម្មាធិការធនាគារកណ្តាលនៃទីផ្សារបើកចំហរ (FOMC) បានបង្ហាញថាគោលបំណងដើម្បីប្រើប្រាស់ឥណទានលើកិច្ចព្រមព្រៀងទិញត្រលប់ (ON RRP Facilities) ជាតម្រូវការ នៃការអនុវត្តឧបករណ៍គោលនយោបាយដើម្បីជួយការគ្រប់គ្រងមូលនិធិរបស់ធនាគារ កណ្តាល និងរក្សានៅកម្រិតគោលដៅដែលបានកំណត់ដោយ FOMC ។ គណៈកម្មាធិការនេះបានថ្លែងថានឹងប្រើ ON RRP facilities ទៅលើតែវិសាលភាពចាំបាច់ ហើយនឹងបន្ថយវាចេញនៅពេលដែលលែងត្រូវការជាចាំបាច់ក្នុងការ ជួយគ្រប់គ្រងអត្រាការប្រាក់ ។នៅពេលដែលធនាគារកណ្តាលណែនាំពីឥណទាន ON RRP ធនាគារកណ្តាលបានលក់នូវមូលបត្រដើម្បីផ្តល់សិទ្ធដល់ជាគូភាគី និងការព្រមព្រាងលើកិច្ចសន្យាដើម្បីទិញមូលបត្រត្រឡប់វិញនូវថ្ងៃបន្ទាប់ ។ ប្រតិបត្តិការនេះមិនប៉ះពាល់ដល់ទំហំនៃប្រព័ន្ធគណនីទីផ្សារចំហ (SOMA) លើសំពាធ (Portfolio) ឥណទាននោះទេ ។ ប៉ុន្តែបានកាត់បន្ថយ នៅក្នុងសមតុល្យទុនបម្រុង នៅលើផ្នែកបំណុលនៃតារាងតុល្យការរបស់ធនាគារកណ្តាល និងការឆ្លើយតបការកើនឡើងជាកាតព្វកិច្ចលើកិច្ចសន្យាទិញត្រឡប់ ខណៈពេលដែលពាណិជ្ជកម្មនេះកំពុងតែមានភាពរឹងមាំ ។FOMC បានកំណត់អត្រាលើឥណទាន ON RRP ដែលជាអត្រាការប្រាក់អតិបរមារបស់ ធនាគារកណ្តាលគឺមានឆន្ទៈ ក្នុងការបង់ប្រាក់នៅក្នុងប្រតិបត្តិការទិញត្រឡប់ (Repurchase Agreement) (ឧបសម្ព័ន្ធ ១) អត្រាការប្រាក់ពិតប្រាកដដែលត្រូវទទួលបានគឺកំណត់តាមរយៈដំណើរការដេញថ្លៃ ។

ធនាគារកណ្តាលបានធ្វើការប្រើប្រាស់បច្ចេកទេសក្នុងការចាប់ផ្តើម ប្រើប្រាស់ RRPs នៅខែ កញ្ញា ឆ្នាំ ២០១៣ ក្នុងគោលបំណងដើម្បីទទួលបាននូវបទពិសោធប្រតិបត្តិការ និងជម្រុញប្រតិបត្តិបែបនេះដែលអាចត្រូវបានប្រើកំឡុងពេលដំណើរការប្រក្រតី ។

**១.២.៦. ឥណទានមានកាលកំណត់** ( Term Deposit Facility)

ប្រាក់បញ្ញើមានកាលកំណត់ ជួយសម្រួលដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដោយការផ្តល់នូវឧបករណ៍បន្ថែមទៀត ដែលធនាគារកណ្តាលអាមេរិកអាចគ្រប់គ្រងបរិមាណសរុបនៃសមតុល្យទុនបម្រុងបង្កើតធ្វើឡើងដោយស្ថាប័នទទួលប្រាក់បញ្ញើ ។ មូលនិធិដែលបានដាក់ក្នុងប្រាក់បញ្ញើមានកាលកំណត់ ត្រូវបានដល់ចេញពីគណនីទុនបម្រុងនៃស្ថាប័នដែលចូលរួមសម្រាប់

កាលវសាន្តនៃប្រាក់បញ្ញើរមានកាលកំណត់និងដោយការបង្វិលសមតុល្យទុនបម្រុងពីប្រព័ន្ធធនាគារ ។ ធនាគារកណ្តាលបានផ្តល់នូវប្រាក់បញ្ញើរមានកាលកំណត់តាមរយៈឥណទានមានកាលកំណត់(TDF) និងស្ថាប័នទាំងអស់ដែលមានសិទ្ធិទទួលបានប្រាក់ចំណូល នៅលើសមតុល្យទុនបម្រុងធនាគាររបស់ខ្លួននឹងចូលរួមនៅក្នុងកម្មវិធីប្រាក់បញ្ញើរមានកាលកំណត់ ។ នៅក្នុងគោលយោបាយ (Normalization Principles and Plans) ដែលអនុម័តដោយគណៈកម្មាធិការទីផ្សារបើកចំហរ (FOMC) នៅខែថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ FOMC បានបង្ហាញថាក្នុងអំឡុងពេលដំណើរការនៃ គោលនយោបាយរូបិយវត្ថុ Normalization ធនាគារកណ្តាលមានបំណងប្រើឧបករណ៍បន្ថែមផ្សេងទៀតដូចជា TDF នេះ ជាការចាំបាច់ដើម្បីជួយគ្រប់គ្រងអត្រាទុនបម្រុង និងការផ្លាស់ប្តូរក្នុងគោលដៅដែលបានកំណត់ដោយ FOMC ។

**១.២.៧. ឧបករណ៍គោលនយោបាយផុតកំណត់** ( Expired Policy Tools )

ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ ធនាគារកណ្តាលបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដើម្បីផ្តល់នូវសន្ទនីភាពដោយផ្ទាល់ដល់អ្នកខ្ចី និងអ្នកវិនិយោគនៅក្នុងគន្លឹះនៃទីផ្សារឥណទាន ។ ធនាគារកណ្តាលបានបញ្ចប់ជាបណ្តោះអាសន្ននូវប្រតិបត្តិការរបស់ធនាគារមួយចំនួន ។ ក្រុមហ៊ុនទាំងនោះមានដូចជា៖

The Money Market Investor Funding Facility ផុតកំណត់នៅថ្ងៃទី ៣០ ខែតុលាឆ្នាំ ២០០៩ ក្រុមហ៊ុន ៖

- the Asset-Backed Commercial Paper Money Market Mutual Fund Liquidity Facility (ABCP MMMF)
- the Commercial Paper Funding Facility
- the Primary Dealer Credit Facility
- the Term Securities Lending Facility បិទនៅថ្ងៃទី ០១ ខែកុម្ភៈឆ្នាំ ២០១០ នេះផងដែល

ជាចុងក្រោយក្រុមហ៊ុន Term Auction Facility បានលក់ឡៃលុងត្រូវបានធ្វើឡើងនៅថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១០ និងក្រុមហ៊ុន the Term Asset-Backed Securities Loan Facility ត្រូវបានបិទ នៅថ្ងៃទី ៣០ មិថុនាឆ្នាំ ២០១០ ។

ដើម្បីផ្តល់ការគាំទ្របន្ថែមទៀតសម្រាប់ការសន្ទុះសេដ្ឋកិច្ច ធនាគារកណ្តាលអាមេរិកបានបង្កើតឡើងកម្មវិធីអូសបន្លាយកាលវសាន និងនយោបាយវិនិយោគឡើងវិញ ដែលបានតំនើរការចាប់ពីខែកញ្ញា ឆ្នាំ២០១១ រហូតដល់ចុងឆ្នាំ ២០១២ ។ ដែលមានក្រុមហ៊ុនជាច្រើនដូចជា៖

- Money Market Investor Funding Facility
- ABCP MMMF Liquidity Facility
- Commercial Paper Funding Facility
- Primary Dealer Credit Facility
- Term Securities Lending Facility
- Term Auction Facility
- Term Asset-Backed Securities Loan Facility
- Maturity Extension Program and Reinvestment Policy

## ១.៣. គោលនយោបាយផ្សេងៗទៀត

### ១.៣.១. គោលក្រោមសូន្យ

ទម្រង់ផ្សេងទៀតនៃគោលនយោបាយរូបិយវត្ថុត្រូវបានគេប្រើជាពិសេសនៅពេលអត្រាការប្រាក់ស្មើសូន្យភាគរយ ឬ ខិតជិតសូន្យភាគរយ និងមានបរិត្តផរណាកំពុងកើតមានឡើង ត្រូវបានគេស្គាល់ ថាជា **គោលនយោបាយរូបិយវត្ថុមិនមែនប្រពៃណី** (Unconventional Policy)[5] ។ ឧបករណ៍ទាំងនោះរួមមាន ៖

- ការបន្ថយឥណទាន (Credit Easing)
- ការបន្ថយបរិមាណ (Quantitative Easing)
- Forward Guidance

#### ១.៣.១.១. Credit Easing

នៅក្នុងការឆ្លើយតបរបស់ធនាគារកណ្ដាលទៅនឹងវិបត្តិហិរញ្ញវត្ថុ ២០០៨-២០០៩ ប្រធានធនាគារកណ្ដាល លោក Ben Bernanke[6] បានសម្គាល់កម្មវិធីថ្មីនេះដែលលោកបានហៅថា "ការបន្ធូរបន្ថយឥណទាន"ពីប្រទេសជប៉ុន។នៅក្នុងសុន្ទរកថារបស់លោកហើយលោកបានប្រកាសថា៖ វិធីសាស្ត្រដែលយើងស្គាល់ថាជាឧបករណ៍នយោបាយ ការបន្ធូរបន្ថយឥណទាន(Credit easing) គឺស្រដៀងទៅនឹងឧបករណ៍នយោបាយការបន្ធូរបន្ថយបរិមាណ (Quantitative Easing) គឺនៅក្នុងគោលដៅតែមួយ ។ វាជាប់ពាក់ព័ន្ធនឹងការពង្រីកនៃតារាងតុល្យការធនាគារកណ្ដាលមួយ។ ទោះ

---

[5] Roubini, Nouriel (January 14, 2016). "Troubled Global Economy". Time Magazine. time.com. Retrieved 5 February 2016.

[6] Ben Shalom Bernanke ជាអ្នកសេដ្ឋកិច្ចវិទូរបស់សហរដ្ឋអាមេរិក ដែលជាប្រធានមន្ត្រីផ្នែកទុកបម្រុងកាតព្វកិច្ចរបស់ធនាគារកណ្ដាលអាមេរិក ពីឆ្នាំ ២០០៦ ដល់ ២០១៤

ទោះជាយ៉ាងណានៅក្នុងរបបឧបករណ៍គោលនយោបាយការបន្ធូរបន្ថយបរិមាណ ផ្តោតសំខាន់ទៅលើបរិមាណនៃទុនបម្រុងរបស់ធនាគារដែលជាបំណុលដែលផ្តល់ដោយ ធនាគារកណ្តាលដែលជាសមាសភាពនៃប្រាក់កម្ចី និងទ្រព្យសកម្មមូលបត្រជាផ្នែកមួយនៃតារាងតុល្យការធនាគារកណ្តាល ។ ជាការពិតណាស់ទោះបីជាវិធីសាស្ត្រគោលនយោបាយរបស់ ធនាគារកណ្តាលជប៉ុនក្នុងអំឡុងពេលមួយបានបញ្ចប់ក៏ដោយ តែវាក៏ជាជំហររួមនៃគោលនយោបាយរបស់ខ្លួនត្រូវបានវាស់នៅក្នុងលក្ខខណ្ឌនៃគោលដៅ របស់ខ្លួនសម្រាប់ទុនបម្រុងធនាគារ ។

ផ្ទុយទៅវិញវិធីសាស្ត្រ នៃការបន្ធូរបន្ថយឥណទានរបស់ធនាគារកណ្តាលផ្តោតលើចង្ក្រាមឥណទាននិងមូលបត្រដែលរក្សាទុក និងធាតុនៃទ្រព្យសកម្មដែលប៉ះពាល់ដល់លក្ខខណ្ឌឥណទានសម្រាប់គ្រួសារ និងអាជីវកម្ម ។

ការបន្ធូរបន្ថយឥណទានពាក់ព័ន្ធនឹងការបង្កើនការផ្គត់ផ្គង់សាច់ប្រាក់ដោយការទិញ មិនមែនមូលបត្របំណុលរបស់រដ្ឋាភិបាល ប៉ុន្តែជាទ្រព្យសម្បត្តិវិស័យឯកជនដូចជា មូលបត្របំណុលសាជីវកម្មនិងមូលបត្រកម្ចីទិញផ្ទះត្រលប់ ។ នៅឆ្នាំ ២០១០ ធនាគារកណ្តាលបានទិញ ១.២៥ ពាន់ពាន់លានដុល្លារ នៃមូលបត្រកម្ចីទិញផ្ទះ ដើម្បីគាំទ្រដល់ទីផ្សារប្រាក់កម្ចីទិញផ្ទះដែលបានធ្លាក់ចុះ ។ ការទិញទាំងនេះបានបង្កើនមូលដ្ឋានរូបិយវត្ថុនៅក្នុងវិធីដែលស្រដៀងគ្នាទៅនឹងការទិញមូលបត្ររបស់រដ្ឋាភិបាល ។

**១.៣.១.២**. Quantitative Easing

ការកាត់បន្ថយបរិមាណ (Q.E) គឺជាគោលនយោបាយរូបិយវត្ថុ ដែលធនាគារកណ្តាលបង្កើតរូបិយប័ណ្ណអេឡិចត្រូនិចថ្មី នៅក្នុងគោលបំណងដើម្បីទិញ មូលបត្របំណុលរបស់រដ្ឋាភិបាល ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ដើម្បីជំរុញសេដ្ឋកិច្ច ពោលគឺដើម្បីបង្កើនការចំណាយរបស់វិស័យឯកជន និងត្រឡប់អតិផរណារបស់ខ្លួនឲ្យចំគោលដៅ។ គោលនយោបាយរូបិយវត្ថុមិនមែនពៃណី វាត្រូវបានប្រើជាធម្មតានៅពេលដែលគោលនយោបាយរូបិយវត្ថុបានក្លាយទៅជាស្តង់ដារនៅពេលដែលគ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះការផ្គត់ផ្គង់រូបិយវត្ថុ ។

ធនាគារកណ្តាលអនុវត្តគោនយោបាយបន្ថយបរិមាណដោយការទិញបរិមាណ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ពី ធនាគារពាណិជ្ជ និងស្ថាប័នហិរញ្ញវត្ថុផ្សេងធ្លាក់ចុះ ។ នោះជាការបង្កើនតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងការកាត់បន្ថយទិន្នផលទាំងនោះ ខណៈពេលដំណាលក្នុងគ្នាការបង្កើន ការផ្គត់ផ្គង់រូបិយវត្ថុ ។ ទាំងនេះខុសគ្នាពីគោលនយោបាយធម្មតាដោយការទិញ ឬ លក់មូលបត្របំណុលរបស់រដ្ឋាភិបាលរយៈពេលខ្លី ក្នុងការរក្សាអត្រាការប្រាក់អន្តរធនាគារ នៅតម្លៃគោលដៅមួយជាក់លាក់ ។

**១.៣.១.៣** Forward Guidance

គោលនយោបាយការណែនាំទៅមុខ គឺជាឧបករណ៍ដែលត្រូវបានប្រើដោយធនាគារកណ្តាលមួយដើម្បីអនុវត្តនូវអំណាចគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ក្នុងគោលបំណងដើម្បីមានឥទ្ធិពលលើ ការព្យាកររបស់ខ្លួនផ្ទាល់ និងកម្រិតការរំពឹងទុករបស់ទីផ្សារនាពេលអនាគតទៅលើអត្រាការប្រាក់ ។

អត្រាការប្រាក់ គឺជាចំនួនការប្រាក់ក្នុងកំឡុងពេលមួយ សមាមាត្រនៃចំនួនទឹកប្រាក់ដែលបានផ្តល់កម្ចី ប្រាក់បញ្ញើរ ឬ ប្រាក់កម្ចី ។ ការប្រាក់សរុបលើចំនួនទឹកប្រាក់ដែលបានផ្តល់ប្រាក់កម្ចី ឬការខ្ចីប្រាក់មួយអាស្រ័យលើគោលការណ៍ផលបូក ប្រេកង់សមាស និងរយៈពេលដែលវាត្រូវបានគេផ្តល់ប្រាក់កម្ចី ការដាក់ប្រាក់ ឬ ការខ្ចី ៕

# ជំពូកទី ២
# ស្ថានភាពទូទៅរបស់
# ធនាគារជាតិនៃកម្ពុជា

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ធនាគារជាតិ នៃ កម្ពុជា

## ២.១. ប្រវត្តិនៃការកកើតធនាគារជាតិ នៃ កម្ពុជា

### ២.១.១. ដំណាក់កាល ២០ឆ្នាំ មុនឆ្នាំ ១៩៩៧៥

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៩៥៥ បន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ គឺនៅពេលដែលប្រទេសទាំងបី កម្ពុជា វៀតណាម និងឡាវដណ្តើមបានឯករាជ្យរៀងៗខ្លួន ពីអាណានិគមបារាំង។ ក្នុងដំណាក់កាលដំបូងនោះ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយប្រាក់រៀល ឯករាជ្យមួយដើម្បីបញ្ចប់ជាស្ថាពរនៅសម្ព័ន្ធភាពជាមួយប្រាក់វៀតណាម និងឡាវ។ ចាប់តាំងពីការកកើតដំបូងរហូតដល់ឆ្នាំ ១៩៧០ ធនាគារជាតិនៃកម្ពុជាត្រូវបានបំរើយ៉ាងជិតស្និទ្ធដល់គោលនយោបាយកសាងជាតិនៃសង្គមរាស្ត្រនិយម ។ ក្នុងកំឡុងពេលនោះធនាគាជាតិមានការប្រែប្រួលជាសំខាន់នៅក្នុងឆ្នាំ ១៩៦៤ ។ ធនាគារជាតិនៃកម្ពុជាបានប្រែក្លាយជាពីស្ថាប័នពាក់កណ្តាលស្វាយ័តទៅជាធនាគាររបស់រដ្ឋ ក្រោមទម្រង់ស្ថាប័នសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ធនាគារឥណទានជាតិ ធនាគារអភិវឌ្ឍ ធនាគារកសិកម្មជនបទ ។ នាពេលនោះធនាគារឯកជនជាតិ និងបរទេសចំនួន ៩ ត្រូវបានបិទទ្វាដើម្បីបង្កើតឡើងជាធនាគារកសិកម្មជនបទ ។ ទន្ទឹមនឹងគ្នានេះដែលមន្ទីររាជសហាករណ៍ដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៥៦បានរៀបចំ និងគ្រប់គ្រងសហាករណ៍បី គឺ សហាករណ៍ផលិតកម្ម សហាករណ៍ឧបភោគបរិភោគ និងសហាករណ៍ឥណទាន ។

សហារកណ៍ឥណទានបានធ្វើសកម្មភាព យ៉ាងទូលំទូលាយទូទាំងប្រទេសក្រៅប្រព័ន្ធធនាគារដើម្បីគាំទ្រដល់ប្រជារាស្ត្រតូចតាច ។ សកម្មភាពឥណទាននេះជាសំខាន់គឺធ្វើឡើងមុនការបង្កើតឡើងនូវធនាគារកសិកម្មជនបទនាឆ្នាំ ១៩៧០ ។

ចាប់តាំងពីឆ្នាំ១៩៧០មកប្រព័ន្ធធនាគារបានធ្វើសេរីភាវូបនីយកម្មជាថ្មី ដើម្បីបង្កលក្ខណៈអោយធនាគារឯកជនធ្វើសកម្មភាពទន្ទឹមនឹងធនាគាររដ្ឋទាំងឡាយក្រោមការណែនាំ និងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

### ២.១.២. ដំណាក់កាល ២០ឆ្នាំ ក្រោយឆ្នាំ ១៩៧៩

បន្ទាប់ពីរបប ប៉ុល ពត ត្រូវផ្តួលរលំធនាគារជាតិនៃកម្ពុជាត្រូវបាន បង្កើតឡើងវិញនៅថ្ងៃទី ១០ ខែតុលា ឆ្នាំ១៩៧៩ ។ ក្នុងដំណាក់កាល ២០ឆ្នាំចុងក្រោយនេះគេអាចចែកប្រវត្តិស្ថាប័នរូបិយវត្ថុកម្ពុជាជាពីរដំណាក់កាលតូចៗ គឺដំណាក់កាលឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ និង ដំណាក់កាល

ក្រោយឆ្នាំ ១៩៨៣។

### ២.១.៣. ដំណាក់កាលពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៣

ក្នុងដំណាក់កាលនេះប្រវត្តិស្ថាប័ន រូបិយវត្ថុកម្ពុជាត្រូវបានកំនត់ត្រានូវវីរភាពដ៏ថ្លៃថ្លា និងការលះបង់ដ៏ខ្ពង់ខ្ពស់បំផុត និងការសំរេចដែលមានលទ្ធផលគួរជាទីមោទន: ។ ប្រការទាំងនេះបានសំដែងឡើងតាមរយ:ការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ការបោះផ្សាយឡើងវិញ និងរួមចំណែកស្តារជីវភាព សង្គ្រោះប្រជាជាតិអោយរួចផុតពីគ្រោះទុរភិក្សក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ។ ភាពដ៏អស្ចារ្យទាំងនោះគឺ ៖

**ទី១-** វីរជននៃរណសិរ្សសាមគ្គីសង្រោះជាតិកម្ពុជា ដែលដឹកនាំការរំដោះប្រទេសក្រៅពីការដឹកនាំប្រយុទ្ធលើសមរភូមិបានគ្រោងទុកនូវការបង្កើតធនាគារជាតិ និងបោះផ្សាយប្រាក់រៀលឡើងវិញសម្រាប់ជួយអោយ ជីវភាពសង្គមវិលមកប្រក្រតីភាពវិញយ៉ាងឆាប់រហ័ស ។

**ទី២-** ក្រោយថ្ងៃរំដោះភ្លាមៗរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាកំពុងមមាញឹកយ៉ាងខ្លាំងក្នុងភារកិច្ចបន្ទាន់បំផុត គឺបន្តវាយប្រយុទ្ធការពារជាតិផង និងរៀបចំការបោះទីតាំងជូនប្រជាជនដែលបែកខ្ញែកគ្រប់ច្រកល្ហក និងរៀបចំពង្រឹង និងការពាររដ្ឋអំណាចថ្មីផង និងដោះស្រាយគ្រោះទុរភិក្សដែលកំពុងរាតត្បាតពេញផ្ទៃប្រទេសផង ។ ស្ថិតក្នុងស្ថានភាពដ៏តឹងតែងបែបនោះរណសិរ្សសាមគ្គីសង្រោះជាតិកម្ពុជា និងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជានៅមានពេលគិតគូរបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជាក្នុងរយះពេលតែមួយ ១០ខែ ក្រោយថ្ងៃរំដោះប៉ុណ្ណោះ ។

**ទី៣-** ក្រុមរៀមច្បងធនាគារជាតិ នៃកម្ពុជាបានរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំ និងសកម្មភាព ប្រតិបត្តិការនៅស្នាក់កាលកណ្តាល ហើយពង្រីកបណ្តាញទៅតាមបណ្តាលខេត្ត-ក្រុងទាំង២០យ៉ាងឆាប់រហ័សបំផុត ។ ភាពដ៏អស្ចារ្យនេះស្ថិតនៅលើចំនុចដែលគួរអោយកត់សម្គាល់ទាំងឡាយគឺ: បង្កើតធនាគារមួយពីចំនុចសូន្យដោយបាតដៃទទេ ។ ទោះបីជាអគារធនាគារជាតិត្រូវបានគម្រេចអោយរលាយជាផេះផង់ ក៏ដោយក៏យើងបានបើកទីស្នាក់ការជាបណ្តោះអាសន្នលើអគារនៃអតីតអគារធនាគារខ្មែរ សម្រាប់ពាណិជ្ជកម្ម ដែលមានតែសំបកអគារ។ យើងគ្មានប្រភពហិរញ្ញវត្ថុ គ្មានសេសសល់នៅមរតកពីធនាគារពីមុនទាំងកសារ បទពិសោធន៍ និងធនធានមនុស្ស។ អ្នកចេះដឹងត្រូវបានកាប់សម្លាប់ ត្រូវបានបែកខ្ញែកទៅគ្រប់ទិសទី ខ្លះបាក់ស្មារតីគេចវេសមិនហ៊ានចូលបំរើការងារដោយខ្លាចការយ៉ាយីនៃរបប ប៉ុល ពតសារជាថ្មីទៀត ។ ក្នុងស្ថានភាពដែលរាងកាយស្គាំងស្គមបាក់កំលាំងសម្លៀកបំពាក់រយីករយ៉ៃ ស្មារតីភ្លេចភ្លាំង គ្រួសារបែកបាក់មិនទាន់ប្រមូលជួបជុំគ្នាផងតែយើងមូលចិត្តមូលថ្លើមធ្វើការ មិនស្គាល់យប់ មិនស្គាល់ថ្ងៃកាត់គ្រោះ

អសន្តិសុខគ្រប់ទីកន្លែងដើម្បីធ្វើការផង រៀនផងតាមរយៈជំនាញដែលផ្តល់មកតាមជំនួយដ៏ស្ហួចស្មើងនៃប្រទេស ជាមិត្តដើម្បីកសាងអោយបានធនាគារមួយដូចសព្វថ្ងៃ ។

**ទី៤-** ដោយមានការឧបត្ថម្ភពីប្រទេសជាមិត្ត ប្រាក់រៀលថ្មីបានបោះពុម្ពថ្មីក្នុងកាលៈទេសៈដ៏សែនប្រចុចញ៉ុច ប៉ុន្តែយើងអាចបោះផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៨០ គឺរយៈពេលត្រឹមតែ ៦ ខែប៉ុណ្ណោះក្រោយថ្ងៃបង្កើតធនាគារជាតិឡើងវិញ ។ ការបោះផ្សាយប្រាក់រៀលនេះត្រូវបានទទួលនូវការ អបអរសាទរ និងគាំទ្រយ៉ាងក្លៀវក្លាបំផុតពីសំណាក់ប្រជាជន និងមហាជន ។ ប្រាក់រៀលបានបម្រើការទូទាត់យ៉ាងឆាប់រហ័ស និងបង្កើតឡើងនូវសកម្មភាពធនាគារ និងប្រព័ន្ធថវិការរដ្ឋ ។

**ទី៥-** ក្នុងស្ថានភាពដែលយើងគ្មានប្រាក់កាសចាយវាយតាំងពីឆ្នាំ ១៩៧៩ ដល់ ១៩៨០ ក្រុមរៀបចំយើងមានភាពវៃឆ្លាតក្នុងការបោះផ្សាយប្រាក់រៀល តាមរយៈការប្តូរប្រាក់ដុង វៀតណាម ដែលកំពុងធ្វើចរាចរណ៍ក្នុងប្រទេសតាមរយៈការប្រើប្រាស់បៀវត្ស និងតាមរយៈឥណទាន ។

**ទី៦-** តាមរយៈគោលនយោបាយឥណទាន ចំពោះក្រុមសាមគ្គី និងសហគ្រាសរដ្ឋ ធនាគារជាតិ បានចូលរួមយ៉ាងមានប្រសិទ្ធភាពបំផុតក្នុងការស្តារជីវភាពរស់នៅឡើងវិញ ស្តារភាពបាក់កំលាំង និងសង្គ្រោះប្រជាជនទាំងមូលអោយរួចផុតពីគ្រោះទុរភិក្សក្រោយថ្ងៃរំដោះ ។ ឥណទានធនាគារបានជួយស្តារឡើងវិញនូវមុខរបរ នេសាទ កសិកម្ម សិប្បកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ជាពិសេសគឺប្រមូលទិញកសិផលដែលផ្តល់អោយ ផលិតកម្ម កសិកម្ម បានរីកចម្រើនយ៉ាងឆាប់រហ័ស ។

ក្នុងឆ្នាំ ១៩៨៩ យើងដំណើរការកែទម្រង់ប្រព័ន្ធធនាគារជាបន្តបន្ទាប់ ។ យើងបានផ្ទេរធនាគារខេត្តក្រុងទៅជាធនាគារឯកទេសខេត្ត-ក្រុង ដែលធ្វើសកម្មភាពតាមរបបស្វាយ័តភិបាលសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុ និងធ្វើសកម្មភាពនៅលើតំបន់ដែនដីរបស់ខ្លួន ។ ធនាគារជាតិនៃកម្ពុជាបានបំពេញតួនាទីបញ្ជាណែនាំ និងត្រួតពិនិត្យធនាគារឯកទេសទាំងនោះ ។ មុខងារជាបេឡាថវិការរដ្ឋក៏បានផ្ទេរទៅអោយក្រសួងហិរញ្ញវត្ថុតាំងពីចុងឆ្នាំ ១៩៩១ ។ ការវិនិយោគបរទេសលើវិស័យធនាគារក៏ចាប់ផ្តើមឡើងតាំងពីពាក់កណ្តាលឆ្នាំ១៩៩១។

សរុបសេចក្តីមកក្នុងដំណាក់កាល ឆ្នាំ ១៩៧៩-១៩៩៣ យើងអាចចាត់ទុកជាការកកើតឡើងប្រកបដោយវីរភាព និងការលះបង់យ៉ាងខ្ពស់ ហើយជួយគាំទ្រដល់រដ្ឋកម្ពុជាដោយមានស្ថានភាពរឹងមាំដើម្បីដំណើរចរចារសន្តិភាពបង្រួមបង្រួមជាតិ និងការកសាងព្រះរាជាណាចក្រកម្ពុជាទី២ឡើងវិញ ។

### ២.១.៤. ដំណាក់កាលក្រោយឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្ន

លទ្ធផលនៃការបោះពុម្ពទូទាំងប្រទេស លើកទី១នាឆ្នាំ ១៩៩៣ បាននាំមកនូវបរិយាកាសថ្មី ដល់ប្រជាជាតិទាំងមូល ក៏ដូចជាប្រព័ន្ធធនាគារដែរ ។ នោះគឺការបើក ទ្វារចំហរទៅកាន់ពិភពលោក ការឧបត្ថម្ភគាំទ្រយ៉ាងទូលំទូលាយពីសហគមន៍អន្តរជាតិ ការអនុវត្តរបបសេដ្ឋកិច្ចទីផ្សារ ការវិលមកកសាងសង្គមជាតិវិញនៃប្រជាជនខ្មែរគ្រប់ទិសទី និងគ្រប់ទិន្នាការនយោបាយ ក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការកសាងនីតិរដ្ឋ និងការគោរពសិទ្ធមនុស្ស។ ប្រព័ន្ធធនាគាររបស់កម្ពុជាក៏មានការប្រែប្រួលថាថ្មី ពោល គឺបើកទូលាយអាជីវកម្មលើវិស័យធនាគារដោយបង្កើតឡើងនូវធនាគារពាណិជ្ជទាំងឡាយក្រោមច្បាប់ក្នុងស្រុក ឬ ក្រោមទម្រង់ជាសាខាធនាគារបរទេស ។ ប្រការនេះតម្រូវអោយធនាគារជាតិកម្ពុជាត្រូវពង្រឹងតួនាទីជាធនាគារកណ្តាល បង្កើតសមត្ថភាពបញ្ជាណែនាំ និងត្រួតពិនិត្យបណ្តាធនាគារពាណិជ្ជដែលបច្ចុប្បន្ននេះមានចំនួន៣៩ធនាគារ ។ ច្បាប់ស្តីពីការកំណត់អោយធនាគារជាតិមានបេសកកម្មចំបង គឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សា ថ្លៃអោយមានស្ថេរភាព ។ លក្ខណៈជាប្រព័ន្ធធនាគារពីរថ្នាក់ក៏បានរៀបចំពង្រឹងជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះធនាគាជាតិបានធ្វើអោយបានសម្រេចជាមូលដ្ឋានក្នុងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចស្ថេរភាពតម្លៃប្រាក់រៀលស្ថេរភាពអត្រាប្តូរប្រាក់ និងការបង្កើនទុកបំរុងអន្តរជាតិក្នុងបណ្តាឆ្នាំកន្លងមក ។

## ២.២. អត្តសញ្ញាណរបស់ធនាគារជាតិ

ធនាគារជាតិនៃកម្ពុជាហៅថា " ធនាគារកណ្តាលគឺជាស្ថាប័នស្វ័យតសាធារណៈជា " ពាណិជ្ជកម្ម និងឧស្សាហកម្ម ។

### ២.២.១. រូបសញ្ញា

រូបសញ្ញាធនាគារជាតិនៃកម្ពុជារួមមាន រូបសញ្ញាស្រូវដែលចងភ្ជាប់បូ ហើយព័ទ្ធជុំវិញនិមិត្តសញ្ញារូបិយវត្ថុជាតិ គឺរៀល ។ (៛)

### ២.២.២. ផ្លាកសញ្ញា

រូបភាពខាងក្រោមនេះគឺផ្លាកសញ្ញារបស់ធនាគារជាតិនៃកម្ពុជា ។

### ២.២.៣. អត្ថន័យរូបសញ្ញា

- គួរស្រូវ បង្ហាញ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាគឺ ពឹងផ្អែកចំបងលើវិស័យកសិកម្ម ។
- បួចងគួរស្រូវបង្ហាញថាវិស័យកសិកម្មមានច្រើនយ៉ាង ទើបសរុបជារួមតាមរយៈការចងបួ ។
- (រ) តំណាងរូបិយវត្ថុជាតិខ្មែរ គឺរៀល ។ លុយរៀលនេះ មានប្រវត្តិកកើតឡើងនៅសម័យអាណានិគមបារាំង និមិត្តសញ្ញានេះត្រូវបានបង្កើតដោយជនជាតិបារាំង ។

## ២.៣. បេសកកម្ម

ធនាគារកណ្តាលមានបេសកកម្មចំបងគឺ កំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាស្ថេរភាពថ្លៃឲ្យមានស្ថេរភាពសំដៅលើការបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឲ្យសេដ្ឋកិច្ចរីកចំរើន ។

ធនាគារកណ្តាលមានសិទ្ធចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗទៀតដើម្បីបំពេញបេសកកម្មរបស់ខ្លួននិង ដើម្បីអនុវត្តន៍ខ្លឹមសារនៃច្បាប់នេះ ។

## ២.៤. មុខងារ និងភារកិច្ចទូទៅរបស់ធនាគារជាតិនៃកម្ពុជា

ធនាគារកណ្តាលមានុចងារនិងភារកិច្ច ដូចតទៅ ៖

- កំណត់គោលនយោបាយរូបិយវត្ថុដោយពីគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខណ្ឌនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា
- ត្រិះរិះរក អនុវត្ត និងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូប្រាក់ឲ្យសម្រេចគោលដៅដែលបានកំណត់
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី រួចចេញផ្សាយលទ្ធផល ហើយលើកសំណើរ និងវិធានការជូនរាជរដ្ឋាភិបាល
- ផ្តល់ និងដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឯទៀតដែលពាក់ព័ន្ធ ដូចជា ស្នងការគណនីគ្រឹះស្ថានជំរះជញ្ជីញជាដើម ព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ

- ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែសម្រួលប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ
- ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវ និងអនុវត្តន៍ក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានៃកិច្ចការទាំងឡាយដែល
- ជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័ណអន្តរជាតិសាធារណៈ
- ក្នុងកិច្ចការធនាគារឥណទានរូបិយវត្ថុ
- តម្លើងជញ្ជីងទូទាត់
- ចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណតេយ្យជាមួយប្រទេសក្រៅ
- ចូលរួមក្នុងការបង្កើតនិងត្រួតពិនិត្យទីផ្សាររូបិយវត្ថុ
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្ម ទីផ្សាប្តូប្រាក់ សង្ហារឹមប័ណ្ណ ត្បូងថ្ម និងលោហៈធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ញាត្តិ និងត្រួតពិនិត្យនិងគ្រឹះស្ថានទាំងនេះ
- និង កំណត់អាត្រាការប្រាក់ ។

## ២.៥. រចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់ធនាគារជាតិ នៃកម្ពុជា

### ២.៥.១. រចនាសម្ព័ន្ធ (ឧបសម្ព័ន្ធទី២)

ក្រុមប្រឹក្សាភិបាលជាគណៈគ្រប់គ្រង ដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា នៅធនាគារជាតិនៃកម្ពុជា និងមានសមាសភាពចំនួន ៧ រូបគឺ ទេសាភិបាល ទេសាភិបាលរង តំណាងប្រមុខរដ្ឋាភិបាល តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាង មជ្ឈដ្ឋានឧត្តមសិក្សា តំណាង មជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច និងតំណាង មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ។ ទេសាភិបាលជាប្រធានក្រុមប្រឹក្សាភិបាល និងមានតួនាទីជានាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជា ជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល (ឧបសម្ព័ន្ធទី៣) និងទទួលខុសត្រូវចំពោះកិច្ចការអនុវត្តគោលនយោបាយ និងប្រតិបត្តិការប្រចាំថ្ងៃ ។ ទេសាភិបាលត្រូវបានតែងតាំង ដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យដែលយោងតាមសំណើរបស់រាជរដ្ឋាភិបាល។ ក្នុងកម្រិតបច្ចេកទេសធនាគារជាតិនៃកម្ពុជាមានប្រាំអគ្គនាយកដ្ឋានគឺៈ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា និង អគ្គាធិការដ្ឋាន ដែលក្នុងនោះរួមមាន២១ នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋាន ។

នាយកដ្ឋាន និងអគ្គនាយកដ្ឋាន មានតួនាទី ទទួលខុសត្រូវចំពោះការអនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាលនិងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា ។

### ២.៥.១.១. អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋានៈ ជាសេនាធិការផ្ទាល់របស់ថ្នាក់ដឹកនាំ ដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់អោយ សម្រាប់វិស័យការងារដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលនឹងគ្រប់គ្រងផ្ទាល់នូវខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានគណនេយ្យ នាយកដ្ឋានគ្រប់គ្រងសាខា និងមជ្ឈមណ្ឌលសិក្សាបច្ចេកទេសធនាគារ។

### ២.៥.១.២. អគ្គនាយកដ្ឋានត្រួតពិនិត្យ

**ការគ្រប់គ្រង**

អគ្គនាយកដ្ឋានត្រួតពិនិត្យបានបែងចែកនាយកដ្ឋានក្រោមឱវាទជាបួន។ នាយកដ្ឋាននីមួយៗតែងមានការិយាល័យបួនទៀត ដែលដឹកនាំដោយប្រធានមួយរូប អមដោយ អនុប្រធានមួយរូប ឬ ច្រើនរូបជួយធ្វើការតាមការចាំបាច់។

**មុខងារនិងភារកិច្ច**

អគ្គនាយកដ្ឋានត្រួតពិនិត្យទើបតែត្រូវបានផ្លាស់ប្តូររចនាសម្ព័ន្ធនាពេលថ្មីៗនេះ ហើយមានមុខងារ និង ភារកិច្ចចម្បងៗគឺៈ

- ចូលរួមតាក់តែងច្បាប់ បទបញ្ញា សារាចរ និងចេញគំរូរបាយការណ៍ស្តង់ដានានាដែលពាក់ព័ន្ធដល់ការគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រុមហ៊ុនស្នងការគណនេយ្យឯករាជ្យ គ្រឹះស្ថានជម្រះបញ្ជីជាដើម
- ត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ ដោយប្រយោលទៅលើរបាយការណ៍ដែលបានទទួលប្រចាំគ្រា និងធ្វើអធិការកិច្ចដល់ទីកន្លែង
- ត្រួតពិនិត្យជាអចិន្ត្រៃយ៍នូវស្ថានភាពហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានចំណុះច្បាប់ បន្ទាប់ពីបានរកឃើញការពិតជាក់ស្តែងតាមរយៈការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង
- ដាក់ទណ្ឌកម្មខាងវិន័យចំពោះគ្រឹះស្ថានចំណុះច្បាប់ ដែលមិនបានអនុវត្តតាមច្បាប់ និង បទបញ្ញា
- ប្តឹងទៅតុលាការប្រសិនបើមានការរំលោភច្បាប់ និង បទបញ្ញាមានការប៉ះពាល់ដល់ផលប្រយោជន៍សារធារណៈ ។

ចំពោះរាល់ការចេញសេចក្តីសម្រេចត្រូវអនុវត្តអោយបានជាក់លាក់។ រាល់សេចក្តីសម្រេចត្រូវមានការចុះហត្ថលេខាដោយប្រធាន និង អនុប្រធាននាយកដ្ឋាន ឬ ដោយ អគ្គនាយកដ្ឋាន ឬ ទេសាភិបាលយោងទៅតាមសារៈសំខាន់នៃសេចក្តីសម្រេចនោះ។ ក្នុងករណីណាក៏ដោយ គ្រប់លិខិតស្នាមក្នុងការចេញអាជ្ញាប័ណ្ណ ឬ ដកហូតអាជ្ញាប័ណ្ណ គ្រប់បទបញ្ញាត្រួតពិនិត្យថ្មីៗ ឬ កែសម្រួលគ្រប់លិខិតជូនដំណឹងពីការដាក់ទណ្ឌកម្មខាងពិន័យគ្រប់លិខិតតែងតាំងអភិបាលបណ្តោះអាសន្ន ឬ អ្នកជម្រះបញ្ជីរត្រូវមានហត្ថលេខាដោយទេសាភិបាល ឬ ដោយ មន្ត្រីជាន់ខ្ពស់ដែលទេសាភិបាលបានចាត់តាំងជាពិសេសសម្រាប់គោលបំណងនេះ ។

**នាយកដ្ឋានក្រោមឪវាទ**

អគ្គនាយកដ្ឋានត្រួតពិនិត្យត្រូវបានរៀបចំអោយមាននាយកដ្ឋាន ៤៖

នាយកដ្ឋានត្រួតពិនិត្យឯកសារ

នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង

នាយកដ្ឋានផ្តល់អាជ្ញាប័ណ្ណ

១. ការិយាល័យអាជ្ញាប័ណ្ណ និង ជម្រះបញ្ជីរ

២. ការិយាល័យវិភាគ និង តាមដានម៉ាក្រូ

៣. ការិយាល័យត្រួតពិនិត្យការិយាល័យឥណទាន

៤. ការិយាល័យគ្រប់គ្រងទិន្នន័យ

នាយកដ្ឋាននីតិកម្ម

១. ការិយាល័យគតិយុត្តិ និង វិវាទ

២. ការិយាល័យបញ្ញត្តិកម្ម និង ស្រាវជ្រាវ

៣. ការិយាល័យបណ្តុះណ្តាល

៤. ការិយាល័យរដ្ឋបាល

**២.៥.១.៣. អគ្គាធិការដ្ឋាន**

អគ្គាធិការដ្ឋាន៖ ជាសេនាធិការត្រួតពិនិត្យសំខាន់របស់ដឹកនាំ ដោយបំពេញភារកិច្ចទូលំទូលាយខាងសវនកម្មផ្ទៃក្នុង លើអង្គភាពគ្រប់ថ្នាក់ដែលនៅក្រោមឪវាទផ្ទាល់របស់ធនាគារជាតិនៃកម្ពុជា ។ ពោលគឺគ្រប់គ្រងផ្ទាល់នូវនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានអធិការកិច្ច ។

**២.៥.១.៤. អគ្គលេខា**

អគ្គបេឡាៈ គឺជាសេនាធិការជំនាញរបស់ថ្នាក់ដឹកនាំដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់អោយ សម្រាប់វិស័យសកម្មភាពដែលទាក់ទងទៅនឹងរូបិយវត្ថុជាតិ និង កាន់កាប់រូបិយប័ណ្ណ ។ អគ្គបេឡាគ្រប់គ្រងផ្ទាល់នូវនាយកដ្ឋានបោះផ្សាយ និង នាយកដ្ឋានរោងពុម្ព ។

**២.៥.១.៥. អគ្គនាយដ្ឋានបច្ចេកទេស**

ជាសេនាធិការជំនាញរបស់ថ្នាក់ដឹកនាំដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់អោយសម្រាប់វិស័យសកម្មភាពដែលទាក់ទងនឹងអាជីវកម្មស្នូលនៃស្ថាប័ន។អគ្គនាយកដ្ឋាននេះគ្រប់គ្រងផ្ទាល់នូវនាយកដ្ឋានត្រួតពិនិត្យ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ។

អគ្គនាយកដ្ឋានបច្ចេកទេស គឺជាផ្នែកមួយនៃធនាគារជាតិនៃកម្ពុជាដែលមានបេសកម្មចម្បងគឺ អនុវត្តការត្រួតពិនិត្យឡើងវិញជាប្រចាំលើការប្រតិបត្តិ ឬ លទ្ធផលនៃការប្រតិបត្តិការរបស់នាយកដ្ឋានទាំងអស់។ ហើយអគ្គនាយកដ្ឋានបច្ចេកទេសធ្វើការវិភាគ សិក្សា សរុប និងទាញសេចក្តីសន្និដ្ឋានទៅលើលទ្ធផលនៃការត្រួតពិនិត្យឡើងវិញជាប្រចាំ និងលើកយោបល់ ផ្តល់ការកោតសរសើរ កែលម្អ ដាក់ពិន័យ ឬ វិធានការសមស្របផ្សេងៗទៅតាមការជាក់ស្តែង។

**ក. នាយដ្ឋានស្ថិតិ**

***លំហូការងារ***

ស្ថិតិជញ្ជីញទូទាត់ស្ថិតិជញ្ជីញទូទាត់ត្រូវបានចងក្រងឡើង ដោយប្រភពទិន្នន័យដែលទទួលបានពីក្រសួងស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារពាណិជ្ជ និង នាយកដ្ឋានពាក់ព័ន្ធនៃធនាគារជាតិនៃកម្ពុជា និងទិន្នន័យមួយចំនួនទៀត ។

***ប្រភពទិន្នន័យនិងស្ថិតិដែលត្រូវប្រមូល***

ធនាគារជាតិនៃកម្ពុជា

ទិន្នន័យតារាងតុល្យការរបស់ធនាគារពាណិជ្ជ និងគ្រិះស្ថានមីក្រូហិរញ្ញវត្ថុ

- តារាងស្ថិតិទុនបំរុងអន្តរជាតិ
- រាបាយការណ៍ប្រតិបត្តិការអន្តរជាតិ (IRTS)
- របាយការណ៍ស្តីពីចំណូលទទួលបានពីការវិនិយោគទុនបម្រុង
- លទ្ធផលការចុះសិក្សាស្វែងយល់តាមច្រកព្រំដែនប្រទេសកម្ពុជា

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ស្ថិតិនាំចេញនាំចូលតាមប្រភេទទំនិញ (ប្រចាំខែ ត្រីមាស និងឆ្នាំ)
- ស្ថិតិនាំចេញនាំចូលតាមរបបពន្ធគយ (ប្រចាំឆ្នាំ)

- ស្ថិតិពាណិជ្ជកម្មបែងចែកតាមប្រទេស (ត្រីមាស និងឆ្នាំ)
- ស្ថិតិចុះបញ្ជីវិនិយោគបរទេស
- ស្ថិតិបំណុលក្រៅប្រទេស
- ស្ថិតិផែនការចំនួយអភិវឌ្ឍផ្លូវការ (ODA)

ក្រសួងពាណិជ្ជកម្ម

- ស្ថិតិនាំចេញតាមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP)

ភ្នាក់ងារកម្ពុជានាវាចរ KAMSAB

- ស្ថិតិនាវាដឹកជញ្ជូនទំនិញនាំចេញ-នាំចូល

អជ្ញាធរអាកាសចរណ៍ស៊ីវិល

- ស្ថិតិនាវាដឹកជញ្ជូនផ្លូវអាកាស

ក្រសួងមហាផ្ទៃ

- ស្ថិតិសមាសភាពពលរដ្ឋខ្មែរចេញ-ចូលតាមច្រកទ្វារព្រំដែន
- ស្ថិតិសមាសភាពជនបរទេសចេញ-ចូលតាមច្រកទ្វារព្រំដែន

ក្រសួងទេសចរណ៍

- របាយការណ៍ស្ថិតិទេសចរណ៍

ធនាគារទូទាត់អន្តរជាតិ (BIS )

- តារាងប្រាក់បញ្ញើ និងកម្ចីនៅក្រៅប្រទេសរបស់វិស័យមិនមែនធនាគារ

ស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ

**ខ. ប្រភពទិន្នន័យដែលត្រូវប្រមូល**

ធនាគារជាតិនៃកម្ពុជា

តារាងតុល្យការស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត

- គណនី Nostro
- របាយការណ៍សាច់ប្រាក់ធនាគារជាតិនៃកម្ពុជា
- របាយការណ៍ Cash in Transit
- របាយការណ៍ស្តីពីការទិញ-លក់ដុល្លារអាមេរិក
- របាយការណ៍រូបិយប័ណ្ណបរទេស (Foreign Exchange Report)
- របាយការណ៍អាត្រាប្តូរប្រាក់ប្រចាំថ្ងៃ សប្តាហ៍ និងខែ

- របាយការណ៍ពីប្រពន្ធធនាគារស្នូល (BI Resport)
- របាយការណ៍អាត្រាប្តូប្រាក់

ធនាគារពាណិជ្ជ និងធនាគារឯកទេស

- របាយការណ៍សង្ខេបតារាងតុល្យការធនាគារ )Call Report on spread Sheet )
- របាយការណ៍អាត្រាការប្រាក់
- របាយការណ៍ Chart of Account (COA)

  (*របាយការណ៍ទាំងនេះមាននៅក្នុង Banking Supervision Report System )*

រតនាគារជាតិ

- ស្ថានភាពសាច់ប្រាក់រតនាគារជាតិ

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់
- ផលិតផលក្នុងស្រុក

វេបសាយ IMF

- ស្ថានភាពសាច់ប្រាក់ធនាគារជាតិនៃកម្ពុជា IMF (SDR allocation and holding )
- អាត្រាប្តូរប្រាក់ SDR និងដុល្លារអាមេរិច

**ខ. នាយដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ**

***ភារកិច្ចចម្បងៗរបស់ការិយាល័យនីមួយៗ***

ការិយាល័យគោលនយោបាយរូបិយវត្ថុទទួលបន្ទុក៖

- ជាលេខាធិការដ្ឋានសម្រាប់គណៈកម្មការគោននយោបាយរូបិយវត្ថុនៃធនាគារជាតិនៃកម្ពុជា
- រៀបចំផែនការសម្រាប់ដំណើរការគោលនយោបាយរូបិយវត្ថុ និង
- តាមដានស្ថានភាពសាច់ប្រាក់ងាយស្រួល និងប្រាក់បម្រុងកាតព្វកិច្ចរបស់វិស័យធនាគារដែលរួមមានមុខងារ និងភារកិច្ចតាមផ្នែកដូចតទៅ៖

  **ផ្នែកគោលនយោបាយរូបិយវត្ថុ**

  - សិក្សា វិភាគ និងរៀបចំរបាយការណ៍អតិផរណាប្រចាំគ្រា
  - បម្រើការងារផ្សេងៗទៀតជាលេខាធិការដ្ឋានសម្រាប់គណៈកម្មការគោលនយោបាយរូបិយវត្ថុ និង

- ជាតំណាងឲ្យធនាគារជាតិនៃកម្ពុជា ចូលរួមក្នុងកិច្ចប្រជុំផ្សេងៗជាមួយស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ និងរបបប្តូរប្រាក់នៅកម្ពុជា

**ផ្នែកតាមដាស្ថានភាពសាច់ប្រាក់ងាយស្រួលៈ**

- ប្រមូលព័ត៌មាន ទិន្នន័យដើម្បីតាមដាន និងវិភាគស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់ប្រព័ន្ធធនាគារ ស្ថានភាពប្រាក់បម្រុងកាតព្វកិច្ច និងចលនាអត្រាប្តូរប្រាក់
- ប៉ាន់ស្មាន និងព្យាករស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់ប្រព័ន្ធធនាគារប្រចាំគ្រា និង
- ផ្តល់ព័ត៌មាន និងមតិសម្រាប់ការរៀបចំគោលនយោបាយរូបិយវត្ថុ និងប្តូរប្រាក់

**ផ្នែកទីផ្សាររូបិយវត្ថុ - អន្តរធនាគារ ៖**

- ប្រមូលព័ត៌មាន ទិន្នន័យដើម្បីតាមដានដំណើរការទីផ្សាររូបិយវត្ថុ-អន្តរធនាគារ
- រៀបចំផែនការ និងអនុវត្តគោលនយោបាយរូបិយវត្ថុ និង
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធរៀបចំផែនការធ្វើការអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។

**ផ្នែកវិភាគម៉ាក្រូ-ហរិញ្ញវត្ថុៈ**

- ប្រមូលព័ត៌មាន ទិន្នន័យដើម្បីវិភាគ តាមដាន និងវាយតម្លៃស្ថានភាពម៉ាក្រូ-ហិរញ្ញវត្ថុ
- រៀបចំ និងតាមដានសូចនាករភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ និងអភិវឌ្ឍម៉ាក្រូស្រ្តេតេស្តន៍ និង
- រៀបចំគោលនយោបាយស្ថិរភាពម៉ាក្រូ-ហិរញ្ញវត្ថុ និងតាមដានការអនុវត្ត។

**ការិយាល័យស្រាវជ្រាវសេដ្ឋកិច្ចក្នុងស្រុក** ទទួលបន្ទុក:

- ប្រមូលទិន្នន័យសម្រាប់ តាមដាន វិភាគ និងព្យាករ ស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ ទីផ្សារ ទុន និងហិរញ្ញវត្ថុនៅកម្ពុជា
- សិក្សា ស្រាវជ្រាវ លើប្រធានបទ និងបញ្ហាពាក់ព័ន្ធសំខាន់ៗ និង

- រៀបចំឯកសារ របាយការណ៍ និងសុន្ទរកថាចាំបាច់នានាសម្រាប់កម្មវិធីផ្សេងៗនៅក្នុងប្រទេសដែលរួមមានមុខងារ-ភារកិច្ចតាមផ្នែកដូចតទៅៈ

**ផ្នែកវិភាគរូបិយវត្ថុៈ**

- តាមដាន និងវិភាគស្ថានភាពរូបិយវត្ថុ ការផ្គត់ផ្គង់រូបិយវត្ថុ និងសមាសធាតុ
- រៀបចំរបាយការណ៍ Flash Report ប្រចាំខែ និង
- តាមដាន ដំឡើង និងព្យាករអតិផរណារយៈកាលខ្លី
- ប្រមូលទិន្នន័យសម្រាប់ តាមដាន វិភាគ និងព្យាករ ស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ ទីផ្សារ

**ផ្នែកវិភាគសេដ្ឋកិច្ចទូទៅៈ**

- តាមដាន និងវិភាគស្ថានភាពសេដ្ឋកិច្ចទូទៅ ជាពិសេស វិស័យកសិកម្ម កាត់ដេរ អចលនទ្រព្យ
- តាមដាន និងវិភាគសូចនាករម៉ាក្រូសេដ្ឋកិច្ចប្រចាំត្រីមាស និងឆមាស
- រៀបចំឯកសារ បទអន្តរាគមន៍ និងសុន្ទរកថាចាំបាច់នានាជូនថ្នាក់ដឹកនាំសម្រាប់ចូលរួមក្នុងកម្មវិធីផ្សេងៗនៅក្នុងប្រទេស និង
- ដើរតួជាមន្ត្រីទំនាក់ទំនងចំពោះសហប្រតិបត្តិការក្នុងប្រទេស

**ផ្នែកស្រាវជ្រាវសេដ្ឋកិច្ច-ហិរញ្ញវត្ថុៈ**

- សិក្សា ស្រាវជ្រាវ អំពីស្ថានភាព និងការវិវត្តសេដ្ឋកិច្ច ស្ថានភាពវិស័យធនាគារ និងហិរញ្ញវត្ថុ ក្នុងប្រទេស និងក្រៅប្រទេសដែលអាចមានផលប៉ះពាល់ដល់ការអនុវត្តនយោបាយរូបិយវត្ថុ និង
- រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា។

**ផ្នែកព្យាករណ៍សេដ្ឋកិច្ចៈ**

- ដំឡើងម៉ូដែលសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ
- អភិវឌ្ឍម៉ូដែលម៉ាក្រូសេដ្ឋកិច្ច ដើម្បីព្យាករលើនិន្នាការ និងបម្រែបម្រួលសំខាន់នៃសេដ្ឋកិច្ច និង
- ដំឡើង និងតាមដានប្រព័ន្ធឲ្យសញ្ញាជាមុន (Early Warning System)

**ការិយាល័យសេដ្ឋកិច្ចអន្តរជាតិ** ទទួលបន្ទុកៈ

- តាមដាន និងវិភាគស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុរបស់បណ្តាប្រទេសអភិវឌ្ឍសំខាន់ៗរួមទាំងប្រទេសជាដៃគូរពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា
- តាមដានបម្រែបម្រួលគោលនយោបាយសេដ្ឋកិច្ចគោលនយោបាយរូបិយវត្ថុ គោលនយោបាយពាក់ព័ន្ធទីផ្សារហិរញ្ញវត្ថុសំខាន់ៗ រួមទាំងនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជានិង
- រៀបចំឯកសារ បទអន្តរាគមន៍ និងសុន្ទរកថាចំបាច់នានាសម្រាប់កម្មវិធីផ្សេងនៅក្រៅប្រទេសដែលរួមមានមុខងារ-ភារកិច្ចតាមផ្នែកដូចតទៅៈ

**ផ្នែកវិភាគទីផ្សាររូបិយប័ណ្ណ ឥណទាន និងទីផ្សារទុនអន្តរជាតិ**

- តាមដាន និងវិភាគស្ថានភាព និងនិន្នាការអត្រាប្តូរប្រាក់ អត្រាការប្រាក់ ចំពោះទីផ្សាររូបិយប័ណ្ណ ទីផ្សារឥណទាន និងទីផ្សារទុនសំខាន់ៗ រួមទាំងស្ថានភាពនៃប្រទេសជាដៃគូរពាណិជ្ជកម្មរបស់កម្ពុជា
- រៀបចំរបាយការណ៍ Flash Report ប្រចាំខែអំពីអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងទីផ្សារទុន និង
- សិក្សា និងវិភាគអំពីផលប៉ះពាល់នៃការវិវត្តន៍លើទីផ្សារទាំងនោះ

**ផ្នែកវិភាគវិភាគសេដ្ឋកិច្ចអាស៊ាន និងដៃគូពាណិជ្ជកម្មរបស់កម្ពុជាៈ**

- តាមដាន ស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុរបស់បណ្តាប្រទេសអាស៊ាន រួមទាំងប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា និងរៀបចំរបាយការណ៍ Flash Reportប្រចាំខែ និង
- សិក្សា និងវិភាគអំពីផលប៉ះពាល់នៃការវិវត្តសេដ្ឋកិច្ច-ហិរញ្ញវត្ថុអាស៊ាន និងដៃគូពាណិជ្ជកម្មសំខាន់ៗ ទៅលើ ការអនុវត្តនយោបាយរូបិយវត្ថុ និងវិស័យធនាគារ និងហិរញ្ញវត្ថុកម្ពុជា។

**ផ្នែកវិភាគទីសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ៈ**

- តាមដាន ស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុរបស់បណ្តាប្រទេសអភិវឌ្ឍន៍ និងរៀបចំរបាយការណ៍ Flash Report ប្រចាំខែ និង
- សិក្សា និងវិភាគអំពីផលប៉ះពាល់នៃការវិវត្តសេដ្ឋកិច្ច-ហិរញ្ញវត្ថុ បណ្តាប្រទេសទាំងនោះទៅលើការអនុវត្តនយោបាយរូបិយវត្ថុ និងវិស័យធនាគារនិងហិរញ្ញវត្ថុកម្ពុជា

**ការិយាល័យសហប្រតិបត្តិការអន្តរជាតិ** ទទួលបន្ទុក ៖

- ទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ មានជាអាទិ៍ មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារសម្រាប់ការទូរទាត់អន្តរជាតិ និងធនាគារពិភពលោក
- ទំនាក់ទំនងសហប្រតិបត្តិការជាមួយអាស៊ាន អាស៊ាន+ដៃគូ ស៊ាសិន និងទំនាក់ទំនងទ្វេរភាគី និង
- សហការជាមួយស្ថាប័នខាងលើក្នុងការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា ក្នុង និងក្រៅប្រទេសដែលរួមមានមុខងារ-ភារកិច្ចតាមផ្នែកដូចតទៅ៖

**ផ្នែកសហប្រតិបត្តិការគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ៖**

  - ទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារសម្រាប់ការទូទាត់អន្តរជាតិ និងធនាគារពិភពលោក
  - សហការជាមួយស្ថាប័នខាងលើក្នុងការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា ក្នុងនិងក្រៅប្រទេស និង
  - រៀបចំឯកសារ បទអន្តរាគមន៍ និងសុន្ទរកថាចំបាច់នានាជូនថ្នាក់ដឹកនាំ សម្រាប់ការចូលរួមក្នុងកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ

**ផ្នែកសហប្រតិបត្តិការជាមួយអាស៊ាន និងដៃគូអាស៊ា៖**

  - ទំនាក់ទំនងសហប្រតិបត្តិការជាមួយ អាស៊ាន និងដៃគូរអាស៊ាន
  - សហការជាមួយស្ថាប័នខាងលើក្នុងរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា ក្នុង និងក្រៅប្រទេស
  - រៀបចំឯកសារបទអន្តរាគមន៍ និងសុន្ទរកថាចំបាច់នានាជូនថ្នាក់ដឹកនាំក្នុងចូលរួមក្នុងកម្មវិធីផ្សេងៗពាក់ព័ន្ធ នឹងអាស៊ាន និងដៃគូអាស៊ាន និង
  - សិក្សា ស្រាវជ្រាវ ដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មវិស័យធនាគារ និង ហិរញ្ញវត្ថុក្នុងតំបន់

**ផ្នែកសហប្រតិបត្តិការអាស៊ាន និងស្ថាប័នពហុភាគីមិនមែនហិរញ្ញវត្ថុ៖**

  - សហការជាមួយស្ថាប័នខាងលើក្នុងការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា ក្នុងនិងក្រៅប្រទេស

  - រៀបចំឯកសារ បទអន្តរាគមន៍ និងសុន្ទរកថាចំបាច់នានាជូន ថ្នាក់ដឹកនាំ សម្រាប់ការចូលរួមក្នុងកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងអាស៊ាន និងស្ថាប័នពហុភាគី មិនមែនហិរញ្ញវត្ថុ និង
  - សិក្សា ស្រាវជ្រាវ ដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មវិស័យធនាគារនិង ហិរញ្ញវត្ថុ ក្នុងតំបន់

**ផ្នែកសហប្រតិបត្តិការទ្វេរភាគី៖**

  - ទំនាក់ទំនងដើម្បីសហប្រតិបត្តិការទ្វេរភាគី៖
  - សហការជាមួយស្ថាប័នខាងលើក្នុងរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា ក្នុង និងក្រៅប្រទេស
  - រៀបចំឯកសារ បទអន្តរាគមន៍ និងសុន្ទរកថាចំបាច់នានាជូនថ្នាក់ដឹកនាំ សម្រាប់ចូលរួមក្នុងកម្មវិធីផ្សេងៗពាក់ព័ន្ធ នឹងសហប្រតិតបត្តិការទ្វេភាគី និង
  - សិក្សា ស្រាវជ្រាវដើម្បីគាំទ្រដល់ការពង្រឹង និងពង្រីកសហប្រតិបត្តិការទ្វេភាគី

**ការិយាល័យផ្សព្វផ្សាយ និងរដ្ឋបាល៖**

- រៀបចំតុបតែង បោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាស របាយការណ៍ប្រ ចាំគ្រា និងប្រចាំឆ្នាំ
- រៀបចំ បែងចែក ទុកដាក់ព័ត៌មាន និងរក្សាឯកសារ ឬរបាយការណ៍ផ្ទៃក្នុង និងពី ក្រៅ និង
- ចាត់ចែងការផ្គត់ផ្គង់សម្ភារៈសម្រាប់ដំណើរការរបស់នាយកដ្ឋាន និងផ្តល់ការ សម្របសម្រួលនានាដែលមានមុខងារ-ភារៈកិច្ចតាមផ្នែកដូចតទៅ៖

**ផ្នែកព្រឹត្តិបត្រ៖**

  - ប្រមូលព័ត៌មាន ទិន្នន័យសម្រាប់ព្រឹត្តិបត្តិប្រចាំត្រីមាស
  - ពិភាក្សា ទំនាក់ទំនងជាមួយនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធដើម្បីរៀបចំ ព្រឹត្តិបត្តិ និង
  - សិក្សា វិភាគព័ត៌មាន និងទិន្នន័យ និងរៀបចំព្រឹត្តិបត្តិប្រចាំត្រីមាស

**ផ្នែកប្រមូលផ្តុំ រក្សាទិន្នន័យ និងឯកសារ៖**

  - ប្រមូលផ្តុំ និងរក្សាប្រព័ន្ធទិន្នន័យ ព័ត៌មាន របាយការណ៍ អត្ថបទស្រាវជ្រាវ ក្នុង និងក្រៅប្រទេសដែលចំបាច់សម្រាប់ការងារផ្ទាល់របស់នាយកដ្ឋាន និង

- តុបតែង និងបោះពុម្ពអត្ថបទ ឯកសារ របាយការណ៍នានារបស់នាយកដ្ឋាន

**ផ្នែករដ្ឋបាលៈ**

- បែងចែក ផ្សព្វផ្សាយ អត្ថបទ ឯកសារ របាយការណ៍នានារបស់នាយកដ្ឋាន
- ផ្តល់ការសម្របសម្រួលជាមួយនាយកដ្ឋាន ទាំងឡាយ និងរៀបចំ និងចាត់ចែង ការផ្គត់ផ្គង់សម្ភារៈ និង ឧបករណ៍ចំបាច់ទាំងឡាយសម្រាប់ដំណើរការរបស់នាយកដ្ឋាន៕

# ជំពូកទី ៣
# ការអភិវឌ្ឍគោល
# នយោបាយរូបិយវត្ថុនៅ
# កម្ពុជា

# ជំពូកទី ៣
# ការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុនៅកម្ពុជា

## ៣.១. ស្ថានភាពដុល្លារូបនីយកម្ម និងទិដ្ឋភាពទូទៅនៃប្រាក់រៀលនៅកម្ពុជា

### ៣.១.១. បទពិសោធន៍ការធ្វើដុល្លារូបនីយកម្ម

ក្នុងរយៈពេល ៣ ទសវត្សរ៍ចុងក្រោយនេះ ប្រទេសដែលប្រឈមនឹងដុល្លារូបនីយកម្មបានប្រើប្រាស់គោលនយោបាយនានាទាំងវិធានការផ្អែកលើយន្តការទីផ្សារ និងវិធានការរដ្ឋបាល ដើម្បីកាត់បន្ថយកម្រិតដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ច។បទពិសោធន៍ក្នុងការអនុវត្តគោលនយោបាយទាំងនេះបានបង្ហាយថាការធ្វើបដិដុល្លារូបនីយកម្មប្រកបដោយជោគជ័យ អាស្រ័យទៅលើការមានផែនការច្បាស់លាស់ និងការចូលរួមសហការអនុវត្តពីសំណាក់គាគីពាក់ព័ន្ធទាំងអស់។ ការរៀបចំផែនការនេះត្រូវផ្តោតលើ៖

១. គោលនយោបាយថ្នាក់ម៉ាក្រូ ដែលសំដៅរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើសេដ្ឋកិច្ចជាតិប្រព័ន្ធហិរញ្ញវត្ថុ និងរូបិយវត្ថុ

២. គោលនយោបាយថ្នាក់មីក្រូជាក់លាក់នានាដែលធ្វើឲ្យរូបិយវត្ថុក្នុងស្រុកមានភាពទាក់ទាញជាងរូបិយប័ណ្ណ

លើសពីនេះការរួមបញ្ចូលរវាគោលនយោបាយម៉ាក្រូ និងមីក្រូត្រូវអនុវត្តទន្ទឹមពេលនឹងការលើកទឹកចិត្តដល់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់អោយចូលរួមក្នុងដំណើរការអនុវត្តដោយស្ម័គ្រចិត្ត និងផ្អែកលើយន្តការទីផ្សារ។

ជាក់ស្តែងបទពិសោធន៍ជោគជ័យក្នុងការធ្វើបដិដុល្លារូបនីយកម្ម ជាពិសេសនៅតំបន់អាមេរិកឡានទីន បានបង្ហាញឲ្យឃើញថាការថយចុះជាលំដាប់នៃកម្រិតដុល្លារូបនីយកម្មនៅក្នុងទស្សវត្សចុងក្រោយនេះ គឺដោយសារការអនុវត្តន៍គោលនយោបាយរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចជាការរក្សាស្ថិរភាពថ្លៃ អាត្រាប្តូរប្រាក់ ភាពរឹងមាំនៃស្ថានភាពថវិការបស់រដ្ឋ និងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ ទន្ទឹមនេះ វិធានការមីក្រូដែលសមស្របក៏បានដាក់ឲ្យអនុវត្តដើម្បីធ្វើឲ្យរូបិយវត្ថុក្នុងស្រុកកាន់តែមានភាពទាក់ទាញ រួមមាន៖ ការការពារអំណាចទិញនៃរូបិយវត្ថុក្នុងស្រុក វិធានការប្រុងប្រយ័ត្នសម្រាប់គ្រឹះស្ថានធនាគារ ការពង្រឹងវិស័យសារពើពន្ធ និងការអភិវឌ្ឍន៍ទីផ្សារទុនក្នុងស្រុក។ នៅក្នុងប្រទេស អ៊ីស្រាអ៊ែល អេសហ្ស៊ីប និង ប្រទេសមួយចំនួននៃតំបន់អឺរ៉ុប

កណ្តាល មានភាពជោគជ័យនៃការធ្វើបដិដុល្លារូបនីយកម្មបានបង្ហាញពីការអនុវត្តវិធាន ការប្រហាក់ប្រហែលគ្នាផងដែរ ។

នៅក្នុងករណីមួយចំនួន វិធានការរដ្ឋបាលអាចត្រូវបានអនុវត្ត ប៉ុន្តែត្រូវបានធ្វើឡើងស្របនឹងផែនការគោលនយោបាយរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនិងពឹងផ្អែកលើទីផ្សារ ដើម្បីកាត់បន្ថយកម្រិតដុល្លារូបនីយកម្ម និងបន្តលើកទឹកចិត្តចំពោះការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។ វិធានការរដ្ឋបាលដែលត្រូវបានប្រើ រួមមាន៖ ការតម្រូវឲ្យកំណត់ថ្លៃទំនិញសេវារូបិយវត្ថុក្នុងស្រុក ការគ្រប់គ្រងអត្រាការប្រាក់លើប្រាក់បញ្ញើរូបិយប័ណ្ណ ការគ្រប់គ្រងមូលធន និងបទប្បញ្ញត្តិដែលមានលក្ខណៈមិនគាំទ្រដល់ការប្រើប្រាស់រូបិយប័ណ្ណ ដូចជា ការដាក់កម្រិតលើការខ្ចី ឬ ការឲ្យខ្ចីជារូបិយប័ណ្ណ ការមិនអនុញ្ញាតឲ្យមានការធានាលើប្រាក់រូបិយប័ណ្ណនៅក្នុងកម្មវិធីធានារ៉ាប់រងប្រាក់បញ្ញើជាដើម ។

ទោះជាយ៉ាងណាក៏ដោយវិធានការរដ្ឋបាលមួយចំនួន អាចធ្វើឲ្យសាធារណៈជនបាត់បង់ទំនុកចិត្តជាពិសេសនៅពេលដែលមិនអនុវត្តស្របតាមគោលនយោបាយដ៏ទៃទៀត ដូចជាការបង្ខំឲ្យប្តូរប្រាក់បញ្ញើរពីរូបិយប័ណ្ណ មកជារូបិយប័ណ្ណក្នុងស្រុក ឬ ការមិនអនុញ្ញាតអោយទទួលយកប្រាក់បញ្ញើរជារូបិយប័ណ្ណនៅក្នុងប្រព័ន្ធធនាគារជាដើម ។

### ៣.២.១. ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា

ដុល្លារូបនីយកម្មបានចាប់ផ្តើមកើតឡើងនៅក្នុងវិស័យសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មក ។ បញ្ហាដុល្លារូបនីយកម្មនេះមិនបានកើតឡើងដោយសារជម្រើសគោលនយោបាយរបស់រដ្ឋាភិបាលទេ ប៉ុន្តែដោយសារយ៉ាងហោចណាស់កត្តាពីរចម្បងគឺ៖

១. បាត់បង់ជំនឿទុកចិត្តទៅលើរូបិយវត្ថុជាតិ

២. លំហូរចូលនៃរូបិយប័ណ្ណក្នុងសេដ្ឋកិច្ចជាបន្តបន្ទាប់

សង្គ្រាមស៊ីវិលដែលអូសបន្លាយអស់រយៈពេលប្រមាណ៣០ឆ្នាំ (ដើមទសវត្សរ៍ ១៩៧០ ចុងទសវត្សរ៍ ១៩៩០) បានធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ចមកលើការរក្សាទុក និងប្រើប្រាស់រូបិយវត្ថុជាតិ ជាពិសេសសម័យ ប៉ុល ពត ដែលលុបបំបាត់ការប្រើប្រាស់រូបិយវត្ថុ ទីផ្សារ នឹងរាល់សកម្មភាពសេដ្ឋកិច្ចទាំងអស់ ។ បទពិសោធន៍នៃការលុបបំបាត់រូបិយវត្ថុជាតិ នឹងការប្រើប្រាស់វត្ថុមានតម្លៃផ្សេងៗ (ដូចជា មាស ប្រាក់ អង្ករ ជាដើម) ដើម្បីរក្សាទ្រព្យសម្បត្តិ នឹងការដោះដូរក្នុងរយៈពេលអស្ថិរភាពនាសម័យសង្គ្រាម បានដក់ជាប់នៅក្នុងផ្នត់គំនិតប្រជាជនយ៉ាងជ្រៅ ហើយបានដាក់កំហិតលើការប្រើប្រាស់រូបិយវត្ថុជាតិ ទោះបីជាសុខ

ភាពសន្តិភាពនៃស្ថិរភាពនយោបាយ នឹងស្ថេរភាពសេដ្ឋកិច្ចហិរញ្ញវត្ថុ ត្រូវរក្សា អស់រយះពេលប្រមាណ ២ ទសវត្សរ៍ចុងក្រោយនេះក៏ដោយ ។

### ៣.១.៣. ស្ថានភាព នឹងការបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល

#### ៣.១.៣.១. ប្រវត្តិរូបិយវត្ថុកម្ពុជា

ក្រោយអាណានិគមបារាំង (១៨៦៨-១៩៥៣) មធ្យោបាយទូទាត់ទំនិញ នឹងសេវាប្រជាជនគឺប្រើដុំមាស ដុំប្រាក់ (ប្រាក់ដួង-ប្រាក់ស្លឹក) ។ រហូតក្រោយមកទើបឃើញមានប្រើប្រាស់ក្រដាស់ប្រាក់ នឹងកាក់ដែលរូបិយវត្ថុនេះ គេអោយឈ្មោះថា Piastre ។ Piastre នេះត្រូវបានប្រើប្រាស់ក្នុងប្រទេសគឺ វៀតណាម នឹងឡាវ ។

ក្រោយថ្ងៃឯករាជ្យ ០៩ វិច្ឆិកា ឆ្នាំ ១៩៥៣ ធនាគារជាតិក៏ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំង ១៩៥៤ ក្រោយព្រះរាជក្រមលេខ ៩២២ ន.ស ហើយប្រាក់រៀលក៏ត្រូវបានចាប់បដិសន្ធិឡើងដោយចរាចរលើទីផ្សារជំនួសលុយ Piastre វិញ (១រៀល=១ Piastre) ។ រហូតល់បំណាចឆ្នាំ១៩៦៥ គេក៏លែងឃើញមានលុយ Piastre នេះចរាចរលើទៅផ្សារកម្ពុជាទៀត ។ ទំនាក់ទំនងនៃការប្តូរប្រាក់ពីរូបិយវត្ថុជាតិ ទៅជារូបិយប័ណ្ណបរទេសត្រូវបានឆ្លងកាត់ ONC (Office National de Change) ។

#### ៣.១.៣.២. ស្ថានភាព និងការប្រែប្រួលតម្លៃនៃប្រាក់រៀល

បច្ចុប្បន្នតម្លៃទំនិញ នឹងសេវាមានការប្រែប្រួលកើនឡើងគួរអោយគត់សម្គាល់ ។ ជាមួយគ្នានោះដែរ តម្លៃនៃប្រាក់រៀលក៏មានការប្រែប្រួលចុះឡើងទៅតាមរបត់នៃសេដ្ឋកិច្ច មានដូចជាបម្រែបម្រួលនៃតម្រូវការ នឹងការផ្គត់ផ្គង់ វិបត្តិសេដ្ឋកិច្ច អតិផរណា ការប្រែប្រួលនៃអត្រាការប្រាក់ និងអត្រាការប្រាក់ជាដើម ។

ប្រវត្តិនៃការបង្កើតរូបិយវត្ថុជាតិមានរយៈពេលខ្លីបើធៀប នឹងប្រទេសនានានៅក្នុងពិភពលោក នឹងតំបន់ ។ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ១៩៥៤ ហើយរូបិយវត្ថុជាតិប្រាក់រៀល ក៏ត្រូវបបានបង្កើតឡើងផងដែរ ។ ប្រជាជនកម្ពុជាបានទទួលស្គាល់យ៉ាងទូលំទូលាយលើប្រាក់រៀល ក្រោយពីដាក់ឲ្យចរាចរ ប៉ុន្តែទំនុកចិត្តលើប្រាក់រៀលត្រូវបានបំផ្លាញទាំងស្រុង នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល្លដែលអូសបន្លាយអស់រយៈពេលជិត ៣០ឆ្នាំ ។ បន្ទាប់ពីមានរដ្ឋប្រហារ លន់ ណុល នៅឆ្នាំ១៩៧០ កម្ពុជាបានធ្លាក់ក្នុងស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ដែលធ្វើឲ្យសាធារណជនបាត់បង់ជំនឿទុកចិត្តលើរដ្ឋាភិបាល សេដ្ឋកិច្ច និងរូបិយវត្ថុជាតិ ។ សង្គ្រាមបានកើតឡើងនៅគ្រប់ទីកន្លែង ប្រទេសត្រូវបានផ្តាច់ជាកង់ៗ ហើយ

ផលិតកម្ម បានថយចុះជាលំដាប់។ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដុនដាបជាខ្លាំង ប្រទេសទាំងមូលត្រូវពឹងផ្អែកលើជំនួយបរទេស ។ អតិផរណាបានកើនឡើងកាន់តែខ្លាំងឡើងៗ ដោយសារកង្វះការផ្គត់ផ្គង់ក្នុងស្រុកហើយថវិការរដ្ឋត្រូវបំពេញបន្ថែមដោយបុរេប្រទានពីធនាគារកណ្តាល។ ធនាគារជាតិនៃកម្ពុជានាពេលនោះបានបោះពុម្ពប្រាក់ជាច្រើនបន្ថែម ដើម្បីបំពេញឱនភាពថវិការដ្ឋ ជាពិសេស សម្រាប់បើកប្រាក់ខែឲ្យមន្ត្រីរាជកា ។ យោងតាមការសិក្សាលើអតិផរណាសម័យនោះបង្ហាញថា ថ្លៃទំនិញនានាបានឡើងថ្លៃ ជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ឧទាហរណ៍ ថ្លៃគុយទាវមួយចាន ដែលមានតម្លៃ ៥០រៀល បានឡើងថ្លៃដល់ ៥០០រៀល រួចឡើងដល់ ១០០០រៀល ហើយថ្លៃមេជ្រូកមួយបាន កើនឡើងដល់ ១លានរៀល គឺស្មើនឹងប្រាក់បៀវត្សរ៍មន្ត្រីថ្នាក់មធ្យមម្នាក់ក្នុងពេលពីឆ្នាំ ។ ភាពមិនច្បាស់លាស់ នៃស្ថានភាពនយោបាយនិងអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រទេស (កំណើនអត្រាអតិផរណា ឱនភាពថវិការដ្ឋ កំណើនការនាំចូលនិងការធ្លាក់ចុះផលិតកម្មក្នុងស្រុក ។ល។) បានធ្វើឲ្យប្រជាជន បាត់បង់ជំនឿទុកចិត្តយ៉ាងខ្លាំងទៅលើរូបិយវត្ថុជាតិ ។ គួរកត់សម្គាល់ថា នៅក្នុងសម័យ លន់ ណុល ប្រាក់ដុល្លារបានហូរចូលកាន់តែច្រើនតាមរយៈជំនួយអាមេរិក ហើយការរក្សាទុក និងប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ត្រូវបានគេសង្កេតឃើញមាននៅក្នុងមជ្ឈដ្ឋានអ្នកមាបុព្វសិទ្ធដែលស្ថិតនៅក្បែរ អ្នកកាន់អំណាច អ្នករកស៊ីលួចលាក់ក្នុងសង្គ្រាម និងអ្នកទទួលផលពីជំនួយរបស់អាមេរិក ។ លើសពីនេះរូបិយវត្ថុត្រូវបានបាត់បង់ទាំងស្រុងក្នុងសម័យ ប៉ុល ពយ(១៩៧៥-១៩៧៩) ។ សង្គមទាំងមូលត្រូវបានប្រែក្លាយទៅជាសង្គមទាសភាព គ្មានកម្មសិទ្ធឯកជន គ្មានទីផ្សារ គ្មានរូបិយវត្ថុ និងគ្មានសិទ្ធសេរីភាពអ្វីទាំងអស់ ។ បទពិសោធន៍ខ្លោចផ្សាទាំងនេះគឺ ជាឬសគល់ចម្បងនៃការបាត់បង់ជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិមកដល់សព្វថ្ងៃ ។

ក្រោយពីថ្ងៃរដោះ ៧ មករា ឆ្នាំ ១៩៧៩ ប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងបានរួចផុតពីសម័យកាលខ្មៅងងឹតនៃរបប ប៉ុល ពត ហើយសេដ្ឋកិច្ចជាតិក៏បានចាប់ផ្តើមមានសកម្មភាពឡើងវិញបន្តិចម្តងៗពីបាតដៃទទេ ។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៧៩ ធនាគារកណ្តាលត្រូវបានបង្កើតឡើងហើយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ប្រាក់រៀលត្រូវបានដាក់ឲ្យចរាចរឡើង ។ ទំនុកចិត្តលើប្រាក់រៀលត្រូវបានចាប់ផ្តើមស្តារឡើងវិញពីចំនុចសូន្យ ។ នាពេលនេះការដោះដូរភាគច្រើនត្រូវបានធ្វើឡើងដោយទំនិញនិងទំនិញនៅឡើយ ហើយវត្ថុមានតម្លៃនានាផងដែរ ។

នៅក្នុងពាក់កណ្តាលទី២ នៃទស្សវត្សរ៍១៩៨០ រដ្ឋបានចាប់ផ្តើមកំណែទម្រង់ពីសេដ្ឋកិច្ចមជ្ឈការទៅរកសេដ្ឋកិច្ចទីផ្សារជាមុន និងបានអនុញ្ញាតបន្តិចម្តងៗឲ្យមានវត្តមានជំនួយផ្នែកមនុស្សធម៌របស់អង្គការសហប្រជាជាតិនិងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងជំនួយហិរញ្ញវត្ថុពីគ្រួសារខ្មែរ

នៅបរទេស ។ ការបើកលទ្ធភាពនេះបានធ្វើឲ្យប្រាក់ដុល្លារអាមេរិកហូរចូលក្នុងសេដ្ឋកិច្ចកម្ពុជាសន្សឹមៗ ។ លើសពីនេះ កត្តាដែលធ្វើឲ្យប្រជាជនកម្ពុជាបាត់បង់ជំនឿទុកចិត្តមកលើប្រាក់រៀលជាថ្មីម្តងទៀតនេះគឺនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ រដ្ឋបានជួបប្រទះនឹងឱនភាពថវិកាយ៉ាងខ្លាំងដែលតម្រូវឲ្យធនាគារកណ្តាលបោះពុម្ពរូបិយវត្ថុ បន្ថែមដើម្បីបំពេញការចំណាយរបស់រដ្ឋ ដែលបន្ទាប់ថយចុះយ៉ាងខ្លាំងផងដែរ ។ វិបត្តិថវិកា និងវិបត្តិវត្ថុ គួបផ្សំនឹងការហូរចូលយ៉ាងសន្ធឹកសន្ធាប់សហប្រជាជាតិនៅកម្ពុជា (UNTAC) បានធ្វើឲ្យប្រជាជនកម្ពុជាទទួលយកប្រើប្រាស់ និងរក្សាទុកប្រាក់ដុល្លារកាន់តែទូលំទូលាយនៅទូទាំងប្រទេស ។ កងរក្សាសន្តិសុខ ជំនាញការ មន្ត្រី និងក្រុមការងារ ប្រតិបត្តការរបស់ខ្លួន រាប់ចាប់ពីការបើកប្រាក់ខែ ការជួលកន្លែងស្នាក់នៅ រហូតដល់ការចំណាយលើម្ហូបអាហារ ។

ចាប់តាំងពីកម្ពុជាទទួលបានសន្តិភាព១០០% នៅឆ្នាំ១៩៩៨ មក រដ្ឋាភិបាល បានបន្តខិតខំប្រឹងប្រែងរក្សាស្ថិរភាពនយោបាយ សង្គម និងសេដ្ឋកិច្ច ។ ប្រទេសជាតិទាំងមូលមានការរីចម្រើនយ៉ាងឆាប់រហ័ស ហើយជំនឿទុកចិត្តមកលើប្រាក់ត្រូវបានពង្រឹងជាបន្តបន្ទាប់ ។ រាជរដ្ឋាភិបាលបានដាក់ចុះនូវគោលនយោបាយនិងវិធានការនានា ដើម្បីលើកម្ពស់ជំនឿទុកចិត្តនិងការប្រើប្រាស់ប្រាក់រៀល ។ ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវគោលនយោបាយនិងវិធានការទីផ្សារនានា រួមមាន៖

១. រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំនឿទុកចិត្តមកលើប្រាក់រៀលតាមរយៈការរក្សាស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀល ដើម្បីការពារអំណាចទិញរបស់ប្រាក់រៀល

២. ការពង្រឹងគុណភាព និងសោភ័ណភាពក្រដាសប្រាក់រៀល

៣. បំពេញសេចក្តីត្រូវការប្រាក់រៀលរបស់សេដ្ឋកិច្ច

៤. ការលើកទឹកចិត្តនិងជំរុញឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក៏ដូចជា សាធារណជននានាប្រើប្រាស់ប្រាក់រៀល ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន ៖

   ១. អនុវត្តគោនយោបាយសារពើពន្ធប្រកបដោយប្រសិទ្ធភាព

   ២. ពង្រឹងស្ថានភាពថវិការរបស់រដ្ឋ

   ៣. តម្រូវឲ្យការបង់ពន្ធជាប្រាក់រៀល

   ៤. តម្រូវឲ្យការបង់ថ្លៃប្រើប្រាស់ទឹកនិងភ្លើងជាប្រាក់រៀល ។ល។ ម្យ៉ាងទៀតក្រសួងពាណិជ្ជកម្មក៏បានចេញការណែនាំចំពោះអាជីវករឲ្យកំណត់ថ្លៃទំនិញសេវាជាប្រាក់រៀលដែរ ។ លើសពីនេះ វិធានការលើកទឹកចិត្តនានាក៏ត្រូវបាន

ប្រើប្រាស់ផងដែរ ដើម្បីឲ្យការប្រើប្រាស់មានភាពងាយស្រួល និងទាក់ទាញជាងរូបិយប័ណ្ណ ដូចជា ការដាក់អាត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងកម្ចីជាប្រាក់រៀល និងការយកកម្រៃសេវាផ្សេងៗជារៀលទាបជារូបិយប័ណ្ណ ជាដើម ។

## ៣.២. គណៈកម្មាធិការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុ

គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុជា គណៈកម្មាធិការគោលនយោបាយកម្រិតខ្ពស់របស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីវាយតម្លៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយរូបិយវត្ថុ ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃ ។ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុជួបប្រជុំជាប្រចាំត្រីមាស ពោលគឺ ៤ដងក្នុងមួយឆ្នាំ ។ មុនកិច្ចប្រជុំចាប់ផ្តើម ក្រុមលេខាធិការដ្ឋាន រួមមានអ្នកសេដ្ឋកិច្ច និងមន្ត្រីបុគ្គលិកផ្សេងទៀតពីនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានស្ថិតិ នឹងរៀបចំរបាយការណ៍វិភាគលំអិតសម្រាប់គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ ។ យោងតាមរបាយការណ៍នេះ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុនឹងពិភាក្សា និងវាយតម្លៃទិដ្ឋភាពផ្សេងគ្នានៃសេដ្ឋកិច្ច ដោយផ្តោតលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុគន្លឹះៗគិតចាប់ពីកិច្ចប្រជុំចុងក្រោយ ។

គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុនឹងប្រមូលផ្តុំការវិភាគនេះ គួបផ្សំនឹងការវិនិច្ឆ័យ និងការព្យាករណ៍ពីអ្វីដែលនឹងអាចកើតមានក្នុងសេដ្ឋកិច្ច និងថ្លៃក្នុងអំឡុងពេលខាងមុខ រួចធ្វើការសម្រេចចិត្តលើជម្រើសគោលនយោបាយរូបិយវត្ថុដើម្បីធានាស្ថិរភាពថ្លៃរយៈពេលវែង។

### សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ

| | | |
|---|---|---|
| ឯកឧត្តម ជា ចាន់តូ | ទេសាភិបាល | ប្រធាន |
| ឯកឧត្តម ស៊ុំ សន្និសិទ្ធ | អគ្គលេខាធិការ | អនុប្រធាន |
| ឯកឧត្តម គិម វ៉ាដា | អគ្គនាយកត្រួតពិនិត្យ | សមាជិក |
| លោកជំទាវ ជា សិរី | អគ្គនាយកបច្ចេកទេស | សមាជិកា |
| លោក រ័ត្ន សុវណ្ណនរៈ | អគ្គនាយករង | សមាជិក |
| លោក គឹមទី កោមលី | អគ្គនាយករង | សមាជិក |
| លោកស្រី គាំ គណ្ឌា | អគ្គនាយករង | សមាជិកា |
| លោកស្រី អ៊ុច សុខុម | អគ្គបេឡារង | សមាជិកា |

លោក ឃូ វុណ្ណី ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិង សហប្រតិបត្តិការអន្តរជាតិ សមាជិកអចិន្ត្រៃយ៍

## ៣.៣. ឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

### ៣.៣.១. គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់

ក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ កម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរដែលឆ្លុះបញ្ចាំងតាមរយៈស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់ ។ ស្ថិរភាពនេះបានបង្កើតជំនឿទុកចិត្តរបស់សាធារណៈជន និងភ្នាក់ងារសេដ្ឋកិច្ចនានា មកលើសេដ្ឋកិច្ច និងការប្រើប្រាស់រូបិយវត្ថុជាតិជាលំដាប់ព្រមទាំងបានបើកកាលានុវត្តភាព ឲ្យអាជ្ញាធរដាក់ឲ្យអនុវត្តវិធានការថ្មីបន្ថែមទៀត ដើម្បីជម្រុញការប្រើប្រាស់រូបិយវត្ថុជាតិឲ្យកាន់តែទូលំទូលាយឡើង ។

គោលនយោបាយរូបិយវត្ថុ គួរបន្តអនុវត្តដោយទន់ភ្លន់ និងប្រុងប្រយ័ត្ន សំដៅធានាឲ្យបានស្ថិរភាពថ្លៃ ដើម្បីការពារអំណាចទិញរបស់រូបិយវត្ថុជាតិ ។ ការសម្រួលចរាចរណ៍ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចមានសារៈសំខាន់ ដើម្បីឆ្លើយតបឲ្យបានកាន់តែប្រសើរនូវកំណើនតម្រូវការរូបិយវត្ថុជាតិ ។ ដូច្នេះ ធនាគារនៃកម្ពុជានឹងពង្រឹងនូវយន្តការបែងចែក និងផ្គត់ផ្គង់ប្រាក់រៀល ស្របតាមតម្រូវការទីផ្សារ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងស្វែងរកឱកាសក្នុងការលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុ និងពង្រឹងយន្តការចម្លងឥទ្ធិពល (Transmission Mechanism) នៃការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

គោលនយោបាយអត្រាប្តូរប្រាក់ របស់ធនាគារជាតិនៃកម្ពុជា គឺជាឧបករណ៍នយោបាយមួយរបស់គោលនយោបាយរូបិយវត្ថុ ដែលមានគោលដៅចម្បងរក្សាស្ថិរភាពថ្លៃ ។ ជាមួយនឹងការអនុវត្តរបបអត្រាប្តូរប្រាក់ អណ្តែតមានការគ្រប់គ្រង ធនាគារជាតិនឹងធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាព អត្រាប្តូរប្រាក់ ទៅតាមគោលដៅដែលបានកំណត់ ។ អត្រាប្តូរប្រាក់ផ្លូវការ ជាអត្រាទិញ-លក់រវាងរូបិយវត្ថុជាតិ និងរូបិយប័ណ្ណបរទេសផ្សេងទៀត ។ អត្រាប្តូរ ប្រាក់ផ្លូវការនេះត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា និងដាក់ឲ្យប្រើប្រាស់សម្រាប់រាល់ប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជាជាមួយនឹងភាគីពាក់ព័ន្ធ ។ លើសពីនេះ ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជា សាធារណៈជនអាចប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការនេះទៅតាមគោលដៅរៀងៗខ្លួន ហើយអត្រានេះក៏ជា អត្រាប្តូរប្រាក់គោលប្រើដោយវិស័យឯកជន ផងដែរ ។

**ធនាគារជាតិនៃកម្ពុជា បានកំណត់អត្រាប្តូរប្រាក់ផ្លូវការ ដូចតទៅ ៖**

"គណៈកម្មការកំណត់អត្រាប្តូរប្រាក់ផ្លូវការ" ដែលរួមមានសមាសភាពមកពីនាយកដ្ឋានពាក់ព័ន្ធ ដូចជា នាយកដ្ឋានគ្រប់គ្រងប្តូរប្រាក់ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានស្ថិតិ និងនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ គឺជាអ្នកកំណត់អត្រាប្តូរប្រាក់ផ្លូវការ។

សមាជិកគណៈកម្មការនេះ ជួបប្រជុំគ្នាជារៀងរាល់ព្រឹក ដើម្បីពិភាក្សានិងវិភាគទៅលើសូចនាករ សំខាន់ៗមួយចំនួន ដែលត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ។ បន្ទាប់មកអត្រាប្តូរប្រាក់ផ្លូវការនេះ ដាក់ជូនថ្នាក់អគ្គនាយកបច្ចេកទេសសម្រេច និងផ្សព្វផ្សាយជាសាធារណៈ។

ករណីដែលទីផ្សារមានការប្រែប្រួលខ្លាំង គណៈកម្មការនឹងមានការប្រជុំជាបន្ទាន់ ដើម្បីរកដំណោះស្រាយ និងកំណត់យុទ្ធសាស្ត្រ ។

ទន្ទឹមនឹងនេះ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់នៅតែជាគោលនយោបាយចំបាច់ ដើម្បីពង្រឹងជំនឿទុកចិត្តមកលើប្រាក់រៀល សំដៅបង្កើនតម្រូវការរូបិយវត្ថុជាតិ ។ ក្នុងរយៈពេលខ្លី និងមធ្យម ការរក្សារបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង (Stabilized exchange rate regime) មានសារៈសំខាន់ណាស់ដើម្បីសម្រេចបានតាមគោលដៅនេះ ។ ធនាគារជាតិនៃកម្ពុជានឹងអភិវឌ្ឍន៍ក្របខ័ណ្ឌ និងយន្តការដេញថ្លៃលក់ និងទិញរូបិយប័ណ្ណ ដើម្បីបន្តពង្រឹងប្រសិទ្ធភាព និងកំណត់អត្រាប្តូរប្រាក់ឲ្យកាន់តែឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារ ។ នៅក្នុងរយៈពេលវែងអត្រាប្តូរប្រាក់នឹងអនុញ្ញាតឲ្យមានភាពបត់បែងកាន់តែច្រើនស្របតាមបម្រែបម្រួលសេដ្ឋកិច្ច និងធ្វើឲ្យភ្នាក់ងារសេដ្ឋកិច្ចយល់ពីហានិភ័យនៃការកាន់រូបិយវត្ថុ អន្តរជាតិដោយសារការប្រែប្រួលអត្រាប្តូរប្រាក់ ។

### ៣.៣.២. ប្រាក់បម្រុងកាតព្វកិច្ច ( Reserve Requirement)

ប្រាក់បម្រុងកាតព្វកិច្ច ជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ ដែលធនាគារជាតិ នៃកម្ពុជាប្រើដើម្បីគ្រប់គ្រងល្បឿនកំណើនឥណទាន ។ បច្ចុប្បន្នធនាគារជាតិបានកំណត់ថាប្រាក់បម្រុងកាតព្វ កិច្ចជាឧបករណ៍គោលនយោបាយរូបិយវត្ថុផ្លូវការ ប៉ុន្តែ ឧបករណ៍មួយនេះនៅមានកំរិតនៅឡើយក្នុងការជម្រុញ គោលនយោបាយរូបិយវត្ថុអោយមានប្រសិទ្ធភាពក្នុងពេលបច្ចុប្បប្រាក់បម្រុងកាតព្វកិច្ចត្រូវបានអភិវឌ្ឍន៍៣លើក៖ ដោយនៅឆ្នាំ ១៩៩៣ ធនាគារជាតិបានកំណត់ប្រាក់

បម្រុងកាតព្វកិច្ចចំនួន ៥% លើប្រាក់បញ្ញើសរុបរបស់ធនាគារតែក្រោយមកនៅឆ្នាំ ១៩៩៧ ធនាគារជាតិក៏បានធ្វើការកែតម្រូវ និងបង្កើនឲ្យមានប្រាក់បម្រុងកាតព្វកិច្ចដល់ ៨%វិញ ។ អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយប័ណ្ណបរទេស[7] (ជាពិសេស ប្រាក់ដុល្លារអាមេរិក) និង រូបិយវត្ថុជាតិ[8] ត្រូវបានកំណត់ផ្សេងគ្នា។ អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយបណ្ណបរទេស និងរូបិយវត្ថុជាតិ ត្រូវបានកំណត់ក្នុងអត្រា១២,៥% និង ៨% រៀងគ្នា ។ ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសចំនួន ១២,៥% ក្នុងនោះ ៤,៥% ត្រូវបានផ្តល់ការប្រាក់ដោយធនាគារជាតិនៃកម្ពុជា និង ៨% បន្ថែមទៀត មិនត្រូវបានផ្តល់ការប្រាក់ទេ ។ ប៉ុន្តែការបង្កើនអត្រាប្រាក់បំម្រុងកាតព្វកិច្ចនេះក៏បានជួយកាត់បន្ថយបរិមាណផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងចរាចរណ៍បានមួយចំនួន និងអាចជួយធ្វើអោយសាធារណៈជនមានជំនឿទុកចិត្តលើប្រព័ន្ធធនាគារជាងមុន ។ ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារៀល ក៏មិនត្រូវបានផ្តល់ការប្រាក់ដែរ ។

### ៣.៣.៣. មូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា (NCD)

#### ៣.៣.៣.១. មូលហេតុនៃការបង្កើតអោយមាន មូលប័ត្រអាចជួញដូរបានរបស់ធនាគារជាតិ

ទីផ្សារមូលបត្រនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដោយសារតែ ៖

១. គ្មានឧបករណ៍អាចជួញដូរបានដូចជាមូលបត្ររដ្ឋាភិបាលដែលអាចបើកផ្លូវសម្រាប់ការអភិវឌ្ឍទីផ្សារអន្តរធនាគារ

២. អវត្តមានអ្នកកំណត់ទីផ្សារ និងបណ្តាញអន្តរការីយកម្មនានា និង

៣. គ្មានអត្រាការប្រាក់គោលសម្រាប់មូលដ្ឋានក្នុងការកំណត់ថ្លៃមូលបត្រនាពេលបោះផ្សាយ ។

ដោយសារហេតុផលខាងលើ ធនាគារជាតិនៃកម្ពុជា (NBC) បានបង្កើតគម្រោងការអភិវឌ្ឍទីផ្សារអន្តរធនាគារ ដោយបានចេញប្រកាសលេខ ធ.៥.០១០-១៨៣ ប្រ.ក ស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១០ (ឧបសម្ព័ន្ធទី៤) ។ គម្រោងអភិវឌ្ឍទីផ្សារអន្តរធនាគារមានបំណង៖

ក.បង្កើនការឲ្យខ្ចីអន្តរធនាគារប្រកបដោយសុវត្ថិភាព

---

[7] រូបិយប័ណ្ណ (Foreign currency) សំដៅលើក្រដាស់ប្រាក់ឬកាសដែលបានបោះផ្សាយដោយធនាគាកណ្តាលបរទេស។ ឧទាហរណ៍ ប្រាក់អាមេរិកគឺជារូបិយប័ណ្ណនៅកម្ពុជា។

[8] រូបិយវត្ថុ (National currency) សំដៅលើក្រដាសប្រាក់ឬកាសដែលបានបោះផ្សាយ និដាក់ឲ្យចរាចរដោយធនាគារកណ្តាលជាតិនៃប្រទេសមួយ។ នៅកម្ពុជាជារូបិយវត្ថុជាតិគឺប្រាក់រៀលដែលបោះដោយធនាគារជាតិនៃកម្ពុជា។

ខ.បង្កើតឲ្យមានឧបករណ៍មានប្រសិទ្ធភាពបន្ថែម សម្រាប់អនុវត្តនយោបាយរូបិយវត្ថុ និងនយោបាយអត្រា ប្តូរប្រាក់

គ.បែងចែកឡើងវិញនូវប្រភពហិរញ្ញវត្ថុក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងបង្កើននិងពង្រីកអន្តរការិយកម្មហិរញ្ញវត្ថុ

ឃ.កាត់បន្ថយការផ្តេកផ្តួលរបស់ធនាគារលើប្រភពទុនអំពីអ្នកដាក់ប្រាក់បញ្ញើ ដើម្បីបំពេញតម្រូវការសន្ទនីយ ភាពបណ្តោះអាសន្នរយៈពេលខ្លីនិងមធ្យម

ង. ឆ្លើយតបទៅនឹងតម្រូវការទីផ្សារហិរញ្ញវត្ថុក្នុងការៈ

- វិនិយោគសន្ទនីយភាពដែលនៅសល់ទំនេររយៈពេលខ្លី ។ ធនាគារភាគច្រើនមិនមានជម្រើសផ្សេងក្នុងការវិនិយោគសន្ទនីយភាពដែលលើសពីការប្រើប្រាស់របស់ខ្លួនឡើយ
- កាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងសន្ទនីយភាព និងការផ្តល់ប្រាក់កម្ចីអន្តរធនាគារ

បន្ទាប់បានរៀបចំអស់រយៈពេល ៣ ឆ្នាំមក ធនាគារជាតិនៃកម្ពុជា បានសម្រេចដាក់ឲ្យដំណើរការជាផ្លូវការនូវគម្រោងអភិវឌ្ឍន៍ទីផ្សារអន្តរធនាគាររបស់ខ្លួននៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ ។

### ៣.៣.៣.២. លក្ខណៈរបស់មូលបត្រអាចជួញដូរបាន

មូលបត្រអាចជួញដូរបាន (NCD) គឺជាប័ណ្ណបំណុលរយៈពេលខ្លីមានការប្រាក់ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ មូលបត្រនេះត្រូវបានចេញផ្សាយជាប្រាក់រៀល (KHR) និងប្រាក់ដុល្លារអាមេរិក (USD) ដើម្បីជួយ ដល់បណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុវិនិយោគនូវសន្ទនីយភាពរយៈពេលខ្លីរបស់ខ្លួន។ តម្លៃនាមចារឹកអប្បបរមា គឺ ៥០.០០០ ដុល្លារអាមេរិក ឬ ២០០.០០០.០០០ រៀល ។ កាលវសាននៃ KHR-NCD មានចាប់ពី ២ សប្តាហ៍ ដល់ ១ឆ្នាំ ចំណែកឯ USD-NCD វិញ មានកាលវសានចាប់ពី ២សប្តាហ៍ ដល់ ៦ខែ។ អត្រាការប្រាក់របស់ NCD ត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយប្រែ

### ៣.៣.៣.៣. គុណសម្បត្តិនៃNCD

គុណសម្បត្តិនៃការកាន់កាប់NCDរួមមានៈ

#### ១.គ្មានហានិភ័យ :

ដោយសារតែ NCD បានគាំទ្រដោយប្រកាសស្តីពីការចេញផ្សាយមូលបត្រអាចជួញ ដូរបាន

ដោយធនាគារជាតិនៃកម្ពុជា និងចេញដោយ NBC ដូច្នេះឧបករណ៍នេះគ្មានហានិភ័យឥណទានឡើយ។

### ២. ទទួលបានការប្រាក់ :

NCD គឺជាឧបករណ៍អាចជួញដូរបានដែលមានការប្រាក់ ដូច្នេះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានប្រើប្រាក់បម្រុងសល់ទំនេររបស់ខ្លួនជាវ NCD អាចនឹងទទួលបានការប្រាក់ ដែលនឹងត្រូវបានទូទាត់សងនាកាលវសានទៅក្នុងគណនីចរន្តរបស់ម្ចាស់មូលបត្រដែលបានបើកនៅNBC ។ អត្រាការប្រាក់របស់ NCD ខ្ពស់ជាងអត្រាការប្រាក់របស់ប្រាក់បញ្ញើមានកាលកំណត់។ រូបមន្តសម្រាប់ គណនាការប្រាក់NCDមានដូចខាងក្រោម:

$$I = Prt$$

ដោយ:

- I គឺជាការប្រាក់
- P គឺជាចំនួនប្រាក់ដើម
- r គឺជាអត្រាការប្រាក់ប្រចាំឆ្នាំ ជាភាគរយដោយចែកជាមួយចំនួនថ្ងៃពិតប្រាកដក្នុងឆ្នាំនីមួយៗ
- t អាយុកាល NCD

### ៣. អាចប្តូរសាច់ប្រាក់បានរហ័ស :

NCD គឺជាឧបករណ៍បំណុលរយៈពេលខ្លី គ្មានហានិភ័យ និងចេញផ្សាយ ដោយ NBC ដូច្នេះ NCD អាចត្រូវបានជួញដូរនៅក្នុងទីផ្សារទីពីរដែលមានកម្រិតសន្ទនីយភាពខ្ពស់។ លើសពីនេះទៀត ស្ថិតក្នុងដំណាក់កាលបណ្តោះអាសន្ន ធនាគារជាតិនៃកម្ពុជា នឹងទទួលទិញត្រឡប់វិញមុនកាលវសានតាមថ្លៃអប្បហារ ប្រសិនបើម្ចាស់ NCD មានការលំបាកក្នុងការស្វែងរកសមភាគី។ រូបមន្តសម្រាប់គណនាការទិញ NCD ត្រឡប់វិញមានដូចខាងក្រោម:

$$\text{ថ្លៃទិញត្រឡប់វិញ} = \frac{\text{ប្រាក់ដើម} + \text{ការប្រាក់}}{១ + \left(\frac{\text{អត្រាទិញត្រឡប់វិញប្រចាំឆ្នាំ x ចំនួនថ្ងៃនៅសល់ដល់កាលវសាន}}{\text{ចំនួនថ្ងៃពិតប្រាកដក្នុងឆ្នាំនីមួយៗ}}\right)}$$

**៤. អាចប្តូរកម្មសិទ្ធិ:**

ម្ចាស់ NCD អាចផ្ទេរ NCD ទៅឱ្យភាគីណាមួយនៅ ពេលណាមួយក៏បាននៅក្នុងទីផ្សារអន្តរធនាគារ។ NBC នឹងផ្ទេរកម្មសិទ្ធិភាពជូន នៅពេលណាបានទទួលការជូនដំណឹងពីអ្នកទិញ និងអ្នកលក់។

**៥. អាចធ្វើជាវត្ថុធានា :**

NCD អាចត្រូវបានប្រើជាវត្ថុធានាសម្រាប់ប្រតិបត្តិការឥណទាន ពីធនាគារជាតិនៃ កម្ពុជា និងនៅក្នុងទីផ្សារអន្តរធនាគារ។

**៣.៣.៣.៤. គុណវិបត្តិនៃ NCD**

គុណវិបត្តិមួយចំនួនមានដូចជា៖

១. វិនិយោគិនមិនអាចវិនិយោគមូលនិធិរបស់ខ្លួន តាមកាលវសានដែលគេចង់បានឡើយ ព្រោះកាលវសាននេះត្រូវបានកំណត់ជាមុនដោយធនាគារជាតិនៃកម្ពុជា។

២. អត្រាការប្រាក់ NCD មានកម្រិតថេរ ដូច្នេះវិនិយោគិនមិនអាចទទួលបានការប្រាក់ខ្ពស់ឡើយ ប្រសិនបើ អត្រាការប្រាក់កើនឡើង ក្នុងអំឡុងពេលវិនិយោគនេះ។

៣. រាល់សំណើសុំការលក់ NCD ឲ្យ NBC វិញ គឺអាស្រ័យលើការសំរេចចិត្តរបស់ NBC។ NBC លើកទឹកចិត្តឱ្យវិនិយោគិនទាំងអស់ លក់ NCD នៅក្នុងទីផ្សារអន្តរធនាគារ ។

៤. តម្លៃ NCD ដែលធនាគារជាតិនៃកម្ពុជានឹងត្រូវទិញត្រឡប់វិញ គឺអាស្រ័យទៅនឹងរយៈពេលកាន់កាប់ និងអត្រាអប្បហាររបស់ NBC ។

៥. ក្នុងអំឡុងពេលនៃការវិនិយោគ វិនិយោគិនអាចប្រឈមមុខនឹងហានិភ័យនៃអត្រាការប្រាក់ ដោយសារតែ ការប្រែប្រួលអត្រាទីផ្សារ។

**៣.៣.៣.៥. ការស្នើសុំ និងប្រតិបត្តិការមូលបត្រអាចជួញដូរបាន**

**១. ការបើកគណនីបញ្ញើមូលបត្រ (NCD Custodian Account)**

- ពាក្យសុំបើកគណនីបញ្ញើមូលបត្រ ចំនួន១ច្បាប់ (ឧបសម្ព័ន្ធ ៥)
- លិខិតអនុញ្ញាត (Authorized Letter)

- គំរូហត្ថលេខាចំនួន៣ច្បាប់ ដែលអាចទំនាក់ទំនងទៅកាន់ការិយាល័យគ្រប់គ្រងមូលបត្រ និងនាយកដ្ឋានប្រតិបត្តិការ ដើម្បីទទួលបានគំរូហត្ថលេខា
- ឯកសារថតចម្លងពាក់ព័ន្ធរួមមាន៖

  ក. លក្ខន្តិកៈ

  ខ.អាជ្ញាប័ណ្ណ

  គ. លិខិតឆ្លងដែនអត្តសញ្ញាណប័ណ្ណរបស់ម្ចាស់គណនី ឬអ្នកមានសិទ្ធ

**២. ការសុំជាវ NCD**

អ្នកសុំជាវត្រូវតែមានគណនីបញ្ជីមូលបត្រជាមុន។ អ្នកសុំជាវត្រូវផ្តល់ជូនការិយាល័យគ្រប់គ្រងមូលបត្រ នាយកដ្ឋានប្រតិបត្តិការ នូវឯកសារដូចខាងក្រោម៖

- ពាក្យសុំជាវ NCD ចំនួន១ច្បាប់ (ឧសម្ព័ន្ធ៦)
- ឧបករណ៍ទូទាត់ រួមមានមូលប្បទានបត្រ ឬ បញ្ជាផ្ទេរប្រាក់

**៣. ការផ្ទេរកម្មសិទ្ធិ**

ប្រតិបត្តិការផ្ទេរកម្មសិទ្ធិកើតមានឡើងនៅពេលដែលមានការលក់ផ្តាច់ ដាក់បញ្ចាំ ឬប្រតិបត្តិការលក់ សន្យាទិញវិញ REPO រវាងស្ថាប័នមួយនិងស្ថាបនមួយទៀត ដែលបានបើកគណនីបញ្ជីមូលបត្រនៅធនាគារជាតិ នៃកម្ពុជា។ ការផ្ទេរកម្មសិទ្ធិអាចនឹងប្រព្រឹត្តិឡើងពីរករណី៖

**ក. ករណីទូទាត់ប្រព្រឹត្តិឡើងតាមរយៈធនាគារជាតិនៃកម្ពុជា**

- ទាំងពីរភាគីត្រូវប្រគល់ពាក្យសុំផ្ទេរជូនការិយាល័យគ្រប់គ្រងមូលបត្រ នាយកដ្ឋានប្រតិបត្តិការ។ (ឧសម្ព័ន្ធ៧)
- ភាគីអ្នកទិញ ត្រូវចេញឧបករណ៍ទូទាត់ ដែលអាចជាមូលប្បទានបត្រឬ បញ្ជាផ្ទេរប្រាក់ជូនភាគី អ្នកលក់ មកធនាគារជាតិនៃកម្ពុជា ដើម្បីផ្ទេរមូលនិធិដែលបានព្រមព្រៀង ចូលគណនីភាគីអ្នកលក់

**ខ. ករណីទូទាត់ដែលប្រព្រឹត្តិឡើងក្រៅធនាគារជាតិនៃកម្ពុជា**

- ទាំងពីរភាគីត្រូវប្រគល់ពាក្យសុំផ្ទេរកម្មសិទ្ធិជូន ការិយាល័យគ្រប់គ្រងមូលបត្រ នាយកដ្ឋានប្រតិបត្តិការយ៉ាងយូរបីថ្ងៃធ្វើការបន្ទាប់ពីបានព្រមព្រៀង (ឧបសម្ព័ន្ធ ៧)

### ៤. ការលក់មូលបត្រជូនធនាគារជាតិនៃកម្ពុជា

- ធនាគារជាតិនៃកម្ពុជា អាចនឹងទិញ NCD ដែលបានចេញបោះផ្សាយ និងនៅមានសុពលភាព តាមអត្រាទិញត្រឡប់វិញ (Repurchasing Rate)[9] ដូចដែលមានផ្សព្វផ្សាយលើគេហទំព័រធនាគារជាតិនៃកម្ពុជាជារៀងរាល់ថ្ងៃធ្វើការ។
- អ្នកស្នើសុំលក់ត្រូវបំពេញពាក្យសុំលក់មូលបត្រអាចជួញដូរ បានដោយប្រើប្រាស់ទម្រង់បំពេញដោយលក់តែមួយ (ឧបសម្ព័ន្ធទី៨) តែក្នុងលក្ខខ័ណ្ឌអ្នកលក់ច្រើនជាងមួយត្រូវបំពេញទម្រង់សម្រាប់ការលក់ច្រើនជាងមួយ (ឧបសម្ព័ន្ធ ៩) រួចប្រគល់ជូនការិយាល័យគ្រប់គ្រង មូលបត្រនៃនាយកដ្ឋានប្រតិបត្តិការ
- ការគណនាតម្លៃទិញ NCD ត្រឡប់វិញមុនកាលវសានត្រូវបានអនុវត្តតាមរូបមន្ត Discounting Method[10]

## ៣.៣.៤. ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

### ៣.៣.៤.១.គោលដៅនៃ ការបង្កើតប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា

ដើម្បីជម្រុញដល់ការប្រើប្រាស់មូលបត្រដែល អាចជួញដូរបានអោយមានប្រសិទ្ធភាពខ្ពស់ ធនាគារជាតិនៃកម្ពុជាបានបង្កើតអោយមានដាក់អោយអនុវត្តកិច្ចសន្យាមេសម្រាប់សម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារក្នុងទីផ្សាររូបិយវត្ថុ នឹងដាក់ឲ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity-Providing Collateralized Operation-LCPO) ។

ធនាគារជាតិនៃកម្ពុជាបាន នឹងកំពុងលើកកម្ពស់ការគ្រប់គ្រងសន្ទនីយភាពតាមរយៈការធ្វើទំនើបកម្មការតាមដាន និងព្យាករណ៍សន្ទនីយភាព ហើយនិងកំពុងបន្តអភិវឌ្ឍមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit-NCD) ។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ ឲ្យដំណើរការនូវ ប្រតិបត្តិការថ្មីមួយគឺការផ្តល់សន្ទនីយភាពដោយមានការធានា

---

[9] Repurchasing Rate គឺជាអត្រាដែលធនាគារកណ្តាលរបស់ប្រទេសមួយបានផ្តល់ប្រាក់កម្ចីដល់ធនាគារពាណិជ្ជក្នុងករណីមានការខ្វះមូលនិធិ ហើយអត្រាត្រូវបានប្រើប្រាស់ និងចេញជាផ្លូវការដោយអាជ្ញាធររូបិយវត្ថុ

[10] Discounting method ជាដំណើរការនៃការកំណត់តម្លៃបច្ចុប្បន្ននៃការទូទាត់ដែលត្រូវបានទទួលនាពេលអនាគត។ ការបញ្ចុះតម្លៃគឺជាកត្តាចម្បងដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់តម្លៃនៃលំហូរសាច់ប្រាក់នៅថ្ងៃស្អែក (អនាគត)។

(LCPO) ដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀលតាមការចាំបាច់ដល់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលជាភាគីពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

ក្នុងគោលដៅជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ ធនាគារជាតិ នៃ កម្ពុជាបានចេញ NCDs ដើម្បីអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញប្រើប្រាស់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការអន្តរធនាគារ ។ ការអនុវត្តកន្លងមកបានបង្ហាញថា ការចេញផ្សាយ NCDs បានស្រូបយកសន្ទនីយភាពទាំងជាដុល្លារអាមេរិច និងជារៀលពីគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ ដូចច្នេះ ដើម្បីឲ្យការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ធនាគារជាតិ នៃ កម្ពុជាបានអភិវឌ្ឍប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCOហើយ ប្រតិបត្តិការនេះធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖

- បង្កើនឲ្យមានអត្រាការប្រាក់គោល (Benchmark Rate) សម្រាប់ទីផ្សារអន្តរធនាគារ ដើម្បីបម្រើដល់ការអនុវត្តគោនយោបាយរូបិយវត្ថុ
- ជំរុញតម្រូវការ NCDs ដែលជាឧបករណ៍ធានាក្នុងទីផ្សារអន្តរធនាគារ
- ជំរុញការប្រើប្រាស់ប្រាក់រៀល ស្របតាមគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល ដោយសារ៖
    - ប្រតិបត្តិការ LPCO ផ្តល់សន្ទនីយភាពជាប្រាក់រៀល ដែលផ្តល់លទ្ធផលឲ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុផ្តល់ឥណទានជាប្រាក់រៀលច្រើនជាងមុន
    - ផ្តល់លទ្ធភាពឲ្យធនាគារជាតិ នៃ កម្ពុជាស្រូបយកប្រាក់ដុល្លារអាមេរិចក្នុងទីផ្សារតាមរយៈការប្រើប្រាស់ NCDs ជាពិសេស NCDs ចារិកជាប្រាសក់ដុល្លារអាមេរិចសម្រាប់ការដាក់ធានា ។
- ផ្តល់លទ្ធភាពឲ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុត្រៀមខ្លួនក្នុងការបង្កើតប្រតិបត្តិការជារៀលសម្រាប់នាពេលខាងមុខ ដោយសារធនាគារជាតិ នៃ កម្ពុជាអាចនឹងតម្រូវឲ្យគ្រឹះស្ថានធនគារ និងមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការជារៀល ឧទាហរណ៍ ការផ្តល់ឥណា) ក្នុងកម្រិតណាមួយ (ទាន
- ជួយគាំទ្រវិស័យកសិកម្ម ជាពិសេសក្នុងស្ថានភាពថ្មីៗនេះដែលវិស័យកសិកម្មកំពុងតែមានតម្រូវការមូលនិធិដើម្បីប្រមូលទិញកសិផល ។ តាមកាតអង្កេតរបស់អង្គការ JICA និង NBC ប្រាក់រៀលត្រូវបានប្រើប្រាស់ច្រើនបំផុតក្នុងវិស័យកសិកម្ម ដូច្នេះ ការផ្តល់សន្ទនីយភាពជាប្រាក់រៀលនឹងគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម និង

– រួមចំណែកបន្ទាបអត្រាការប្រាក់ជារៀលដែលកំពុងស្ថិតនៅក្នុងកម្រិតខ្ពស់នាពេលបច្ចុប្បន្ន ។

### ៣.៣.៤.២ . លក្ខណៈរបស់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា

បច្ចុប្បន្នទីផ្សារអន្តរធនាគារកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ ដោយប្រតិបត្តិការនៅក្នុងទីផ្សារនេះនៅមានកម្រិតទាប ។ ក្នុងស្ថានភាពនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានបន្តទី NCDs របស់ធនាគារជាតិនៃកម្ពុជា ហើយរក្សាទុកដល់ថ្ងៃឥណប្រតិទាន ចំណែកឯគ្រឹះស្ថានផ្សេងៗទៀតបង្ហាញពីកង្វះខាតសន្ទនីយភាពជាប្រាក់រៀល ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនេះព្រមទាំងរួមចំណែកអភិវឌ្ឍទីផ្សារអន្តរធនាគារ និងលើកម្ពស់ការប្រើប្រាស់ប្រាក់រៀល ធនាគារជាតិ នៃ កម្ពុជាបានសម្រេចដាក់ឲ្យដំណើរការប្រតិបត្តិការ LPCO ។ ប្រតិបត្តិការ LPCO ជាប្រតិបត្តិការផ្តល់សន្ទនីយភាពជាប្រាក់រៀល ដោយមានការប្រើប្រាស់មូបត្រជួញដូរបានជាវត្ថុធានាសម្រាប់ឥណប្រតិទានរយៈពេល ៣ខែ ហើយអាចបន្តកិច្ចការសន្យាថ្មីដោយមានការឯកភាពពីធនាគារជាតិ នៃកម្ពុជា ។

ប្រតិបត្តិការនឹងត្រូវធ្វើឡើងដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀល ហើយត្រូវធានាពេញលេញដោយការដាក់បញ្ចាំមូលបត្រអាចជួញដូរបានជាប្រាក់រៀល ឬ ប្រាក់ដុល្លារអាមេរិក។ វិធានការគ្រប់គ្រងហានិយភ័យសមស្របនឹងត្រូវបានអនុវត្តចំពោះមូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិកដើម្បីកាត់បន្ថយហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស (haircut ១០%លើមូលបត្រអាចជួញដូរបានចារឹកជាប្រាក់ដុល្លារអាមេរិក)។

ប្រតិបត្តិការនឹងត្រូវអនុវត្តប្រចាំខែ ហើយប្រតិបត្តិការនីមួយត្រូវមានកាលវសាន្ត ៣ខែ (ឧបសម្ព័ន្ធ១០) និងអាចបន្តបានអាស្រ័យលើប្រសិទ្ធភាពនៃការប្រើប្រាស់សន្ទនីយភាពដែលទទួល ហើយអត្រាការប្រាក់ដេញថ្លៃអប្បរមាសមស្របនិង បរិមាណទឹកប្រាក់ដែលគ្រោងផ្តល់ នឹងត្រូវប្រកាសនៅពេលចាប់ផ្តើមប្រតិបត្តិការ LCPO នីមួយៗ ដោយធានាគារជាតិនៃកម្ពុជា នឹងគំណត់បរិមាណផ្តល់សមស្របទៅតាមស្ថានភាពតម្រូវការជាក់ស្តែង ជាពិសេសទៅតាមការទទួលសំណើរដេញថ្លៃ នៅប្រតិបត្តិការនីមួយៗ ។ គ្រឹះស្ថានធនាគា និងមីក្រូហិរញ្ញវត្ថុនីមួយៗដែលចូលរួមក្នុងប្រតិបត្តិការ LCPO នឹងតម្រូវឲ្យមានការបង្ហាញពីចំនួនទឹកប្រាក់ដែលមានបំណងចង់ដេញថ្លៃជាមួយនឹងអត្រាការប្រាក់មួយ។

ការពីថ្ងៃពី១៤ ខែតុលា ឆ្នាំ២០១៦ ធនាគារជាតិ នៃ កម្ពុជាបានអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាំ (LPCO) ជាលើកទី១ ប្រកបដោយជោគជ័យ ដោយបានផ្តល់ប្រាក់

ដល់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញហិរវត្ថុដែលមានគុណវុឌ្ឍគ្រប់គ្រាន់សម្រាប់ប្រតិទាន៣ខែ ជាមួយនឹងការដាក់មូលបត្រជួញដូរបានជាវត្ថុធានា (NCD) ។ ដោយពិនិត្យមើលតម្រូវការសន្ទនីយភាពជាប្រាក់រៀលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងប្រតិបត្តិការទី១ និងទទួលបានទស្សនៈឆ្លើយតបជាវិជ្ជមានចំពោះការអនុវត្តប្រតិបត្តិការ LPCO ថែមទៀតធនាគារជាតិ នៃ កម្ពុជាសម្រេចដូចខាងក្រោមៈ

- បន្តអនុវត្តប្រតិបត្តិការ LPCO ជារៀងរាល់ខែ រយៈពេល៦ខែយោងតាមប្រតិទិនដូចបានភ្ជាប់ជាមួយ
- ប្រតិបត្តិការ LPCO លើកទី២នឹងត្រូវអនុវត្តនៅថ្ងៃទី២២ ខែវិច្ឆកា ឆ្នាំ២០១៦
- ប្រតិបត្តិការ LPCO នឹងបន្តអនុវត្តផ្អែកលើយន្តការអត្រាតែមួយ (Dutch Auction)
- អត្រាការប្រាក់ដេញថ្លៃអប្បបរមានឹងប្រកាសជូននៅកាលបរិច្ឆេទនៃការដេញថ្លៃនីមួយៗ
- ទំហំទឹកប្រាក់នៃការដេញថ្លៃប្រតិបត្តិការ LPCO នឹងប្រកាសជូនមួយសប្តាហ៍មុខកាលបរិច្ឆេទនៃការដេញថ្លៃប្រតិបត្តិការ LPCO
- គ្រឹះស្ថានដែលទទួលជោគជ័យ ត្រូវត្រៀមបម្រុងនូវមូលបត្រអាចជួញដូរបាន (NCD) ឬមានទឹកប្រាក់ក្នុងគណនីចរន្តគ្រប់គ្រាន់ ដើម្បីធានាលើប្រតិបត្តិការ LPCO
- ធនាគារជាតិ នៃ កម្ពុជានឹងវិភាគយ៉ាងប្រុងប្រយ័ត្នលទ្ធផល និងផលប៉ះពាល់នៃប្រតិបត្តិការ LPCO នីមួយៗនឹងរក្សាសិទ្ធកែប្រែល័ក្ខខណ្ឌនៃប្រតិបត្តិការ LPCO នាពេលអនាគតនៅពេលចាំបាច់។

### ៣.៣.៤.៣.ការស្នើសុំ និងប្រតិបត្តិការរបស់ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា

ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ត្រូវបានផ្តល់ជូនគ្រប់ធនាគារ និងមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា ក្នុងការបំពេញនៅកង្វះខាតនៅរូបិយវត្ថុ ប្រាក់រៀល។ LPCO គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានប្រតិបត្តិការ ដែលជានាយកដ្ឋានមួយក្នុងចំណោមនាយកដ្ឋានទាំង ៥ របស់អគ្គនាយកដ្ឋានបច្ចេកទេស។ បច្ចុប្បន្ន អគ្គនាយកដ្ឋានបច្ចេកទេសមានលោកជំទាវ ជា សិរី ជាងអគ្គនាយករង និងជាប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការអន្តរជាតិ (ERIC) គ្រប់គ្រង ២នាយកដ្ឋាន (ERIC and Statistic) និងលោក គឹមទី កោមលី ជាអគ្គនាយករង។ ជាទូទៅ ធានាគារជាតិនៃកម្ពុជា ជូនដំណឹងអំពីការដេញថ្លៃ LPCO មួយស

ប្អាហ៍មុន ដើម្បីឲ្យគ្រប់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ជ្រាបជាដំណឹង។ សម្រាប់ការចុះឈ្មោះចូលរួមក្នុងការដេញថ្លៃ ប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានាគ្រប់គ្រឹះស្ថានហិរញ្ញវត្ថុ ទាំងអស់ត្រូវទំនាក់ទំនងមកនាយកដ្ឋានប្រតិបត្តិការតាមរយៈ អ៊ីម៉ែល ឬ តាមរយៈទូរស័ព្ទ ។

ជាដំបូងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវទទួលស្គាល់ នឹងចុះហត្ថលេខាទៅកិច្ចការសន្យាក្នុងការដេញថ្លៃ (Master Agreement)[11] ។ កិច្ចសន្យាក្នុងការដេញថ្លៃត្រូវ បានទទួលស្គាល់ នឹងចុះហត្ថលេខាដោយ ប្រធាននាយកដ្ឋាន ដើម្បីធានាក្នុងការផ្តល់សិទ្ធក្នុងការដេញថ្លៃ។ ចំពោះទំហំទឹកប្រាក់ និងអត្រាការប្រាក់ត្រូវបានកំណត់ដោយនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិអន្តរជាតិ (ERIC) នឹងអនុញ្ញាតអោយប្រើប្រាស់ជាផ្លូវការដោយថ្នាក់ដឹកនាំនាយកដ្ឋាន ។ ERIC មានជំនាញស្រាវជ្រាវ វិភាគ នឹងព្យាការណ៍ ស្ថានភាពសេដ្ឋកិច្ច និងបញ្ហាហិរញ្ញវត្ថុសកលលោក។ គ្រឹះស្ថានហិរញ្ញវត្ថុហិរញ្ញវត្ថុទាំងអស់ មានសិទ្ធិក្នុងការសុំការផ្តល់ប្រឹក្សាដែលទាក់ទងទៅនឹងការដេញថ្លៃ ឬ កិច្ចសន្យា ក្នុងលក្ខខ័ណ្ឌដែលគ្រឹះស្ថានហិរញ្ញវត្ថុមិនយល់អំពីការដេញថ្លៃ។ នៅក្នុងកិច្ចសន្យាដេញថ្លៃ ក្រោយពេលចុះហត្ថលេខាត្រូវបានធានាថា ឈ្នះក្នុងការដេញថ្លៃ នៃប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានា ហើយគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវគោរពគោលការណ៍ ដែលមានបានចែងនៅក្នុងកិច្ចសន្យា៕

[11] Master Agreement ជាកិច្ចសន្យាគោលសម្រាប់ការចុះឈ្មោះចូលរួមដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានា នៅធនាគារជាតិនៃកម្ពុជា។

# ជំពូកទី ៤

# ការពិភាក្សាលើលទ្ធផល

# ស្រាវជ្រាវ

# ជំពូកទី ៤

# ការវិភាគទិន្នន័យ និងប្រសិទ្ធភាពនៃអនុវត្តឧបករណ៍នៃគោលនយោបាយរូបិយវត្ថុ របស់ធនាគារជាតិនៃកម្ពុជា ពីឆ្នាំ ២០១៤ ដល់ ២០១៦

## ៤.១. ទិន្នន័យ នៃមូលបត្រអាចជួញដូរបានជាប្រាក់រៀល និងដុល្លារអាមេរិក ២០១៣ ដល់ ២០១៧

### ៤.១.១. តារាងទិន្នន័យនៃមូលបត្រដែលអាចជួញដូរបានជាប្រាក់រៀល ឆ្នាំ២០១៤ ដល់ ២០១៧

ប្រតិបត្តិការចេញលក់របស់ NCDs ជាប្រាក់រៀល

| ឆ្នាំប្រតិបត្តិការ | ទំហំទឹកប្រាក់ NCDs ដែលបានលក់ (ចារឹកជាប្រាក់រៀល) |
|---|---|
| ២០១៤ | ០ (ទើបតែចាប់ផ្តើមប្រតិបត្តិលក់) |
| ២០១៥ | ៣.០០០.០០០.០០០.០០០ រៀល |
| ២០១៦ | ១២.០០០.០០០.០០០.០០០ រៀល |
| ២០១៧ (ឆមាសទី១) | ៦.០០០.០០០.០០០.០០០ រៀល |

ឧបសម្ព័ន្ធ ១១

### ៤.១.២. ក្រាហ្វិចរបស់មូលបត្រអាចជួញដូរបានជាប្រាក់រៀល



### ៤.១.៣.ការវិភាគទិន្នន័យ និងបកស្រាយតាមក្រាហ្វិចNCDsដែលបានចេញផ្សាយជាប្រាក់រៀល

ពីឆ្នាំ ២០១៣-២០១៧តម្រូវការ NCDs នៅតែបន្តកើនឡើងនៅឆ្នាំ២០១៦ នេះ ។ ទន្ទឹមនេះ NCDs ជារៀល ដែលបានចេញផ្សាយមានទំហំទឹកប្រាក់ប្រមាណ ១២ទ្រីលានរៀល ពោលគឺបានកើនឡើងជិត ៣ដង ធៀបនឹងឆ្នាំមុខ ។ យោងលើកម្រិតខ្ពស់នៃសន្ទនីយភាពលើសជាប្រាក់ដុល្លារអាមេរិច និងរៀល តម្រូវការ NCDs រំពឹងថានឹងបន្តកើនឡើងនៅឆ្នាំ២០១៧ ប៉ុន្តែផ្ទុយមកវិញកំនើននៃមូលបត្រដែលអាចជួញដូរបានចំនួន ៦ទ្រីលានរៀល នៅពាក់កណ្តាលឆ្នាំ២០១៧ (ឆមាសទី១) ហើយតាមការព្យាករណ៍សង្ឃឹមថានឹងកើនឡើងរហូតដល់ ១៩ ទ្រីលានរៀល (៥៨%) នៅចុងឆ្នាំ ២០១៧។

### ៤.១.៤. តារាងទិន្នន័យនៃមូលបត្រដែលអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិក (២០១៣ ដល់ ២០១៧)

**តារាងប្រតិបត្តិការចេញលក់របស់ NCDs**

| ឆ្នាំប្រតិបត្តិការ | ទំហំទឹកប្រាក់NCDsដែលបានលក់(ចារឹកជាប្រាក់ដុល្លារអាមេរិក) |
|---|---|
| ២០១៣ | ១៥.០០០.០០០ ដុល្លារ |
| ២០១៤ | ៤៥៩.០០០.០០០ ដុល្លារ |
| ២០១៥ | ២.៦៩០.០០០.០០០ ដុល្លារ |
| ២០១៦ | ១០.៧០២.០០០.០០០ ដុល្លារ |
| ២០១៧ (ឆមាសទី១) | ៨.៤០០.០០០.០០០ ដុល្លារ |

ឧបសម្ព័ន្ធ ១១

### ៤.១.៥. ក្រាហ្វិចរបស់មូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិក



#### ៤.១.៦. ការវិភាគទិន្នន័យ និងបកស្រាយតាមក្រាហ្វិចNCDsដែលបានចេញផ្សាយជាប្រាក់ដុល្លារអាមេរិក

NCDs ជាដុល្លារអាមេរិចត្រូវបានចេញផ្សាយប្រមាណ ១១ប៊ីលានដុល្លារអាមេរិច កើនឡើងជិត ៣ដង ធៀបនឹងឆ្នាំ២០១៥។ គិតត្រឹមឆមាសទី១ឆ្នាំ ២០១៧ NCDs ជាប្រាក់ដុល្លារបានកើនឡើងរហូតដល់ ៨៤០០ លានដុល្លារ ហើយរំពឹងថានឹងកើនឡើងរហូតដល់ ១៥៤៦៦លានដុល្លារនៅចុងឆ្នាំ២០១៧ ក្នុងនោះយោងទៅតាមការព្យាករណ៍ NCDs ជាដុល្លារអាមេរិចរំពឹងថានឹងកើនឡើង ៤៥% ។

ក្នុងគោលដៅជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងដើម្បីបន្តអភិវឌ្ឍ NCDs ឲ្យក្លាយជាឧបករណ៍គ្រប់គ្រងសន្ទនីយភាពកាន់តែមានប្រសិទ្ធភាពសម្រាប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុចេញផ្សាយតែមយយថ្ងៃក្នុងមួយសប្តាហ៍ជំនួសវិញ និងកែប្រែប្រសិទ្ធភាពនៃការទូទាត់ NCDs ពីការទូទាត់ក្នុង (T+0) មកការទូទាត់នៅថ្ងៃបន្ទាប់ (T+1) ដើម្បីឲ្យកាលវិភាគនៃការចេញផ្សាយ NCDs ស្របនឹងកាលវិភាគនៃការធ្វើប្រតិបត្តិការ LPCO ។ NCDs ចារឹកជាប្រាក់ដុល្លារអាមេរិកមានប្រមាណ ៨,៤ ប៊ីលានដុល្លារអាមេរិក កើនឡើងជិត ១០០% ។ NCDs ចារឹកជាប្រាក់រៀលបានចេញផ្សាយប្រមាណ ៦ ទ្រីលានរៀល កើនឡើង ៣៨% ។

### ៤ .២. ទិន្នន័យនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ២០១៦-២០១៧

#### ៤.២.១.តារាងទិន្នន័យនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានាឆ្នាំ ២០១៦ ដល់ ២០១៧

| លេខរៀង | កាលបរិច្ឆេទ | ចំនួនគ្រឹះស្ថានចូលរួម | ទំហំទឹកប្រាក់ (៛) | អត្រាការប្រាក់ |
|---|---|---|---|---|
| លើកទី១ | ១៨ តុលា ២០១៦ | គ្មានទិន្នន័យ | ១២.០០០.០០០.០០០ | ៣% |
| លើកទី២ | ២២ វិច្ឆិការ ២០១៦ | ៣ | ៨.០០០.០០០.០០០ | ៣% |
| លើកទី៣ | ២០ ធ្នូ ២០១៦ | ១ | ៨.០០០.០០០.០០០ | ៣% |
| លើកទី៤ | ១៧ មករា ២០១៧ | ៣ | ៩.៤០០.០០០.០០០ | ៣% |
| លើកទី៥ | ២១ កុម្ភៈ ២០១៧ | ១ | ៨.០០០.០០០.០០០ | ៣% |
| លើកទី៦ | ២១ មីនា ២០១៧ | គ្មានអ្នកចូលរួម | គ្មាន | គ្មាន |
| លើកទី៧ | ១៨ មេសា ២០១៧ | ១ | ៨.០០០.០០០.០០០ | ៣% |
| លើកទី៨ | ២៣ ឧសភា ២០១៧ | ១ | ៤០.០០០.០០០.០០០ | ៣% |

| | | | | |
|---|---|---|---|---|
| លើកទី៩ | ២០ មិថុនា ២០១៧ | ១ | ៨.០០០.០០០.០០០ | ៣% |
| លើកទី១០ | ១៨ កក្កដា ២០១៧ | ១ | ១៦.០០០.០០០.០០០ | ៣% |

ឧបសម្ព័ន្ធ១២

## ៤.២.២.ក្រាហ្វិច នៃប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានាការធានាឆ្នាំ ២០១៦ ដល់ ២០១៧




| | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ | លើកទី៥ | លើកទី៦ | លើកទី៧ | លើកទី៨ | លើកទី៩ | លើកទី១០ |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួនគ្រឹះស្ថានចូលរួម | ០ | ៣ | ១ | ៣ | ១ | ០ | ១ | ១ | ១ | ១ |
| ទំហំទឹកប្រាក់ | ១២ | ៨ | ៨ | ៩.៤ | ៨ | ០ | ៨ | ៤០ | ៨ | ១៦ |
| អត្រាការប្រាក់ | ៣% | ៣% | ៣% | ៣% | ៣% | 0% | ៣% | ៣% | ៣% | ៣% |

*ក្រាហ្វិច: បង្ហាញពីLPCOឆ្នាំ២០១៦ដល់ឆមាសទី១ ឆ្នាំ២០១៧*

## ៤.២.៣.ការវិភាគទិន្នន័យនិងបកស្រាយប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមាន

ប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានាទើបតែមានការដេញថ្លៃ ១០ដង ដែលគិតចាប់ពីចុងឆ្នាំ ២០១៦ រហូតដល់ ឆ្នាំ ២០១៧ ។ នៅលើកទី១ នៃការដេញថ្លៃ ទំហំទឹកប្រាក់ដែលដេញបានមានចំនួន ១២ ប៊ីលានរៀល ដែលធនាគារជាតិពុំបានបង្ហាញពីទិន្នន័យគ្រឹះស្ថានចូលរួមដេញថ្លៃនោះទេ ។ ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួមដេញថ្លៃស្ថិតនៅក្នុងចន្លោះ ពី ១គ្រឹះស្ថាន រហូតដល់ ៣គ្រឹះស្ថាន ដែលទំហំទឹកប្រាក់ដេញថ្លៃស្ថិតក្នុងចន្លោះពី ៨ ប៊ីលានរៀលរហូតដល់ ៤០ ប៊ីលានរៀល ។ ការដេញថ្លៃលើកទី ៨ គឺជាការដេញថ្លៃដែលមានទំហំទឹកប្រាក់ច្រើនជាងគេបំផុត ហើយគ្រឹះស្ថានចូលរួមមានតែមួយប៉ុន្នោះ ។ នៅលើកទី១ នាខែតុលា ២០១៦ ប្រតិបត្តិការ LPCO បានផ្តល់សន្ទនីយភាពជាប្រាក់រៀល ជាមួយនឹងអត្រាការប្រាក់៣% ថេរ រហូតដល់ លើកទី១០នៃការដេញថ្លៃ ២០១៧ ។ ការដាក់អោយដំណើរការប្រតិបត្តិការ LPCO បានទទួលការគាំទ្រពី

គ្រឹះស្ថានហិរញ្ញវត្ថុប៉ុន្តែទោះជាយ៉ាងណា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលចូលរួមម្ទុងការដេញថ្លៃនៅមានកម្រិតនៅឡើយ (១ គ្រឹះស្ថានរហូត ដល់ ៣គ្រឹះស្ថាន) ដោយសារប្រតិបត្តិការនេះជាប្រតិបត្តិការថ្មីដែលប្រតិបត្តិការនេះឲ្យស្របតាមស្ថានភាពទីផ្សារ និងគោលយោបាយរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាថាសន្ទនីយភាពជាប្រាក់រៀលត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាព ។

ឥណប្រតិទានរបស់ LPCO ត្រូវបានផ្លាស់ប្តូរពី ៣ខែ ទៅ ១ឆ្នាំដើម្បីផ្តល់ឥណទានជារៀលដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដែលមានកង្វះខាតប្រាក់រៀល តាមរយៈការដេញថ្លៃ ។ ប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើងចំនួន ១០លើក ដោយបានផ្តល់សន្ទនីយភាពជាប្រាក់រៀលសរុបប្រមាណ ១១៧,៨ ប៊ីលានរៀលជាមួយនឹងអត្រាការប្រាក់៣%ថេរ និងមានគ្រឹះស្ថានធនាគារចូលរួមចំនួន ១២ ។ ការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលបានធ្វើអោយប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែច្រើនក្នុងសកម្មភាពអាជីវកម្ម និងជីវភាពប្រចាំថ្ងៃ ។ ឆ្លើយតបនឹងកំនើនតម្រូវការនេះ និងដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ តាមរយៈការលក់ប្រាក់រៀលដល់ទីផ្សារប្រមាណ ៨៩,៥ទ្រីលានរៀល កើនឡើងជាង ៣ដងធៀបនឹងឆ្នាំមុន ។ គួរគត់សម្គាល់ថា ស្ថិតក្នុងបរិការណ៍នៃសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ អន្តរាគមន៍លើទីផ្សារប្តូរប្រាក់មានសារៈសំខាន់ណាស់សម្រាប់ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ដើម្បីរួមចំណែកក្នុងការរក្សាស្ថិរភាពថ្លៃ ។ លើសពីនេះ អន្តរាគមន៍នេះ បានផ្តល់សន្ទនីយភាពជារៀលដល់គ្រឹះស្ថាន ធនាគារ និងមីក្រូហិរញ្ញវត្ថុសម្រាប់ធ្វើប្រតិបត្តិការប្រចាំថ្ងៃជាពិសេស ការផ្តល់ឥណទានជា ប្រាក់រៀលដោយ បានស្រូបយកប្រាក់ដុល្លារអាមេរិកពីសេដ្ឋកិច្ចកម្ពុជា ។

## ៤.៣. **ការវិភាគទៅលើ** SWOT

### ៤.៣.១.ចំណុចខ្លាំង

ទោះបីជាការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិតតែ ការអនុវត្តគន្លងមកបានបង្ហាញពីផលវិជ្ជមានមួយចំនួនផងដែល ។ ការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុ ជាមួយនឹងឧបករណ៍គោលនយោបាយរូបិយវត្ថុបានបង្ហាពីចំនុចខ្លាំងដូចខាងក្រោម៖

- ការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាប ក្នុងអត្រា មធ្យមប្រចាំឆ្នាំតិចជាង ៥ %ដែលសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍

- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីបុគ្គលិកដោយផ្តល់អាហារូបករណ៍រៀនក្រៅ ប្រទេសដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ក្នុងវិស័យធនាគារ
- ធនាគារជាតិ នៃ កម្ពុជាផ្តល់អនុសាសន៍ចំពោះធនាគារសាមី ដើម្បីកែតម្រូវ និងចាត់វិធានការដោះស្រាយបញ្ហាតាមស្ថានភាពជាក់ស្តែង
- ធនាគារជាតិ នៃ កម្ពុជានូវតែបន្តអន្តរាគមន៍លើទីផ្សារប្តូរប្រាក់
- ធនាគារជាតិ នៃ កម្ពុជាបានបង្កើតឧបករណ៍រូបិយវត្ថុស្របតាមស្ថានភាពសេដ្ឋកិច្ច
- ធនាគារជាតិ នៃ កម្ពុជាបន្តពង្រឹងនូវការប្រើប្រាស់ប្រាក់រៀល ។

### ៤.៣.២. ចំណុចខ្សោយ

ផ្ទុយជាមួយនឹងចំនុចខ្លាំងរបស់គោលនយោបាយរូបិយវត្ថុ លទ្ធផលនៃការអនុវត្តគោលនយោបាយរូបិយវត្ថុក៏បង្ហាញពីផលអវិជ្ជមានផងដែល ។ ចំណុចខ្សោយទាំងនោះរួមមានៈ

- ការអនុវត្តឧបករណ៍រូបិយវត្ថុនៅមានកម្រិត
- បរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយ
- ធនាគារជាតិនៃកម្ពុជាពុំមាន លទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ
- ទំនុកចិត្តរបស់ប្រជាជនក្នុងការប្រើប្រាស់រៀលនៅមានកម្រិត
- ការគ្រប់គ្រងរូបិយប័ណ្ណបរទេសនៅមានកំម្រិត ។

### ៤.៣.៣. ឱកាស

ធនាគារជាតិ នៃ កម្ពុជានៅតែបន្តធ្វើបដិដុល្លារូបនីយកម្ម និងប្រើយុទ្ធសាស្ត្រលើកកម្ពស់ប្រាក់រៀល ដោយបង្កើតនូវឧបករណ៍គោនយោបាយរូបិយថ្មីៗ ដើម្បីពង្រឹងនូវជំនឿរទុកចិត្តដល់សាធារណជន។ រដ្ឋាភិបាលបានពង្រឹងទៅលើៈ

- គោនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់
- គោនយោបាយសារពើពន្ធ
- គោនយោបាយពាណិជ្ជកម្ម
- គោនយោបាយហិរញ្ញវត្ថុ និងក្របខណ្ឌបទបញ្ញត្តិប្រុងប្រយ័ត្ន
- គោនយោបាយអភិវឌ្ឍទីផ្សារ
- ការអភិវឌ្ឍប្រព័ន្ធទូទាត់
- ការលើកកម្ពស់ការយល់ដឹង និងការចូលរួម

- កិច្ចសហប្រតិបត្តិការដើម្បីអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព
- គោលនយោបាយគាំទ្រនានា ។

### ៤.៣.៤. ការគាំរាមគំហែង

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមដែលអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំកម្ពុជាបានធ្លាក់ក្នុងអស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចដែលធ្វើឲ្យសាធារណជនបាត់បង់ជំនឿទុកចិត្តលើរដ្ឋាភិបាល សេដ្ឋកិច្ច និងរូបិយវត្ថុជាតិ ។ គួកត់សម្គាល់ថា នៅក្នុងសម័យ លន់ ណុលប្រាក់ដុល្លាអាមេរិចហូរចូលកាន់តែច្រើនតាមរយៈជំនួយអាមេរិក ហើយរក្សាទុក និងប្រើប្រាស់ដុល្លារអាមេរិក ។ លើលពីនេះ រូបិយវត្ថុជាតិត្រូវបានបាត់បងទាំងស្រុងក្នុងសម័យ ប៉ុល ពត (១៩៧៥-១៩៧៩) ។ សង្គមទាំងមូលក្លាយជាសង្គមទេសភាព គ្មានកម្មសិទ្ធឯកជន គ្មានទីផ្សា គ្មានរូបិយវត្ថុ និងគ្មានសេរីភាពទាំងអស់។ បទពិសោធន៍ដ៏ខ្លោចផ្សាទាំងនេះ គឺជាឬសគល់ចម្បងនៃការបាត់បង ជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិ និងមានដុល្លាររូបនីយកម្ម ដែលជាហេតុធ្វើឲ្យការអនុវត្តន៍គោលនោបាយរូបិយវត្ថុនូវមានកម្រិត៕

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលពីមន្ត្រី និងបុគ្គជំនាញរបស់ធនាគារជាតិ នៃ កម្ពុជា យើងខ្ញុំសូមអគុណដល់មន្ត្រី និងបុគ្គលិកជំនាញ ដែលបានស្វាគមន៍ទទួលសិស្សនិស្សិតឲ្យ ចុះកម្មសិក្សាដោយសេចក្តីរីករាយ ហើយបានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការចែករំលែកបទពិសោធន៍ទាក់ទងទៅនឹងការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ នៃ កម្ពុជា ក្នុងកំឡុងពេលចុះកម្មសិក្សា យើងខ្ញុំទទួលបានបទពិសោធន៍ និងចំណេះដឹងជាច្រើនលើប្រធានបទ "ការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុ។ ធនាគារជាតិនៃកម្ពុជាបានដឹក "ដឹកនាំគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថេរភាពថ្លៃដើម្បីរួមចំណែកជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃ ព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត ធនាគារជាតិនៃកម្ពុជា ខិតខំធ្វើបរិដុល្លារូបនីយកម្ម ដោយបង្កើតឧបករណ៍ថ្មីឡើងដើម្បីបង្កើននូវជំនឿទុកចិត្តដល់ប្រជាជន និងរវាងធនាគារ និងធនាគារដែលហៅថាអន្តរធនាគារ ដែលបានបាត់បង់នូវជំនឿទុកចិត្តនូវក្រោយសង្គ្រាម។ ធនាគារជាតិនៃកម្ពុជា នៅតែរិះរកនូវឧបករណ៍ថ្មីៗទៀត ដែលសមស្របទៅនឹងបរិបទនៃសង្គម ហើយបន្តអនុវត្តឧបករណ៍ចាស់ៗឲ្យមានប្រសិទ្ធភាព ដើម្បីជំរុញនូវការអនុវត្តន៍គោលនយោបាយរូបិយវត្ថុដើម្បីឆ្លើយតបនឹងការរីកចម្រើន។ ជាងនេះទៅទៀតធនាគារកណ្តាលកំពុងតែពង្រឹងនូវឧបករណ៍ថ្មីមានដូចជា NCD និង LPCO ឲ្យកាន់តែមានប្រសិទ្ធភាព ក្នុងការស្រូប និងបញ្ចេញប្រាក់រៀល។

សរុបមកធនាគារជាតិ នៃ កម្ពុជាកំពុងអភិវឌ្ឍន៍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សារ រូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល ។ល។

## ការផ្តល់អនុសាសន៍

ក្រោយពីបានសិក្សា ស្រាវជ្រាវពីគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ នៃ កម្ពុជា ឧបករណ៍រូបិយវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា។ ធនាគារកណ្តាលបានបើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយសារតែដុល្លារូបនីយកម្មនៅកម្ពុជានៅមានកម្រិតខ្ពស់ ដែលជាបញ្ហាប្រឈមចម្បងចំពោះការអនុវត្ត

គោលនយោបាយរូបិយវត្ថុនៅកម្ពុជា ។ ដូច្នេះ ដើម្បីជាជំនួយជាស្មារតីក្នុងការកែលំអចំនុចខ្វះខាតលើឧបករណ៍រូបិយវត្ថុ យើងខ្ញុំសុំផ្តល់អនុសាសន៍ដូចតទៅះ

- សហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ចូលកម្មវិធីសិក្សាទាក់ទងការពង្រឹងប្រាក់រៀល
- ផ្សព្វផ្សាយពីសារៈសំខាន់នៃអត្ថប្រយោជន៍ប្រាក់រៀលនៅតាមសាលាបឋមដល់វិទ្យាល័យ
- បើកសិក្ខាសាលា ក្នុងការពង្រឹងប្រាក់រៀល
- ចេញសារាចរណែនាំ នៅក្នុងទីផ្សា ក្នុងការទិញ-លក់ជាប្រាក់រៀល
- លើកទឹកចិត្តវិស័យឯកជន ឲ្យកំណត់ថ្លៃទំនិញ និងសេវា និងការបើកប្រាក់បៀវត្សរ៍ឲ្យនិយោជិកជាប្រាក់រៀល៕

# ឯកសារយោង

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


១. របាយការណ៍ប្រចាំមាស និងប្រចាំឆ្នាំ (២០១៦ នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ) របស់ធនាគារជាតិនៃកម្ពុជា

២. ទិន្នន័យស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ (២០១៥ ដល់ ២០១៦ នាយកដ្ឋានស្ថិតិ) របស់ធនាគារជាតិនៃកម្ពុជា

៣. ទិន្នន័យស្ថិតិជញ្ជីងទូទាត់ ឆ្នាំ (២០១៥ ដល់ ឆ្នាំ ២០១៦) របស់ធនាគារនៃកម្ពុជា

៤. ឯកសារនៅបណ្ណាល័យរបស់ធនាគារជាតិនៃកម្ពុជា

៥. ឯកសារនៅបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

៦. ព្រឹត្តិបត្រប្រចាំត្រីមាស ត្រីមាសទី៤ លេខ៤៩ ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា

៧. ព្រឹត្តិបត្រប្រចាំត្រីមាស ត្រីមាសទី៣ លេខ៤៨ ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា


## ឯកសារជាភាសាបរទេស


៨. History of the Bank of United States of American - Bank of U.S.

៩. Money Market Operation in FY2001 in July 2002 by Financial Markets Department Bank of Japan

១០. BOJ reports and Research Papers –Result of the Tokyo Money Market Survey (August 2012) by Financial Markets Department Bank of Japan

១១. Comprehensive Assessment: Developments in Economic Activity and Prices as well as Policy Effects since the Introduction of Quantitative and Qualitative Monetary Easing (QQE) (September 21, 2016) by Bank of Japan

១២. Monetary policy and central Banking by IMF of April 2017

១៣. "Commercial Bank Loans and the Money Supply" (November 1976) by Cacy, J. A.

១៤. "A Brief History of Central Banking in the United States"(2003-03-06) Flaherty, Edward Department of Humanities Computing. Retrieved 2008-02-01.

### ឯកសារដកស្រង់ចេញពីគេហទំព័រ


១៥. https://www.bankofamerica.com

១៦. https://www.boj.or.jp

១៧. https://www.nbc.org.kh

១៨. http://www.mef.gov.kh

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

**EXPRESSION OF INTEREST TO BECOME A REVERSE REPURCHASE AGREEMENT TRANSACTION COUNTERPARTY – BANKS and SAVINGS ASSOCIATIONS**

**By submitting these materials, you agree that you will not advertise or include in promotional material or business discussions with any third parties or customers, other than to supervisory or regulatory authorities or as otherwise required by law, your interest in becoming a reverse repo counterparty or the fact that you have submitted these materials to FRBNY and are under consideration to become a reverse repo counterparty.**

| | |
|---|---|
| Legal Name & Address of Firm | Name:<br>Address: |
| Jurisdiction / State of Organization: | |
| Primary Business Contact: | Name:<br>Address:<br><br>Tel:<br>Email: |
| Primary Legal Contact: | Name:<br>Address:<br><br>Tel:<br>Email: |
| Primary Regulator & Contact at Primary Regulator of the Firm: | Regulator:<br>Name:<br>Address:<br><br>Tel:<br>Email: |
| Is the firm eligible to earn interest on balances maintained at the Federal Reserve Banks? | YES<br>NO |
| Does the Firm have total assets of no less than $30 billion, **or** does the Firm have reserve balances of no less than $10 billion on the last quarter for which the relevant reports are available[1]? (State the amount) | YES Assets:<br>Reserve Balance: $<br>NO |
| Is the Firm set-up to operate in the tri-party repo market? | YES<br>NO |
| Is the Firm able to execute RRP with securities margined at 100% (i.e. the value of the securities provided by FRBNY will equal the funds provided by the counterparty) | YES<br>NO |

[1] FFIEC form 031 for domestic banks, FFIEC form 002 for U.S. branches and agencies of foreign banks, Thrift Financial Report for savings associations.

# ឧបសម្ព័ន្ធ២


ទេសាភិបាល
អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
(ស.ហ.ក)
ទេសាភិបាលរង
សមាជិកក្រុមប្រឹក្សាភិបាល១.ទេសាភិបាល
២.ទេសាភិបាលរង
៣.តំណាងប្រមុខរាជរដ្ឋាភិបាល
៤.តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៥.តំណាងមជ្ឈដ្ឋានឧត្តមសិក្សា
៦.តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច
៧.តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា
ទីប្រឹក្សា
អគ្គលេខាធិការដ្ឋាន
ខុទ្ទកាល័យ
នាយកដ្ឋានគណនេយ្យ
នាយកដ្ឋានគ្រប់គ្រង
មណ្ឌលសិក្សាបច្ចេកទេស
នាយកដ្ឋានព័ត៌វិទ្យា
នាយកដ្ឋានគតិយុត្ត
សាខាពជធនាគារជាតិ
អគ្គលេខាធិការដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិ
នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិង
សហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានស្ថិតិ
នាយកដ្ឋានប្រព័ន្ធទូទាត់សង
អគ្គនាយកដ្ឋានត្រួតពិនិត្យ
នាយកដ្ឋាននីតិកម្ម
នាយកដ្ឋានអាជ្ញាប័ណ្ណ
នាយកដ្ឋានត្រួតពិនិត្យដល់
ទីកន្លែង
នាយកដ្ឋានត្រួតពិនិត្យលើ
ឯកសារ
អគ្គាធិការដ្ឋាន
នាយកដ្ឋានអធិការ
កិច
នាយកដ្ឋានសាវនកម្ម
ផ្ទៃក្នុង
អគ្គបេឡា
នាយកដ្ឋានបោះផ្សាយនិង
ឃ្លាំងបេឡា
នាយកដ្ឋានជាងពុម្ព

# ឧបសម្ព័ន្ធ៣



ប្រធាន

**ឯកឧត្តម ជា ចាន់តូ**

អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា



**លោកជំទាវ នាវ ច័ន្ទថាណា**

ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា



**ឯកឧត្តម ជូ គឹមឡេង**

តំណាងប្រមុខរាជរដ្ឋាភិបាល



**ឯកឧត្តម រស់ សីលវ៉ា**

តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម អ៊ីវ ចុង**

តំណាងមជ្ឈដ្ឋានឧត្តមសិក្សា



**លោក ឡាយ ម៉េងស៊ុន**

តំណាងមជ្ឈដ្ឋានធ្វើ សកម្មភាពសេដ្ឋកិច្ច



**អ្នកស្រី មៅ សុន**

តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា

# ឧបសម្ព័ន្ធ៤

ធ៥-០១០-១៨៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា

## សម្រេច

### ប្រការ ១.- គោលបំណង

ធនាគារជាតិនៃកម្ពុជាចេញផ្សាយមូលបត្រអាចជួញដូរបានក្នុងគោលបំណងដូចខាងក្រោម ៖

- ជម្រុញការអភិវឌ្ឍទីផ្សាររូបិយវត្ថុ និងការផ្តល់ឥណទានអន្តរធនាគារ ផ្អែកលើមូលដ្ឋានសុវត្ថិភាព ដោយមូលបត្រដែលត្រូវបានចេញផ្សាយអាចយកមកប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់ប្រតិបត្តិការទទួលទិញវិញ(Repo)។
- ផ្តល់ឱ្យអ្នកចូលរួមក្នុងទីផ្សារនូវជម្រើសទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលមួយទៀតបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិនៃកម្ពុជា និងបង្កើតឧបករណ៍បន្ថែមក្នុងគោលដៅជួយគាំទ្រដល់ដំណើរការអនុវត្តគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់របស់ធនាគារជាតិ នៃកម្ពុជា។

នៅពេលមានការស្នើសុំពីអ្នកកាន់មូលបត្រនឹងអាចត្រូវផ្ទេរទៅឱ្យអ្នកចូលរួមក្នុងទីផ្សារណាមួយផ្សេងទៀតបាន លុះត្រាតែអ្នកទទួលមូលបត្របានបើកគណនីបញ្ញើសាច់ប្រាក់ និងគណនីបញ្ញើមូលបត្រនៅធនាគារជាតិនៃកម្ពុជាដែលមានតួនាទីជាអ្នកថែរក្សាមូលបត្រដែលខ្លួនបានចេញផ្សាយ។

### ប្រការ ២ .- លក្ខណៈនិងប្រភេទមូលបត្រដែលបានចេញផ្សាយ

១- មូលបត្រនឹងត្រូវបានចេញផ្សាយតាមសំណើរបស់អ្នកទិញ ដូចជាប្រាក់បញ្ញើមានកាលកំណត់ដែលដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជាដែរ។ មូលបត្រដែលបានចេញផ្សាយ នឹងទទួលបានអត្រាការប្រាក់ថេរដែលកំណត់ដោយធនាគារជាតិនៃកម្ពុជានៅពេលមានការបញ្ជាទិញ។ ការប្រាក់នឹងត្រូវបានបង្គរតាមមូលដ្ឋានចំនួនថ្ងៃជាក់ស្តែងនៃឆ្នាំនីមួយៗ។ គូប៉ុង (Coupon) ដែលត្រូវបានគិតបង្គរតាមអាយុកាលនៃមូលបត្រនឹងត្រូវបានទូទាត់សងរួមគ្នាជាមួយតម្លៃចារឹករបស់មូលបត្រនៅកាលវសានទៅឱ្យអ្នកកាន់មូលបត្រ ដូចបានកំណត់ក្នុងប្រការ ៦.២ នៃប្រកាសនេះ។

២- មូលបត្រ ត្រូវបានចេញផ្សាយជាអរូបិយ (Dematerialize) ដូច្នេះត្រូវតែបានដាក់ផ្ញើក្នុងគណនីបញ្ញើមូលបត្រដែលបើកដោយអ្នកទិញនៅធនាគារជាតិនៃកម្ពុជា មុនពេលបញ្ជាទិញ។ គំរូហត្ថលេខាអ្នកមានសិទ្ធិសម្រាប់ការទិញ និងការផ្ទេរមូលបត្រត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា។

៣- ការទិញនឹងត្រូវបានបញ្ជាក់ដោយធនាគារជាតិនៃកម្ពុជា។ ការកាន់កាប់មូលបត្រនេះ ត្រូវបានបង្ហាញដោយទៀងទាត់ផងដែរនៅក្នុងរបាយការណ៍គណនីមូលបត្រ។

៤- មូលបត្ររបស់ធនាគារជាតិនៃកម្ពុជា នឹងត្រូវបានចេញផ្សាយជារូបិយវត្ថុជាតិ និងជារូបិយប័ណ្ណ។ មូលបត្រទាំងនេះ នឹងត្រូវបានសម្គាល់ដោយលេខមាលាមូលបត្រ និងលេខសម្គាល់អត្តសញ្ញាណនៅក្នុងលេខមាលានេះមានដូចជា តម្លៃចារឹក រូបិយប័ណ្ណ អត្រាការប្រាក់ និងកាលវសាន្ត។

៥- មូលបត្រចារឹកជារូបិយវត្ថុជាតិមានកាលវសាន្តៈ ២សប្តាហ៍ ១ខែ ២ខែ ៣ខែ ៦ខែ ៩ខែ និង១ឆ្នាំ។ មូលបត្រដែលចារឹកជារូបិយប័ណ្ណ មានកាលវសាន្តៈ ២សប្តាហ៍ ១ខែ ២ខែ ៣ខែ និង៦ខែ។ ធនាគារជាតិនៃកម្ពុជានឹងកំណត់តម្លៃចារឹកនៃមូលបត្រនៅពេលចេញផ្សាយ។

## ប្រការ ៣ .- ការថែរក្សា និងការចុះបញ្ជីមូលបត្រ

១- ដូចបានចែងក្នុងប្រការ២ កថាខណ្ឌ២ ខាងលើ មូលបត្រត្រូវចេញផ្សាយជាអរូបិយ (Dematerialize)។ មូលបត្រទាំងនេះ ចាំបាច់ត្រូវដាក់ផ្ញើក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

២- បែបបទនៃការចុះបញ្ជី និងការផ្ទេរកម្មសិទ្ធិមូលបត្រត្រូវធ្វើដោយធនាគារជាតិនៃកម្ពុជា។

## ប្រការ ៤ .- ម្ចាស់កម្មសិទ្ធិលើមូលបត្រ

១- កម្មសិទ្ធិលើមូលបត្រអរូបិយ (Dematerialize) ត្រូវបានបញ្ជាក់ជាភស្តុតាងដោយការធ្វើលេខាចារឹកដោយទៀងទាត់នៅក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកចេញផ្សាយ និងជាអ្នកថែរក្សាមូលបត្រ។

ដូច្នេះ រាល់ការផ្លាស់ប្តូរកម្មសិទ្ធិចាំបាច់ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីបញ្ជាក់លើការផ្ទេរកម្មសិទ្ធិនេះឱ្យទៅអ្នកលក់និងអ្នកទិញមូលបត្រ។

២- ការបញ្ជាក់របស់ធនាគារជាតិនៃកម្ពុជា ទៅឱ្យអ្នកទិញតែម្ខាងមិនមែននិងមិនអាចចាត់ទុកជាប័ណ្ណសម្គាល់កម្មសិទ្ធិអាចជួញដូរបាននោះទេ និងដូចនេះអ្នកចូលរួមក្នុងទីផ្សារ មិនអាចធ្វើបិដ្ឋិលេខដើម្បីផ្ទេរកម្មសិទ្ធិមូលបត្រទាំងនោះបានឡើយ។

ការផ្ទេរកម្មសិទ្ធិនេះ អាចធ្វើឡើងស្របច្បាប់បានលុះត្រាតែធនាគារជាតិនៃកម្ពុជា ទទួលបានបញ្ជាពីភាគីទាំងពីរ ក្នុងការធ្វើប្រតិបត្តិការទិញ-លក់ផ្តាច់ ឬប្រតិបត្តិការដាក់វត្ថុធានា ជាពិសេសក្នុងទម្រង់ជាប្រតិបត្តិការទទួលទិញវិញ ឬដាក់បញ្ចាំជាវត្ថុធានាតែប៉ុណ្ណោះ។

**ប្រការ ៥ .- ប្រតិបត្តិការទទួលទិញវិញ** (Repo)

១- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានទទួលយកសម្រាប់ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ។ ក៏ប៉ុន្តែ ដើម្បីធានាសុវត្ថិភាពតាមកិច្ចសន្យា និងតាមផ្លូវច្បាប់សម្រាប់ប្រតិបត្តិការទាំងនោះ អ្នកចូលរួមក្នុងទីផ្សារទាំងឡាយ ត្រូវតែចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា។

២- ជាគោលការណ៍ ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ ត្រូវរួមបញ្ចូលនូវដំណាក់កាលពេញលេញដែលអនុវត្តដោយភាគីទាំងពីរ ក្នុងការបញ្ជាមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិនៃមូលបត្រ ដែលបានលក់ក្រោមកិច្ចសន្យាទទួលទិញវិញ។

៣- ចំពោះប្រតិបត្តិការដែលមានរយៈពេលខ្លី ភាគីនៃកិច្ចសន្យាអាចមិនចាំបាច់បញ្ជាមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិមូលបត្រដែលបានលក់ក្រោមកិច្ចសន្យាទទួលទិញវិញនោះឡើយ។ ក្នុងករណីនេះ អ្នកលក់មូលបត្រ (ភាគីខ្ចីប្រាក់) ត្រូវតែដើរតួជាអ្នកថែរក្សាមូលបត្របន្ទាប់ឱ្យអ្នកទិញមូលបត្រ (ភាគីឱ្យខ្ចីប្រាក់) និងចុះបញ្ជិកាគណនេយ្យជាបន្តបន្ទាប់ដើម្បីជាភស្តុតាងនៃការផ្ទេរកម្មសិទ្ធិ។

៤- ប្រតិបត្តិការទទួលទិញវិញអាចធ្វើបានដោយប្រើរូបិយប័ណ្ណខុសៗគ្នា យោងតាមកិច្ចសន្យាទ្វេភាគីរបស់ភាគីទាំងពីរ។ ក្នុងករណីនេះ ភាគីខ្ចីប្រាក់ជាអ្នកទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់ (អ្នកលក់មូលបត្រសន្យាថានឹងទិញមូលបត្រវិញតាមតម្លៃដែលបានព្រមព្រៀងទុកជាមុន)។ លើសពីនេះ ភាគីដែលទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញ និងទទួលបន្ថែមម៉ាជីនខលសាច់ប្រាក់ (Cash Margin Calls) ប្រសិនបើចាំបាច់។

**ប្រការ ៦ .- ការបញ្ជាក់ និងការបញ្ជាផ្ទេរ**

១- ការបញ្ជាក់លើការទិញ ដោយធនាគារជាតិនៃកម្ពុជា មិនរួមបញ្ចូលកម្មសិទ្ធិភាពលើមូលបត្រ ដែលបានទិញនោះទេ។ ដូច្នេះការបញ្ជាក់នេះ មិនអាចចាត់ទុកជាវិញ្ញាបនបត្រ ដែលអាចធ្វើបិដ្ឋិលេខដោយអ្នកចូលរួមទីផ្សារ ព្រោះថាការធ្វើបិដ្ឋិលេខនោះនឹងមិនរួមបញ្ចូលសិទ្ធិកាន់កាប់លើមូលបត្រនោះឡើយ។

២- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ជាមូលបត្រអរូបិយ (Dematerialize) ភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រ គឺជាលទ្ធផលនៃការធ្វើលេខាចារឹកដោយទៀងទាត់លើមូលបត្រទាំងនោះនៅក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ នៅកាលវសាន្ត តម្លៃចារឹកនៃមូលបត្រ និងគូប៉ុងដែលបានបង្គរ ត្រូវបានផ្ទេរដោយស្វ័យប្រវត្តិ ចូលក្នុងគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា ដែលពាក់ព័ន្ធជាមួយគណនីបញ្ញើមូលបត្រនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកចូលរួមទីផ្សារមានបំណងវិនិយោគឡើងវិញនូវ

ចំនួនប្រាក់ទាំងអស់ ឬមួយផ្នែកនៃចំនួនប្រាក់ដែលបានទទួលអ្នកចូលរួមនោះត្រូវផ្តល់បញ្ជាទៅធនាគារជាតិនៃកម្ពុជាឱ្យបានមុនកាលវសាន្តចំនួនពីរថ្ងៃនៃថ្ងៃធ្វើការ។

៣- នៅពេលចេញផ្សាយមូលបត្រ ក្រោយពីទទួលបានបញ្ជាទិញជាលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខាដោយអ្នកទទួលសិទ្ធិ ធនាគារជាតិនៃកម្ពុជានឹងចុះឥណពន្ធក្នុងគណនីចរន្តដោយស្វ័យប្រវត្តិនិងចុះឥណទានគណនីបញ្ញើមូលបត្រដែលពាក់ព័ន្ធរបស់អ្នកកាន់កាប់មូលបត្រ នៅថ្ងៃប្រសិទ្ធិភាពដែលកំណត់នៅលើបញ្ជាទិញ។ អ្នកទិញ និងអ្នកចូលរួមដេញថ្លៃត្រូវធានាថា មានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់នៅក្នុងគណនីដើម្បីទូទាត់សងថ្លៃមូលបត្រដែលបានទិញ ឬដេញថ្លៃបាន។

៤- ដើម្បីអនុវត្តការផ្ទេរកម្មសិទ្ធិមូលបត្រដែលត្រូវបានលក់និងទិញយកវិញ តាមរយៈប្រតិបត្តិការទទួលទិញវិញ ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យភាគីទាំងពីរបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរដោយឡែកពីគ្នាទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនោះ។ ដើម្បីជៀសវាងការយឺតយ៉ាវ ភាគីទាំងពីរត្រូវធ្វើការបញ្ជាក់ឱ្យគ្នាទៅវិញទៅមកនូវបញ្ជារបស់ខ្លួន ហើយត្រូវធានាថា ការបញ្ជាក់ទាំងនោះមានខ្លឹមសារស្របគ្នាទាំងស្រុង។

៥- ក្នុងដំណើរការនៃប្រតិបត្តិការទទួលទិញវិញ ទោះបីភាគីទាំងពីរយល់ព្រមទូទាត់ម៉ាជីនជាសាច់ប្រាក់ ឬដាក់បន្ថែមម៉ាជីនជាមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរ ដែលមានខ្លឹមសារស្របគ្នាទៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមបទប្បញ្ញត្តិ ដែលបានចែងក្នុងកថាខណ្ឌទី ៤ ខាងលើ។

៦- ទោះបីជាភាគីទាំងពីរសម្រេចចិត្តទិញលក់ផ្តាច់ជាមួយគ្នានូវមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាទៅធនាគារជាតិនៃកម្ពុជា ទាំងការផ្ទេរមូលបត្រដែលបានទិញ ឬលក់ នោះផង និងការទូទាត់សាច់ប្រាក់ដោយបញ្ជាក់អំពីថ្ងៃប្រសិទ្ធភាព និងចំនួនប្រាក់ដែលត្រូវបានទូទាត់សងផងដែរ។ ចរិតលក្ខណៈនៃមូលបត្រដែលត្រូវបានទិញ ឬលក់ ត្រូវតែបានបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរឱ្យច្បាស់លាស់ដោយភាគីទាំងពីរនៅលើប្រតិបត្តិការដែលបានធ្វើ។

### ប្រការ ៧ .- ឥណទានអូវើណាយដែលមានការធានា និងឪសខោនទិនដូ

**(Overnight Secured Facilities and Discount Window)**

១- ក្រោមលក្ខខណ្ឌដែលនឹងត្រូវមានចែងក្នុងប្រកាសដោយឡែករបស់ធនាគារជាតិនៃកម្ពុជា មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានប្រើប្រាស់ជាវត្ថុធានាសម្រាប់ការផ្តល់ឥណទានអូវើណាយ (Overnight) ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ឱ្យអ្នកចូលរួមទីផ្សារក្នុងការបំពេញសមតុល្យផាត់ទាត់អវិជ្ជមានរបស់ខ្លួនរយៈពេលមួយថ្ងៃ។ ឥណទាននេះ មិនត្រូវបានចាត់ទុកជាប្រភពទុនអចិន្ត្រៃយ៍របស់សមាជិកសភាផាត់ទាត់ឡើយ ហើយធនាគារជាតិនៃកម្ពុជានឹងផ្តល់ឥណទាននេះតាមអត្រាការប្រាក់ជាកពិន័យ។



២- ឥណទានអូវើណាយ (Overnight) ត្រូវបានធានាដោយមូលបត្រកាន់កាប់ដោយសមាជិកសភាផាត់ទាត់តាមតម្លៃចារីកសមមូល ឬខ្ពស់ជាងកំរិតឥណទាន។ ធនាគារជាតិនៃកម្ពុជា នឹងផ្ទេរកម្មសិទ្ធិនៃវត្ថុធានាក្រោយពីបញ្ជាក់អំពីការផ្តល់ឥណទានអូវើណាយ (Overnight) នោះដល់អត្ថគាហក។ ធនាគារជាតិនៃកម្ពុជានឹងសងមូលបត្រត្រឡប់វិញនៅថ្ងៃបន្ទាប់ក្រោយពីគណនីផាត់ទាត់មានសមតុល្យវិជ្ជមានឡើងវិញ។

ដំណឹងស្តីពីការដេញថ្លៃនីមួយៗ ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជារួមជាមួយនឹងព័ត៌មានផ្សេងៗទៀតដែលចាំបាច់ ឬសមស្របសម្រាប់ការរៀបចំខ្លួន និងការដាក់ពាក្យសុំចូលដេញថ្លៃ។

## ប្រការ ១០.-ការប្រើប្រាស់មូលបត្ររបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ជាវត្ថុធានាក្នុងប្រតិបត្តិការការទូទាត់ដុលតាមពេលវេលាពិត (RTGS)

# ឧបសម្ព័ន្ធ៥

Institution Letter Head

Form NBC CD 01

# ពាក្យសុំបើកគណនីបញ្ញើមូលបត្រ

APPLICATION FOR OPENING A CUSTODIAN ACCOUNT

## សូមគោរពជូន

## ប្រធាននាយកដ្ឋានប្រតិបត្តិការ

To: Director of Banking Operation Department

យើងខ្ញុំស្នើសុំបើកគណនីបញ្ញើមូលបត្រ តាមមានព័ត៌មានលំអិតខាងក្រោម /We request to open a custodian account with the following details:

- **ឈ្មោះអង្គភាពបើកគណនី**/Organization's name: ......................................................................................................................................
- **អាសយដ្ឋាន**/Address: ......................................................................................................................................

......................................................................................................................................

- **លេខទូរស័ព្ទទំនាក់ទំនង**/Telephone: ..................................................................... **ទូរសារ**/Fax ..........................................
- **ប្រភេទរូបិយវត្ថុ**/Type of currency: ☐ **រៀល/KHR** ☐ **ដុល្លារ**/USD
- **ឈ្មោះគណនី**/Account name: ......................................................................................................................................
- **នីតិវិធីនៃការប្រើប្រាស់គណនី**/Procedure for using the A/c:

......................................................................................................................................

- **ឈ្មោះភ្នាក់ងារទំនាក់ទំនង**/Contact person: ........................................................ **មុខងារ**/Position : ..........................

  **ទូរស័ព្ទ**/Phone: ........................................ **អាសយដ្ឋានសារអេឡិចត្រូនិក**/Email : ..........................
- **លេខគណនីចរន្ត**/Current account number: ☐ **រៀល**/KHR ......................................................................

  ☐ **ដុល្លារ**/USD......................................................................

- **ឯកសារភ្ជាប់**/Attachment: ☐ **លក្ខន្តិកៈ**/ Article Agreement

  ☐ **អាជ្ញាប័ណ្ណ**/License

  ☐ **អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន**/Nation I.D or Passport

យើងខ្ញុំសូមប្រតិបត្តិយ៉ាងត្រឹមត្រូវតាមលក្ខខណ្ឌស្តីពីការបើក និងប្រើប្រាស់គណនី ព្រមទាំងច្បាប់និងបទបញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងការចេញផ្សាយមូលបត្រដែលអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជានេះ /We agree to operate duly in accordance with the terms and conditions for opening and using the account and to abide by the laws and regulations relating to the issuing of NBC Tradable Securities.

**ថ្ងៃ**/Date............**ខែ**/Month.........**ឆ្នាំ**/Year....................

**ម្ចាស់គណនី**/Account holder

# ឧបសម្ព័ន្ធ៦

*Institution Letter Head* Form NBC CD. 002

**ពាក្យសុំជាវមូលបត្រអាចជួញដូរបាន**

SUBSCRIPTION FOR TRADABLE SECURITIES

**សូមគោរពជូន**

# ឧបសម្ព័ន្ធ៧

Form NBC-NCD. 005

*Bank letter head and logo*

# ពាក្យសុំផ្ទេរកម្មសិទ្ធិមូលបត្រអាចជួញដូរបាន

APPLICATION FOR OWNERSHIP TRANSFER OF THE TRADABLE SECURITIES

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា**

To: Director of the Banking Operation Department, National Bank of Cambodia

ផ្អែកលើលទ្ធផលនៃប្រតិបត្តិការ.... (□□□□ ដាក់បញ្ចាំ លក់ផ្តាច់) រវាងភាគី... និងភាគី ... យើងខ្ញុំមានកិត្តិយសសូមជម្រាបជូនលោក/លោកស្រីមេត្តាជ្រាបថា មូលបត្រអាចជួញដូរបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ដែលមានលក្ខណៈលំអិតដូចមានរាយជូនក្នុងតារាងខាងក្រោម ត្រូវបានប្រគល់ជូនភាគីធនាគារ □ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

As a result of our... (Repo, Pledge as collateral, straight forward selling) transaction between the Party … and Party …, I/We have an honor to inform you that the Securities with the details below have been transferred to Party … from the signing date.

| លេខមូលបត្រ<br>Security No. | តម្លៃចារឹក<br>Face Value | កាលវសាន<br>Maturity Date | ពីគ/នីបញ្ញើមូល. លេខ<br>From Cust A/C No. | ទៅគ/នីបញ្ញើមូល.លេខ<br>To Cust. A/C No. | ចំនួនការប្រាក់<br>Int. Amount | ប្រភេទប្រតិបត្តិការ<br>Type of Tran |
|---|---|---|---|---|---|---|
| NCD/USD/14D/AA00001 | 5000000 | 12 DEC 2014 | 00102000001 | 00102000003 | 1000000 | SALE |
| NCD/USD/14D/AA0002 | 3000000 | 01 DEC 2014 | 00102000001 | 00102000003 | 1000000 | REPO |
| | | | | | | |
| | | | | | | |
| | | | | | | |

សូមមេត្តាផ្តល់ដំណឹងដល់យើងខ្ញុំពីលទ្ធផលនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ខណៈដែលប្រតិបត្តិការចុះបញ្ជីបញ្ញើមូលបត្រត្រូវបានបញ្ចប់។

Please kindly inform us the result of recording of the ownership transfer once it has been completed.

**យើងខ្ញុំសូមជូនភ្ជាប់មកជាមួយនូវ**/We are attaching the following documents:

- □ **កិច្ចសន្យាទិញ-លក់ផ្តាច់**/Straight forward sale contract
- □ **កិច្ចសន្យាទទួលទិញវិញ**/Repo contract
- □ **កិច្ចសន្យាដាក់បញ្ចាំ**/Collateral contract
- □ **លិខិតបញ្ជាក់ពីការទូទាត់**/Payment voucher

ថ្ងៃទី/Date ............ខែ/Month..................ឆ្នាំ/Year..................

**ភាគីអ្នកទទួល**/Receiver party

(Authorized Person Sign and Seal)

ថ្ងៃទី/Date............ខែ/Month............/Year..................

**ភាគីអ្នកប្រគល់**/Deliver party

(Authorized Person Sign and Seal)

# ឧបសម្ព័ន្ធ៨

*Institution Letter Head* *Form NBC CD. 08*

**ពាក្យសុំលក់មូលបត្រអាចជួញដូរបាន**

APPLICATION FOR SELLING BACK NCD

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានប្រតិបត្តិការ**

To: Director of the Banking Operation Department

យើងខ្ញុំស្នើសុំលក់មូលមូលបត្រអាចជួញដូរបានជូនធនាគារជាតិនៃកម្ពុជា ដែលព័ត៌មានលម្អិត

# ឧបសម្ព័ន្ធ៩

***Institution Letter Head*** *Form NBC CD. 08*

## ពាក្យសុំលក់មូលបត្រអាចជួញដូរបាន

### សូមគោរពជូន
### លោកប្រធាននាយកដ្ឋានប្រតិបត្តិការ

# ឧបសម្ព័ន្ធ១០

| | Oct-16 | | Nov-16 | | Dec-16 | | Jan-17 | | Feb-17 | | Mar-17 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Saturday | | Tuesday | | Thursday | | Sunday | | Wednesday | | Wednesday | | 1 |
| 2 | Sunday | | Wednesday | | Friday | | Monday | | Thursday | | Thursday | | 2 |
| 3 | Monday | | Thursday | | Saturday | | Tuesday | | Friday | | Friday | | 3 |
| 4 | Tuesday | | Friday | | Sunday | | Wednesday | | Saturday | | Saturday | | 4 |
| 5 | Wednesday | | Saturday | | Monday | | Thursday | | Sunday | | Sunday | | 5 |
| 6 | Thursday | | Sunday | | Tuesday | | Friday | | Monday | | Monday | | 6 |
| 7 | Friday | | Monday | | Wednesday | | Saturday | | Tuesday | | Tuesday | | 7 |
| 8 | Saturday | | Tuesday | | Thursday | | Sunday | | Wednesday | | Wednesday | | 8 |
| 9 | Sunday | | Wednesday | | Friday | | Monday | | Thursday | | Thursday | | 9 |
| 10 | Monday | | Thursday | | Saturday | | Tuesday | | Friday | | Friday | | 10 |
| 11 | Tuesday | | Friday | | Sunday | | Wednesday | | Saturday | | Saturday | | 11 |
| 12 | Wednesday | | Saturday | | Monday | | Thursday | | Sunday | | Sunday | | 12 |
| 13 | Thursday | | Sunday | | Tuesday | | Friday | | Monday | | Monday | | 13 |
| 14 | Friday | | Monday | | Wednesday | | Saturday | | Tuesday | | Tuesday | | 14 |
| 15 | Saturday | | Tuesday | | Thursday | | Sunday | | Wednesday | | Wednesday | | 15 |
| 16 | Sunday | | Wednesday | | Friday | | Monday | | Thursday | | Thursday | | 16 |
| 17 | Monday | | Thursday | | Saturday | | Tuesday | LPCO4 - Auction | Friday | | Friday | | 17 |
| 18 | Tuesday | LPCO1 - Auction | Friday | | Sunday | | Wednesday | | Saturday | | Saturday | | 18 |
| 19 | Wednesday | | Saturday | | Monday | | Thursday | LPCO1 - Maturity<br>LPCO4 - Settlement | Sunday | | Sunday | | 19 |
| 20 | Thursday | LPCO1 - Settlement | Sunday | | Tuesday | LPCO3 - Auction | Friday | | Monday | | Monday | | 20 |
| 21 | Friday | | Monday | | Wednesday | | Saturday | | Tuesday | LPCO5 - Auction | Tuesday | LPCO6 - Auction | 21 |
| 22 | Saturday | | Tuesday | LPCO2 - Auction | Thursday | LPCO3 - Settlement | Sunday | | Wednesday | | Wednesday | | 22 |
| 23 | Sunday | | Wednesday | | Friday | | Monday | | Thursday | LPCO2 - Maturity<br>LPCO5 - Settlement | Thursday | LPCO3 - Maturity<br>LPCO6 - Settlement | 23 |
| 24 | Monday | | Thursday | LPCO2 - Settlement | Saturday | | Tuesday | | Friday | | Friday | | 24 |
| 25 | Tuesday | | Friday | | Sunday | | Wednesday | | Saturday | | Saturday | | 25 |
| 26 | Wednesday | | Saturday | | Monday | | Thursday | | Sunday | | Sunday | | 26 |
| 27 | Thursday | | Sunday | | Tuesday | | Friday | | Monday | | Monday | | 27 |
| 28 | Friday | | Monday | | Wednesday | | Saturday | | Tuesday | | Tuesday | | 28 |
| 29 | Saturday | | Tuesday | | Thursday | | Sunday | | | | Wednesday | | 29 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 30 | Sunday | | Wednesday | | Friday | | Monday | | Thursday | 30 |
| 31 | Monday | | | | Saturday | | Tuesday | | Friday | 31 |

Weekends

Public holidays

Additional holidays (private sector)

Auction Date

Settlement and Maturity Date

| | Apr-17 | | May-17 | | Jun-17 | | |
|---|---|---|---|---|---|---|---|
| 1 | Saturday | | Monday | | Thursday | | 1 |
| 2 | Sunday | | Tuesday | | Friday | | 2 |
| 3 | Monday | | Wednesday | | Saturday | | 3 |
| 4 | Tuesday | | Thursday | | Sunday | | 4 |
| 5 | Wednesday | | Friday | | Monday | | 5 |
| 6 | Thursday | | Saturday | | Tuesday | | 6 |
| 7 | Friday | | Sunday | | Wednesday | | 7 |
| 8 | Saturday | | Monday | | Thursday | | 8 |
| 9 | Sunday | | Tuesday | | Friday | | 9 |
| 10 | Monday | | Wednesday | | Saturday | | 10 |
| 11 | Tuesday | | Thursday | | Sunday | | 11 |
| 12 | Wednesday | | Friday | | Monday | | 12 |
| 13 | Thursday | | Saturday | | Tuesday | | 13 |
| 14 | Friday | | Sunday | | Wednesday | | 14 |
| 15 | Saturday | | Monday | | Thursday | | 15 |
| 16 | Sunday | | Tuesday | | Friday | | 16 |
| 17 | Monday | | Wednesday | | Saturday | | 17 |
| 18 | Tuesday | | Thursday | | Sunday | | 18 |
| 19 | Wednesday | | Friday | | Monday | | 19 |
| 20 | Thursday | LPCO4 - Maturity | Saturday | | Tuesday | | 20 |
| 21 | Friday | | Sunday | | Wednesday | | 21 |
| 22 | Saturday | | Monday | | Thursday | LPCO6 - Maturity | 22 |
| 23 | Sunday | | Tuesday | | Friday | | 23 |
| 24 | Monday | | Wednesday | | Saturday | | 24 |
| 25 | Tuesday | | Thursday | LPCO5 Maturity | Sunday | | 25 |
| 26 | Wednesday | | Friday | | Monday | | 26 |
| 27 | Thursday | | Saturday | | Tuesday | | 27 |
| 28 | Friday | | Sunday | | Wednesday | | 28 |
| 29 | Saturday | | Monday | | Thursday | | 29 |
| 30 | Sunday | | Tuesday | | Friday | | 30 |

| | | | | | | |
|---|---|---|---|---|---|---|
| 31 | [redacted] | [redacted] | Wednesday | [redacted] | [redacted] | 31 |

# ឧបសម្ព័ន្ធ១១

**ក្រាហ្វ ២៧ : ចំនួន ទឹកប្រាក់ NCDs ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**




ប្រភព:ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៨ : ចំនួនទឹកប្រាក់ NCDs ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**




ប្រភព:ធនាគារជាតិនៃកម្ពុជា

## មូលបត្រអាចជួញដូរបាន (NCDs)

### ទំហំទឹកប្រាក់ NCDs ដែលបានចេញផ្សាយ (ឆ្នាំ២០១៣-២០១៧)




ប្រភព : ធនាគារជាតិនៃកម្ពុជា



## ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

### ទំហំទឹកប្រាក់ដេញថ្លៃនិងទឹកប្រាក់មិនទាន់ដល់ឥណប្រតិទាន (ឆ្នាំ២០១៦-២០១៧)




ប្រភព : ធនាគារជាតិនៃកម្ពុជា

# ឧបសម្ព័ន្ធ១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៤៧៤.០១៦-៨២៧.សណ

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦

## សេចក្ដីជូនដំណឹង
## ស្ដីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា LPCO
## លើកទី ០១ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ០១ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ទទួលបានអត្រាការប្រាក់ដេញថ្លៃ៣% និងទឹកប្រាក់ដែលដេញបានគឺ១២.០០០.០០០.០០០ (ដប់ពីរប៊ីលាន)រៀល។

អាស្រ័យដូចបានជម្រាបជូនពត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា
លេខ ធ៥-០៦៧-ធ២៣-ស.ជ.ក

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦

## សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCO
## លើកទី ០២
## ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ០២ នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ៣
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន : ៨.៤០០.០០០.០០០ (ប្រាំបីប៊ីលានបួនរយលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនពត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកនាយកដ្ឋានប្រតិបត្តិការ
តាមរយៈលេខទូរស័ព្ទ៖ ០១២ ៩៦៩៦៤៨/ ០៧៧ ៩៦១៩៩១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៨៥ ០៦៧ ១០០/២ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCO
## លើកទី ០៣
## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ០៣ នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ១
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន: ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកនាយកដ្ឋានប្រតិបត្តិការ
តាមរយៈលេខទូរស័ព្ទ៖ ០១២ ៩៦៩៦៤៨/ ០៧៧ ៩៦១៩៩១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ. [illegible]

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCO លើកទី ០៤ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី០៤ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ៣
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន: ៩.៤០០.០០០.០០០ (ប្រាំបួនប៊ីលានបួនរយលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកនាយកដ្ឋានប្រតិបត្តិការ

តាមរយៈលេខទូរស័ព្ទ: ០១៧ ៤៩៨ ៥០៨ / ០៧៧ ៩៦១៩៩១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩៥ ០១៧ ... ០៧/១៧ ន.ស.ក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCO
## លើកទី ០៥
## ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី០៥ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ១
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន: ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកនាយកដ្ឋានប្រតិបត្តិការ

តាមរយៈលេខទូរស័ព្ទ: ០១២ ៩៦៩ ៦៤៨/ ០៧៧ ៩៦១ ៩៩១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ០៦
## ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ០៦ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : គ្មាន
- អត្រាការប្រាក់ : គ្មាន
- ទឹកប្រាក់ដែលដេញបាន: គ្មាន ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកនាយកដ្ឋានប្រតិបត្តិការ
តាមរយៈលេខទូរស័ព្ទ: ០១២ ៩៦៩ ៦៤៨/ ០៧៧ ៩៦១ ៩៩១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.០១៧-៣៣៣.ធក.ក                    រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ០៧
## ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ០៧ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ១
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន: ៨.០០០.០០០.០០០ (ប្រាំបីពាន់លាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សូមទំនាក់ទំនង ៖

លេខទូរស័ព្ទ : (៨៥៥-២៣) ៧២២ ២២១ EX ១០៤៨ / (៨៥៥-២៣)៧២៤ ៩៦៣

សារអេឡិចត្រូនិក : lpco_nbc@nbc.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ. [illegible]

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ៨
## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី៨ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ១
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន: ៤០.០០០.០០០.០០០ (សែសិបប៊ីលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សូមទំនាក់ទំនង ៖

លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣/ (៨៥៥-២៣) ៧២២ ២២១ EX ១០៤៨

សារអេឡិចត្រូនិក : lpco_info@nbc.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.០១៧.៥៤៥ ត.ស.ប

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ៩
## ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ៩ នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ១
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន : ៨.000.000.000 (ប្រាំបីប៊ីលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សូមទំនាក់ទំនង ៖

លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣/ (៨៥៥-២៣) ៧២២ ២២១ EX ១០៤៨

សារអេឡិចត្រូនិក : lpco_info@nbc.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីអំពី
## លទ្ធផលនៃការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ១០
## ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសាធារណជនជ្រាបថា ការដេញថ្លៃប្រតិបត្តិការ LPCO លើកទី ១០ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ទទួលបានលទ្ធផលដូចខាងក្រោម៖

- គ្រឹះស្ថានចូលរួម : ១
- អត្រាការប្រាក់ : ៣%
- ទឹកប្រាក់ដែលដេញបាន : ១៦.០០០.០០០.០០០ (ដប់ប្រាំមួយប៊ីលាន) រៀល ។

អាស្រ័យដូចបានជម្រាបជូនព័ត៌មានខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុព្រមទាំងសាធារណជនជ្រាប ។

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣/ (៨៥៥-២៣) ៧២២ ២២១ EX ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh